## ជីវប្រវត្តិ

លោក **ទូច-តីមស្រ៊ាន** កើតនៅឆ្នាំ១៩៧៤ ក្នុងគ្រួសារកសិករ នៅក្នុងភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ

## ការសិក្សា

២០០៩ បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យខេមរៈ

២០០៧ បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យបៀលប្រាយ

២០០៣ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

២០០១ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ នៅពុទ្ធិកវិទ្យាល័យសម្ដេច **ជួន-ណាត**

១៩៩៦ ពុទ្ធិកបឋមសិក្សាវត្តសុន្ទរវង្ស ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ

១៩៨០ សាលាបឋមសិក្សាភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ

## មុខតំណែងនិងការងារ

សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការភាសាវិទ្យាខ្មែរនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការនៃការបង្កើតពាក្យនិងកម្រិតពាក្យនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ប្រធានសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរនៃវត្តខ្ទណ្ឌាលោម

ISBN-13 : 978-99963-705-3-3
9 789996 370533

ជំនួយស្មារតី

# សទ្ទានុក្រមសទិសសព្ទ

សាស្ត្រាចារ្យ ទូច-តីមស្រ៊ាន

សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព. ស. ២៥៥៧ គ. ស. ២០១៣

ជំនួយស្មារតី

# សទ្ទានុក្រមសទិសស្វរ

សាស្ត្រាចារ្យ ទូច-តីមស្រ៊ាង
សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព. ស. ២៥៥៧ គ. ស. ២០១៣

**សទ្ធានុក្រមសទិសសូរ**


រៀបរៀង : លោក **ឌូច-គីមស្រ៊ាង**

ជំនួយការ : លោក **អ៊ុន-សុភា**

ឧត្ដមទីប្រឹក្សា : ព្រះតេជព្រះគុណ **យស-ហ៊ុត** ខេមចារោ

: ព្រះតេជព្រះគុណ **ឈីម-ថេង** សោតណោ

: ឯកឧត្ដម នាយឧត្ដមសេនីយ៍ **តេង-សាវង្ស**

: ឯកឧត្ដម ឧត្ដមសេនីយ៍ឯក **ម៉ម-សំ**

: ឯកឧត្ដម ឧត្ដមសេនីយ៍ទោ **អឿ-សាវ៉ន**

: Mr. Christopher Lee

ពិនិត្យអក្ខរាវិរុទ្ធ : ព្រះតេជព្រះគុណ **ម៉ែន-ខបុល** ឥន្ទជ្ជោតោ

: កញ្ញា **ថៃ-សារ៉ែម**

: លោក **គង់-ភុន**

: លោក **គោត-ច័ន្ទខបុល**

: លោក **ឯម-ឫទ្ធី**

រចនាក្រប : កញ្ញា **នូ-ស៊ីនួន**



ISBN-9 789996 370533

បោះពុម្ពលើកទី១ ថ្ងៃពុធ ទី១៨ ខែកញ្ញា ឆ្នាំ២០១៣


រក្សាសិទ្ធិគ្រប់បែបយ៉ាង ការថតចម្លងស្នាដៃរៀបរៀងនៃអ្នកនិពន្ធមកធ្វើអាជីវកម្មជាអំពើល្មើសច្បាប់


ឧបត្ថម្ភបោះពុម្ព : **មូលនិធិអៀង**

រោងពុម្ព : JSRC Printing House

អាសយដ្ឋានចែកចាយ : បណ្ណាគារសន្តិភាព បណ្ណាគារអន្តរជាតិ សាលាភ្សូឌីលីដី...

# **អារម្ភកថា**

សៀវភៅសទ្ទានុក្រមសទិសសូរ នេះ ដែលលោក លោកស្រី និស្សិត អ្នកសិក្សាស្រាវជ្រាវកំពុងតែអាន បង្កើតឡើងក្នុងគោលបំណងបំពេញសំណូមពរ លោកគ្រូ អ្នកគ្រូ អ្នកសិក្សាស្រាវជ្រាវទាំងឡាយដែលតែងតែចង់បានចំណេះដឹងអក្សរសាស្ត្រខ្មែរ ដើម្បីយល់ដឹងគំនិតល្អៗពីសទ្ទានុក្រមសទិសសូរៗ

ការប្រមូលស្នាដៃរបស់អ្នកនិពន្ធទាំងឡាយ ពីអតីតកាលមករៀបរៀងជាសៀវភៅនេះឡើង គឺមានគោលបំណង គោលដៅ វិសាលភាព និយមន័យរួមចំណែកអភិរក្សនិងអភិវឌ្ឍភាសាជាតិយើងផងនិងចែករំលែកបទពិសោធ ព្រមទាំងទស្សនៈបុរាណនិងទស្សនៈថ្មីជុំវិញវិស័យភាសាខ្មែរយើងផង។

ក្នុងការសិក្សាកន្លងទៅគេបានកំណត់ថា **ភាសា អក្សរសាស្ត្រ** ជាមែកធាងសំខាន់ជាងគេនៃវប្បធម៌ ជាមេនៃប្រាជ្ញា ជាមេនៃការសិក្សា ជាមេនៃសិល្បៈ និងជាអត្តសញ្ញាណជាតិយ៉ាងសំខាន់បំផុត។

ប្រសិនបើមានកំហុសឆ្គងខ្លឹមសារដោយប្រការណាមួយ សូមអ្នកសិក្សាមេត្តាអធ្យាស្រ័យផងចុះ។ ខ្ញុំនឹងរង់ចាំទទួលយកកំហុសដោយសុច្ឆន្ទៈ មនសិការសោមនស្សនូវការកែលម្អពីសំណាក់លោកអ្នកសិក្សាស្រាវជ្រាវទាំងឡាយ។

រាជធានីភ្នំពេញ ១៤កើត ខែភទ្របទ ឆ្នាំម្សាញ់ បញ្ចស័ក ព. ស. ២៥៥៧

ត្រូវនឹងថ្ងៃពុធ ទី១៨ ខែកញ្ញា ឆ្នាំ២០១៣

សាស្ត្រាចារ្យ **ខូច-គីមស្រ៊ាង**

បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យានិងអក្សរសាស្ត្រខ្មែរ

# កតញ្ញុតាធម៌

កូនសូមក្រាបថ្វាយបង្គំនិងលើកហត្ថាប្រណម្យឧទ្ទិសស្នាដៃនេះ ជូនចំពោះលោកឪពុក **ទ្រី-យ៉េន** អ្នកម្តាយ **អ៊ុំ-មាស** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតជីវិតកូន។

កូនសូមសម្តែងនូវកតញ្ញូកតវេទិតាធម៌ ជាអនេកប្បការចំពោះលោកមានគុណទាំងទ្វេដែលបានផ្តល់កំណើតដល់រូបកូននិងបានចិញ្ចឹមបីបាច់ ថែរក្សា ការពារ អប់រំរូបកូនឱ្យឃ្លាតចាកឆ្ងាយពីអវិជ្ជា។ ព្រះគុណដ៏មហាប្រសើរនេះ រូបកូនចងចាំអស់មួយជីវិត ហើយមិនអាចរកអ្វីយកមកតបស្នងសងគុណឱ្យស្មើបានឡើយ។

សៀវភៅដែលកូនបានរៀបរៀងនេះគ្រាន់តែជាស្នាដៃតូចមួយប៉ុណ្ណោះ តែវាជាសក្ខីភាពមួយបញ្ជាក់ថា រូបកូនមិនបណ្តោយពេលវេលាឱ្យកន្លងផុតទៅដោយឥតប្រយោជន៍នោះទេ ហើយក៏មិនប្រើប្រាស់វាដើម្បីប្រព្រឹត្តអំពើមិនគួរគប្បីណាមួយនោះដែរ។

កូនសូមសច្ចាប្រព្រឹត្តតែកុសលកម្មនិងរស់នៅជាពលរដ្ឋល្អក្នុងសង្គមជាតិជារៀងដរាប។

រាជធានីភ្នំពេញ ១៤កើត ខែភទ្របទ ឆ្នាំម្សាញ់ បញ្ចស័ក ព. ស. ២៥៥៧

ត្រូវនឹងថ្ងៃពុធ ទី១៨ ខែកញ្ញា ឆ្នាំ២០១៣

សាស្ត្រាចារ្យ **ទូច-គីមស្រ៊ាង**

បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យានិងអក្សរសាស្ត្រខ្មែរ

**ឧទ្ទិសកថា**

សូមខ្ញុំឧទ្ទិសស្នាដៃនេះថ្វាយ ប្រគេន ជូនចំពោះ

- បុព្វបុរសខ្មែរគ្រប់រូបដែលបានធ្វើពលិកម្មគ្រប់យ៉ាងដើម្បីការពារជាតិមាតុភូមិ

- កវី បណ្ឌិត អ្នកនិពន្ធ អ្នកប្រាជ្ញខ្មែរគ្រប់ជំនាន់ដែលបានខិតខំថែរក្សា ការពារវប្បធម៌ ភាសា អក្សរសាស្ត្រជាតិឱ្យបានរីកចម្រើនគង់វង្សរហូតមក

- សម្តេចព្រះមហាសុមេធាធិបតី **ជួន-ណាត** ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី១ គណៈមហានិកាយ ដែលព្រះអង្គបានបន្សល់ទុកស្នាព្រះហស្តដ៏ពិសេសសម្រាប់ខ្មែរគ្រប់ជំនាន់គឺ **វចនានុក្រមខ្មែរ**

- បុព្វការីជនរបស់ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបាទទាំងអស់

សូមជួយទ្រទ្រង់វិស័យវប្បធម៌ អក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ចនិរន្តរ៍។

រាជធានីភ្នំពេញ ១៤កើត ខែភទ្របទ ឆ្នាំម្សាញ់ បញ្ចស័ក ព. ស. ២៥៥៧

ត្រូវនឹងថ្ងៃពុធ ទី១៨ ខែកញ្ញា ឆ្នាំ២០១៣

សាស្ត្រាចារ្យ **នួច-គីមស្រ៊ាង**

បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យានិងអក្សរសាស្ត្រខ្មែរ

## នាមសប្បុរសជនអ្នកមានឧបការគុណក្នុងការចារធម្មទាន
## ដើម្បីដំណើរការសមាគមន្ត្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

| | |
|---|---|
| - **មណ្ឌលព័ត៌មានស្ត្រីកម្ពុជា** | ព្រះតេជព្រះគុណ **យស-ហ៊ុត** ខេមចារោ |
| - CAM-PAINT **ថ្នាំពណ៌ជាត** | **សាលារៀនវ៉េស្តឡាញន៍** |
| - លោក **ប៊ិច-ប៉ូឡែន** | **សាលារៀនឈាត្យូឡាញន៍** |
| - លោក **សោម-សម្បត្តិ** | និង លោកស្រី **អ៊ុក-ចន្ថា** |
| - មហាឧបាសិកា **សុខ-អ៊ឹម** | និង បុត្រ **ត្វ-ឆៃគៀង** |
| - ឧបាសិកា **តិម-ស៊ីមឿន** | និង ឧបាសិកា **ឡេង-ចេងលាង** |
| - ឧបាសក **ដាំ-កុយ** | និង ឧបាសិកា **សុខ-ពៅ** |
| - លោក **ឡាយ-វណ្ណារ័ត្ន** | និង លោកស្រី **វណ្ណា-យី** |
| - លោក **ហែម-សុភខន** | និង លោកស្រី **ភី-លីណា** |
| - លោក **សាម-ស៊ុនឡឿន** | និង លោកស្រី **ឈា-ផានី** |
| - លោក **ឃីម-សុខហេង** | និង លោកស្រី **ប៊ូ-សុខឡេង** |
| - ឯកឧត្តម **តេង-សាវង្ស** | និង លោកជំទាវ **ស៊ាង-តឹម** |
| - ឯកឧត្តម **ម៉ម-សំ** | និង លោកជំទាវ **អ៊ុត-បុប្ផាផល្គុន** |
| - ឯកឧត្តម **អៀវ-សាវ៉ន** | និង លោកជំទាវ **ពៅ-សារឿន** |
| - ឯកឧត្តម **ភីម-ជាត** | និង លោកជំទាវ **ត្នង-ម៉ាឡា** |
| - ឯកឧត្តម **លី-វណ្ណានី** | និង លោកជំទាវ **ប្រាក់-ចិន្ដា** |
| - ឯកឧត្តម **ម៉ម-ឈាង** | និង លោកជំទាវ **ឯម-មុំ** |
| - ឯកឧត្តម **ង៉ុយ-ហាក់** | និង លោកជំទាវ **ង៉ូវ-សុខឡេង** |
| - ឯកឧត្តម **ចាន់-សារ៉េត** | និង លោកជំទាវ **ស៊ឹម-ថារី** |
| - លោក **ហេង-ប៊ុនធី** | និង លោកស្រី **លី-អ្នូវតឹម** |

- ឧបាសក **អៀង-អឿន** និង ឧបាសិកា **អៀង-សាគីម**
- លោក **ហ៊ុល-សុផា** និង លោកស្រី **ពេជ្រ-ចន្ថា**
- លោក **សែ-ទុទ្ធី** និង លោកស្រី **ព្រំ-សុម៉ាលី**
- លោក **នុត-រ៉ានី** និង លោកស្រី **អ៊ុន-សោភា**
- លោក **សៀន-ចាន់ឡាដែត** និង លោកស្រី **ហុក-សុខា**
- លោក **អោម-សេងបូរ៉ា** និង លោកស្រី **ស្វូ-សេរីវឌ្ឍនា**
- លោក **គុយ-វ៉ាត** និង **លោកស្រី**
- លោក **ឱន-សុមេធារិទ្ធ** និង **លោកស្រី**
- លោក **រិទ្ធ-ឌីភា** និង លោកស្រី **ប្រាក់-លីណា**
- មហាឧបាសក **ជា-ផ្លុង** និង មហាឧបាសិកា **កេត-ត្នួង**
- លោក **ឈួរ-អាង** និង លោកស្រី **ង៉ូវ-ស៊ុនសុខនី**
- សាស្ត្រាចារ្យ **យាង-ច័ន្ទរិទ្ធា** និង លោកស្រី **លី-ហាក់ហៀង**
- លោក **ស្រ៊ី-ព្រេង (សំណាព)** និង លោកស្រី **ឈុំ-ផាន់ណា**
- ឧបាសក **ទ៉ក់-ហ៊ាង** និង ឧបាសិកា **ម៉ឹង-សឿន**
- លោក **បូ-គីមលាង** និង លោកស្រី **ឈឹម-ស៊ីយ៉ាន**
- លោក **នួន-ហ៊ីន** នាយកសាលាប៉ែលធីទី១០ និង លោកស្រី **ឈឹម-ចន្ទកែវ**
- លោក **ចាន់-ឌីតា** នាយកសាលាប៉ែលធីទី៥ និង លោកស្រី **ជឹម-ស្រីមនោ**
- លោក **ស្វ៉ាត-ឥន្ថា** នាយកសាលាប៉ែលធីទី១ និង លោកស្រី **ឈឹម-ឡាលីន**
- ឧបាសក **ចាយ-ផាន់** និង ឧបាសិកា **ឌី-ណារិន**
- លោក **ទង-វេង** កញ្ញា **ចាយ-កុសុំ**
- លោក **ឆាវ-សំពិសិដ្ឋ** និង លោកស្រី **ហៀត-ផាវីល័យ**
- លោក **ហ្លួយ-វីរិន** និង លោកស្រី **លាប-រស្មី**

# **សេចក្តីថ្លែងអំណរគុណ**

សូមថ្លែងអំណរគុណជាអតិបរមាចំពោះឧត្តមភរិយា **ម៉ែន-សេងយ៉ុង** ហៅ **ស្រីចិន** និងក្រុមគ្រួសារដែលបានយោគយល់និងចែករំលែកពេលវេលាដើម្បីឱ្យខ្ញុំអាចមានឱកាសសិក្សាស្រាវជ្រាវប្រកបដោយជោគជ័យ។

ជាពិសេស សូមគោរពសម្តែងការដឹងគុណដ៏ជ្រាលជ្រៅបំផុតសន្តានចិត្តឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ច័ន្ទ-សំណាព្វ** ដែលបានលះបង់កម្លាំងកាយវាចាចិត្ត និងបញ្ញាស្មារតី ព្រមទាំងពេលវេលាដ៏មានតម្លៃជួយបង្ហាត់បង្រៀនខ្ញុំបាទលើមុខជំនាញន័យវិទ្យា វាទកម្ម វចនសព្ទ វចនវិទ្យា វេយ្យាករណ៍ប្រៀបធៀប វិភាគវេយ្យាករណ៍ វិធីសាស្ត្រស្រាវជ្រាវ។ ម្យ៉ាងទៀតសូមគោរពសម្តែងការកោតសរសើរនិងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោក **អៀង-សុធារ៉ា** ប្រធានមូលនិធិអៀងដែលមានសន្តានចិត្តសប្បុរិសធម៌ឧបត្ថម្ភធម្មទានថវិកាជួយបោះពុម្ពសៀវភៅសទ្ទានុក្រមសទិសសួរ ក្នុងគោលដៅសំខាន់ផ្សព្វផ្សាយអក្សរសាស្ត្រខ្មែរដើម្បីឱ្យប្រជាពលរដ្ឋទូទៅបានយល់ដឹងពីគុណតម្លៃវប្បធម៌ភាសាអក្សរសាស្ត្រជាតិ ព្រមទាំងដើម្បីឱ្យដំណើរការសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ។

សូមថ្លែងអំណរគុណឯកឧត្តម លោកជំទាវ សប្បុរសជន និងលោកអ្នកអានដែលបានជួយលើកស្ទួយគុណតម្លៃរៀបរៀង សៀវភៅរបស់ខ្ញុំនិងសូមមេត្តាអធ្យាស្រ័យកំហុសឆ្គងដោយប្រការផ្សេងៗ។ ខ្ញុំនឹងរីករាយទទួលយកការកែលម្អកំហុសដើម្បីឱ្យខ្ញុំបានបម្រើអស់លោកអ្នកអានកាន់តែប្រសើរជាងមុនថែមទៀត។ *សូមអរគុណ !*

រាជធានីភ្នំពេញ ១៤កើត ខែភទ្របទ ឆ្នាំម្សាញ់ បញ្ចស័ក ព. ស. ២៥៥៧

ត្រូវនឹងថ្ងៃពុធ ទី១៨ ខែកញ្ញា ឆ្នាំ២០១៣

# មាតិកានុក្រម


ឈ្មោះមាតិកា ទំព័រ

១- អំពី ក, ករ, ក៏......................................................១

២- អំពី កញ្ជា, កាន់...................................................២

៣- អំពី កប្ប, កាប់....................................................២

៤- អំពី កម្ម, កាំ.......................................................៣

៥- អំពី កល, កល់, កលហ៍...........................................៣

៦- អំពី កា, ការ, កាណ៍, ការណ៍.................................៤

៧- អំពី កាប, កាព្យ.....................................................៥

៨- អំពី កោដិ, កោដ្ឋ, កោត.........................................៦

៩- អំពី កំពង់, កំពុង........... ......................................៦

១០- អំពី ក្រម, ក្រំ......................................................៧

១១- អំពី ក្រិត, ក្រឹត្យ.................................................៨

១២- អំពី ក្លែង, ខ្លែង..................................................៨

១៣- អំពី ខញ្ជា, ខន្ធ, ខាន់ ឬ ខ័ន.................................៩

១៤- អំពី ខ្ជូ, ខ្ជូរ....................................................១១

១៥- អំពី ខោ, ខោរ.................................................១១

១៦- អំពី គ, គរ.......................................................១២

១៧- អំពី គត់, គុត..................................................១២

១៨- អំពី គុណ, គុន...............................................១៣
១៩- អំពី គុម្ព, គុំ, គំ...............................................១៧
២០- អំពី គូ, គូរ...............................................១៨
២១- អំពី គូថ, គូធ...............................................១៩
២២- អំពី គេ, គេហ៍...............................................១៩
២៣- អំពី គ្រា, គ្រាហ៍...............................................២០
២៤- អំពី ខា, ខារ...............................................២១
២៥- អំពី ចក្រ, ចាក់...............................................២២
២៦- អំពី ចណ្ឌា, ចន្ទ ឬ ចន្ទ្រ, ចន្ទន៍...............................................២២
២៧- អំពី ចិត, ចិត្ត ឬ ចិត្រ...............................................២៣
២៨- អំពី ចោត, ចោទ, ចោទក៍...............................................២៤
២៩- អំពី ចំណោត, ចំណោទ...............................................២៥
៣០- អំពី ឆន្ទ, ឆាន់...............................................២៥
៣១- អំពី ឆ្អា, ឆ្អារ...............................................២៥
៣២- អំពី ឆ្វេង, ឈ្វេង...............................................២៦
៣៣- អំពី ជន, ជន់, ជន្ម...............................................២៦
៣៤- អំពី ជី, ជីរ...............................................២៧
៣៥- អំពី ជីប, ជីព...............................................២៨

៣៦- អំពី ដួ, ដួរ........................................................២៨

៣៧- អំពី ដ, ដរ, ដ៏....................................................២៩

៣៨- អំពី ដា, ដារ......................................................៣០

៣៩- អំពី ដុស, ដុះ.....................................................៣១

៤០- អំពី ត្លុក, ថ្លុក.....................................................៣១

៤១- អំពី ត្លុម, ត្លុំ.....................................................៣២

៤២- អំពី ត្នួ, ត្នួរ.......................................................៣២

៤៣- អំពី ទ, ទរ.........................................................៣២

៤៤- អំពី ទស, ទស់, ទស្សន៍, ទោះ.................................៣៣

៤៥- អំពី ទា, ទារ......................................................៣៦

៤៦- អំពី  ទាល់, ទ័ល.................................................៣៧

៤៧- អំពី ទុក, ទុក្ខ.....................................................៣៨

៤៨- អំពី ទូ, ទូរ........................................................៤១

៤៩- អំពី ទេ, ទេរ......................................................៤២

៥០- អំពី ទោ, ទោរ....................................................៤២

៥១- អំពី ទុំ, ទំ.........................................................៤៣

៥២- អំពី ទ្រព្យ, ទ្រាប់.................................................៤៤

៥៣- អំពី ទ្រុស្ត, ទ្រុះ.................................................៤៥

៥៤- អំពី ឆន, ឆន់..........................................................៤៥

៥៥- អំពី ឆុំ, ឆំ.................................................................៤៥

៥៦- អំពី ឆា, ឆារ...........................................................៤៦

៥៧- អំពី ឆាក់, ឆ្អក...................................................៤៧

៥៨- អំពី ឆិច, ឆីច, ឆ្អឹច...........................................៥១

៥៩- អំពី ឆួត, ឆៅ......................................................៥៣

៦០- អំពី ឆុះ, ឆ៊ុះ, ឆោះ..............................................៥៤

៦១- អំពី ឆ័យ, ឆៃ.......................................................៥៥

៦២- អំពី ជត់, ជន........................................................៥៥

៦៣- អំពី ឈាឋ, ឈាត, ឈាត្រ, ឈាន.............................៥៦

៦៤- អំពី ជិត, ជិន.......................................................៥៩

៦៥- អំពី ជុស្ស, ជុះ.....................................................៦០

៦៦- អំពី ជូ, ជូតិ...........................................................៦១

៦៧- អំពី ជួ, ជួរ...........................................................៦១

៦៨- អំពី ជន្ទុំ, ជន្ទុំ......................................................៦២

៦៩- អំពី ជម្រាស់, ជម្រះ...........................................៦៣

៧០- អំពី ប្រញប្ត, ប្រញប្តិ, ប្រញាប់............................៦៣

៧១- អំពី ប្រថម, ប្រថំ.................................................៦៤

៧២- អំពី ប្រមាថ, ប្រមាទ........................................................៦៥

៧៣- អំពី ប្រស់, ព្រោះ.................................................................៦៦

៧៤- អំពី ប្រសប់, ប្រសព្វ........................................................៦៨

៧៥- អំពី ប្រាស់, ប្រះ.................................................................៦៩

៧៦- អំពី ប្រុស, ប្រុះ..................................................................៦៩

៧៧- អំពី ប្រួញ, ព្រួញ................................................................៧០

៧៨- អំពី ប្រៀប, ព្រាប, ព្រៀប.................................................៧០

៧៩- អំពី ប្រេង, ព្រេង................................................................៧១

៨០- អំពី ផ្កា, ផ្ការ.....................................................................៧៣

៨១- អំពី ព, ពរ, ពណ៌, ព័រ.......................................................៧៤

៨២- អំពី ពស់, ពោះ..................................................................៧៦

៨៣- អំពី ពាក, ពាក្យ, ពាគ.......................................................៧៧

៨៤- អំពី ពាន់, ព័ន្ធ....................................................................៧៨

៨៥- អំពី ពារ, ពៀរ....................................................................៧៩

៨៦- អំពី ពី, ពីរ..........................................................................៨០

៨៧- អំពី ពុក, ពុក្ក, ពុគ............................................................៨១

៨៨- អំពី ពុរ, ពុល......................................................................៨៩

៨៩- អំពី ពេចន៍, ពេជ្រ...............................................................៩០

៩០- អំពី ព្រឹក, ព្រឹក្ស.........................................................៩១

៩១- អំពី ភប់, ភព.................................................................៩១

៩២- អំពី មី, មីរ.....................................................................៩២

៩៣- អំពី ម្លូ, ម្លូរ....................................................................៩៣

៩៤- អំពី ម្រ័ក្សណ៍, ម្រាក់.........................................................៩៤

៩៥- អំពី យន់, យន្ត ឬ យន្ត្រ....................................................៩៥

៩៦- អំពី រក្ស, រាក់...................................................................៩៦

៩៧- អំពី រង់, រង្គ.....................................................................៩៨

៩៨- អំពី រដ្ឋ, រត្ន, រថ..............................................................៩៩

៩៩- អំពី រម្យ, រុំ, រំ..................................................................១១១

១០០- អំពី រស, រស់..................................................................១១២

១០១- អំពី រាប, រាពណ៍............................................................១១៧

១០២- អំពី រឹត, ឫទ្ធិ..................................................................១១៨

១០៣- អំពី របស់, របោះ..........................................................១២០

១០៤- អំពី ឫក, ឫក្ស.................................................................១២១

១០៥- អំពី លប់, លុប.................................................................១២២

១០៦- អំពី លក់, ល័ក្ខ (ល័ខ), លក្ខណ៍ ឬ លក្សណ៍............១២៤

១០៧- អំពី លាប, លាភ.............................................................១២៧

១០៨- អំពី លិច, លេច..................................................១២៩

១០៩- អំពី លេស, លេះ ឬ លែះ....................................១៣២

១១០- អំពី ស, សរ........................................................១៣៣

១១១- អំពី សក្តិ, ស័ក, សាក់..........................................១៣៥

១១២- អំពី សត្ថ ឬ សត្វ, សត្យ, សាត់..............................១៣៧

១១៣- អំពី សា, សារ......................................................១៤១

១១៤- អំពី សាសន៍, សាស្ត្រ, សះ......................................១៤៨

១១៥- អំពី សិង, សិង្ហ, សឹង.............................................១៥១

១១៦- អំពី សិល្ប៍, សីល...................................................១៥១

១១៧- អំពី សុក, សុក្រ, សុខ.............................................១៥៥

១១៨- អំពី សូ, សូរ, សូរ្យ.................................................១៥៩

១១៩- អំពី សូន, សូន្យ.....................................................១៦១

១២០- អំពី សួ, សួរ, សួគ៌................................................១៦២

១២១- អំពី សៀ, សៀរ.....................................................១៦៣

១២២- អំពី សេ, សេរ.......................................................១៦៤

១២៣- អំពី សំឈុស, សំឈុះ.............................................១៦៤

១២៤- អំពី ស្លា, ស្លារ......................................................១៦៥

១២៥- អំពី ស្លុស, ស្លុះ....................................................១៦៥

១២៦- អំពី ស្មេ, ស្មេរ.................................................១៦៥

១២៧- អំពី សម្រិត, សំរឹទ្ធ ឬ សំរិទ្ធិ.................................១៦៦

១២៨- អំពី ស្រាស់, ស្រះ..............................................១៦៧

១២៩- អំពី ស្រុស, ស្រុះ.................................................១៦៨

១៣០- អំពី ស៊្រែស, ស៊្រែះ ឬ ស្រែះ.....................................១៦៨

១៣១- អំពី សង់, សង្ឃ..................................................១៦៩

១៣២- អំពី សង្ហា, សង្ហារ..............................................១៧៣

១៣៣- អំពី សប់, សប្ត, សព, សព្វ.....................................១៧៤

១៣៤- អំពី សព្ទ, សាប់..................................................១៧៨

១៣៥- អំពី ស្និត, ស្និទ្ធ...................................................១៧៨

១៣៦- អំពី ស្លេះ, ស្លេស្ម.................................................១៧៩

១៣៧- អំពី ហត្ថ, ហាត់...................................................១៨០

១៣៨- អំពី ហា, ហារ.....................................................១៨២

១៣៩- អំពី ហៀ, ហៀរ....................................................១៨៣

១៤០- អំពី ហោ, ហោរ...................................................១៨៤

១៤១- អំពី អគ, អគ៌.....................................................១៨៧

១៤២- អំពី អង្គ, អង់.....................................................១៩០

១៤៣- អំពី អដ្ឋ, អត្ថ, អាត់.............................................១៩៤

១៤៤- អំពី អ័ព្ទ ឬ អ័ព្ភ ឬក៏ អ័ព្រ, អាប់..............................២០១

១៤៥- អំពី អា, អារ.....................................................២០២

១៤៦- អំពី អាចារ, អាចារ្យ...........................................២០៤

១៤៧- អំពី អាស, អាសន៍..............................................២០៧

១៤៨- អំពី អាជី, អាជិ.................................................២០៩

## អក្សរសង្ខេប

ប្រើក្នុងសន្ទានុក្រមសទិសសួរនេះ

*កិ.* : កិរិយាសព្ទ

*កិ. នុ.* : កិរិយានុគ្រោះ

*កិ. វិ.* : កិរិយាវិសេសន៍

*គុ.* : គុណសព្ទ

*ចិ.* : ចិន (ភាសាចិន)

*ន.* : នាមសព្ទ

*និ.* : និបាតសព្ទ

*ប.* : បរិវារសព្ទ

*ប. សំ.* : បកតិសំខ្យា (ប្រើត្រឹមតែ *សំខ្យា.* គឺសំខ្យាសព្ទក៏មាន)

*បា.* : បាលី (ភាសាបាលី)

*បា. សំ.* : បាលីនិងសំស្រ្កឹតលាយគ្នា

*បុ. ស.* : បុរិសសព្វនាម

*ព. កា.* : ពាក្យកាព្យ គឺពាក្យសម្រាប់ប្រើក្នុងកាព្យ

*ព. ខ្ព.* : ពាក្យខ្ពស់

*ព. ទេ.* : ពាក្យទេសនា (ពាក្យសម្រាប់ប្រើក្នុងការទេសនា)

*ព. បុ.* : ពាក្យបុរាណ

*ព. ប្រ.* : ពាក្យប្រៀប

| | |
|---|---|
| *ព. ផ្ទ.* | : ពាក្យផ្ទុយ (ពាក្យជាទំនាស់នឹងគ្នា) |
| *ព. ស.* | : ពុទ្ធសករាជ |
| *ព. សា.* | : ពាក្យសាមញ្ញ (ពាក្យធម្មតា ឬ ពាក្យផ្សារ) |
| *រ. ស.* | : រាជសព្ទ |
| *វិ. ស.* | : វិសេសនសព្វនាម |
| *វេវ.* | : វេវចនៈ |
| *ស.* | : សៀម (ភាសាសៀម) |
| *សព្វ.* | : សព្វនាម |
| *សំ.* | : សំស្រ្កឹត (ភាសាសំស្រ្កឹត) |
| *អា. និ.* | : អាយតនិបាត |

# សទ្ទានុក្រមសនិសស្វរ

## អំពី ករ, ករ, ក៏

**ក** *ន.* អវយវៈដែលតពីក្បាលទៅស្មាឬទៅខ្លួននៃមនុស្សសត្វ។ ដៃជើងមនុស្ស ក៏មាន **ក** ដែរ :

- កដៃ

- កជើង។

❖ ទងខាងដើមក្ជួរស្រូវក៏ហៅ **ក** ដែរ :

- កស្រូវ។

❖ កន្លែងដែលតជាប់ពីមាត់ដបចុះទៅទល់នឹងក្អែងក៏ហៅ **ក** ដែរ :

- កដប

- កក្អម។

❖ តាំងផ្តើម, តាំងធ្វើ :

- កភូមិ

- កកើត

- កសាង

- កចេតិយ។

**ករ** *ន.* (បា.) ដៃ :

- លើកករប្រណម្យ។

**ក៏** *និ.* ពាក្យសន្ធានមានសំឡេងកញ្ជក់ខ្លីសម្រាប់និយាយតប្រយោគដោយឡែក :

- ខ្ញុំក៏ទៅ
- អ្នកក៏ទៅ
- ធ្វើដូច្នេះក៏បាន
- របស់នេះរូបក៏ល្អ តម្លៃក៏ថោក។

## អំពី **កណ្ឌ, កាន់**

**កណ្ឌ** *ន.* (បា.) ព្រួញ; គ្រាប់កាំភ្លើង; ទង់; ដើម; កំណាត់, បរិច្ឆេទ, វគ្គ, ខ្សែ :

- សាស្ត្រាមួយកណ្ឌ។

**កាន់** *កិ.* ចាប់ខ្ជាប់ :

- កាន់ដំបង
- កាន់ឆត្រ។

❖ ប្រកាន់ការ, ចាប់ការដោយមុខៗ :

- កាន់ការណាត្រូវធ្វើការនោះឱ្យហើយ។

## អំពី **កប្ប, កាប់**

**កប្ប** *ន.* (បា.) កាលដែលនៅតាំងយូរអង្វែង :

- មួយកប្ប
- ភ្លើងប្រល័យកប្ប។

**កាប់** *កិ.* ប្រហារដោយគ្រឿងមុខមុត :

- ដាវ

- ពូថៅ

- កាំបិត...។

## អំពី **កម្ម, កាំ**

**កម្ម** *ន.* (បា.) អំពើ; ទោះអំពើល្អក្ដី អាក្រក់ក្ដីក៏ហៅថា **កម្ម** :

- ទទួលរងកម្ម

- រងអំពើដែលខ្លួនបានធ្វើ។

**កាំ** *ន.* អ្វីៗដែលរៀបជាជាន់, ជាថ្នាក់សម្រាប់ទល់, សម្រាប់ទ្រ, សម្រាប់រង :

- កាំរទេះ

- កាំជណ្ដើរ...។

## អំពី **កល, កល់, កលហ៍**

**កល** *ន.* (សំ.) ឧបាយយ៉ាងល្អិត, ល្បិច :

- ប្រយ័ត្នចាញ់កលគេ

- ដំណើរហ្នឹងជាកលឧបាយរបស់គេទេ។

**កល់** *កិ.* ទ្រពីក្រោម, សែមពីក្រោមដើម្បីឱ្យស្មើមិនឱ្យល្អៀង ដើម្បីឱ្យហើប ឱ្យខ្ពស់ឡើង :

- ដាក់កំណល់កល់ឱ្យខ្ពស់ឡើង។

**កលហ៍** *ន.* (បា. សំ. **កលហ**) ជម្លោះ។

## អំពី **ការ, ការ, ការណ៍, ការណ៍**

**ការ** *ន.* បំពង់សម្រាប់ដាក់ទឹក ធ្វើដោយលោហធាតុផ្សេងៗឬដោយដីលាយពណ៌ :

- កាទឹក។

❖ *កិ.* សរសេរអាសយដ្ឋាន គឺសរសេរចុះឈ្មោះលំនៅអ្នកដែលនឹងទទួលសំបុត្រ នៅក្រោមសំបុត្រដែលនឹងផ្ញើទៅ :

- កាក្រោមសំបុត្រ។

**ការ** *កិ.* មូរសរសៃសូត្រ, មូរសរសៃអំបោះជាដើមដោយខ្នារ :

- ការសូត្រ

- ការអំបោះ...។

❖ បិទបាំង, រាំង, ឃាត់ខាំងមិនឱ្យសត្រូវចូលមក។

- ការខ្លួន

- មេមាន់ការកូន។

❖ រៀបចំអាវាហវិវាហមង្គល, ផ្សំផ្គុំបុរសនិងស្ត្រីឱ្យបានគ្នាជាគូស្វាមីភរិយា :

- ស៊ីការ

- ការកូន

- ការក្មួយ...។

❖ *ន.* កិច្ចដែលត្រូវធ្វើ, អំពើដែលត្រូវធ្វើ :

- ធ្វើការ

- មានការ

- ការអ្វីខ្លះ?

❖ *ន.* ពាក្យសម្រាប់ប្រើដាក់នៅខាងដើមពាក្យដែលជាកិរិយាសព្ទផ្សេងៗដើម្បីធ្វើឱ្យទៅជានាមសព្ទ :

- ការសំពះ

- ការពិសោធ...។

**កាណ៌** *ន.* (**សំ. កណ៌** "ត្រចៀក") សព្ទថ្លៃប្រើជារាជសព្ទ :

- ព្រះកាណ៌ (ត្រចៀកស្ដេច)។

**ការណ៍** *ន.* (**បា. ការណ**) ហេតុ, ដំណើរ :

- សេចក្ដីរាយការណ៍

- ទាស់ការណ៍ហើយឯង។

## អំពី **កាប, កាព្យ**

**កាប** *ន.* ខ្នោះសម្រាប់រឹតគាប :

- កាបរទេះ។

**កាព្យ** *ន.* (**បា.**) របៀបពាក្យច្នូនមានឃ្លោងឃ្លា (កំណាព្យ) :

- តែងកាព្យ។

## អំពី កោដិ, កោដ្ឋ, កោត

**កោដិ** *ប. សំ.* (បា. សំ.) ចំនួន១០លាន។

**កោដ្ឋ** *ន* (បា.) ជង្រុក។ របស់សម្រាប់ដាក់សព, របស់សម្រាប់ដាក់ធាតុ។ ឈ្មោះឈើមួយប្រភេទ។

**កោត** *កិ.* ស្ញែង, ស្ងើច :

- គួរកោតគេដែរ។

❖ ច្រើននិយាយនាំមុខពាក្យ ក្រែង, ញញើត, ខ្លាច, ខាម :

- កោតខ្លាច
- កោតខាម
- កោតក្រែង
- កោតញញើត។

## អំពី កំពង់, កំពុង

**កំពង់** *ន.* ទីកន្លែងមាត់ទឹកដែលជនានុជនចុះឡើងឬចតទូកជាដើម :

- កំពង់ទូក
- កំពង់ទឹក
- កំពង់កប៉ាល់។

បញ្ចុះកំពង់ : ស៊ី (ព. ទ្រ.)។

កំពង់ចាម *ន.* ឈ្មោះខេត្តមួយនៃកម្ពុជរដ្ឋ។

កំពង់ឆ្នាំង *ន.* ឈ្មោះខេត្តមួយនៃកម្ពុជរដ្ឋ។

កំពង់ត្រឡាច *ន.* ឈ្មោះស្រុកមួយក្នុងខេត្តកំពង់ឆ្នាំង។

កំពង់ត្រាច *ន.* ឈ្មោះស្រុកមួយក្នុងខេត្តកំពត។

កំពង់ធំ *ន.* ឈ្មោះខេត្តមួយនៃកម្ពុជរដ្ឋ។

កំពង់លែង *ន.* ឈ្មោះស្រុកមួយក្នុងខេត្តកំពង់ឆ្នាំង។

កំពង់សៀម *ន.* ឈ្មោះស្រុកមួយក្នុងខេត្តកំពង់ចាម។

កំពង់សោម *ន.* ឈ្មោះខេត្តមួយនៃកម្ពុជរដ្ឋ។

កំពង់ស្ពឺ *ន.* ឈ្មោះខេត្តមួយនៃកម្ពុជរដ្ឋ។

កំពង់ស្វាយ *ន.* ឈ្មោះស្រុកមួយក្នុងខេត្តកំពង់ធំ។

**កំពុង** *គុ.* ដែលពេញកំពូក កណ្តាលឡើងមិនរាបស្មើ :

- ពេញកំពុង

- ថ្គាល់កំពុង។

❖ *និ.* កាលក្នុង, កាលដែលជាប់នៅក្នុងរវាង :

- កំពុងស៊ី

- កំពុងធ្វើការ។

## អំពី ក្រម, ក្រំ

**ក្រម** *ន.* (សំ.) លំដាប់, ក្បួន, បែប, ពួក, ប៉ែក :

- ក្រមព្រហ្មទណ្ឌ

- ក្រមរដ្ឋប្បវេណី។

❖ ងារក្នុងតំណែងរាជការឃុំក្នុងសម័យពីដើម, ក្លាយមកពីពាក្យ "**ក្រមការ**"។

**ក្រាំ** ***កិ.*** ប្រកប, បញ្ចុះលោហជាតិផ្សេងៗនឹងដែក :

ក្រំមាស : យកមាសមកប្រកបឬបញ្ចុះនឹងដែក។

❖ ***គុ.*** ខ្ទាំ, ស្លូតស្លប់, អន់, សៅហ្មង :

- ក្រំខ្លួន

- ក្រំចិត្ត

- ក្រៀមក្រំ។

## អំពី ក្រិត, ក្រឹត្យ

**ក្រិត** ***កិ.*** លាក់ចំណាំ, លាក់ឱ្យមានស្នាមជាសម្គាល់ :

- ក្រិតលើឈើចំណាំ។

**ក្រឹត្យ** ***ន.*** (**សំ.**) កិច្ច, ច្បាប់ :

- កាន់ក្រឹត្យវិន័យ។

## អំពី ក្លែង, ខ្លែង

**ក្លែង** ***កិ.*** ធ្វើឱ្យប្លែកចាករូបរាងដើមទៅយករូបរាងថ្មីដើម្បីកុំឱ្យគេស្គាល់ឬពោលឱ្យខុសចាកសម្ដីដើមទៅពោលសម្ដីថ្មីដើម្បីកុំឱ្យគេដឹង :

- ក្លែងរូប

- ក្អែងសម្ដី

- ក្អែងសំឡេង។

**ខ្លែង** *ន.* ឈ្មោះសត្វស្លាបមួយប្រភេទសម្បុរក្រហមក្រមៅ ត្រង់កមានសម្បុរ-ស ចំពុះខុប ក្រញាំជើងចំណាប់មាំអាចចាប់សត្វតូចៗស៊ីបាន។

❖ រូបតំណាងសត្វខ្លែងធ្វើដោយក្រដាសសម្រាប់បង្ហើរ :

- ខ្លែងបង្ហើរ

- បង្ហើរខ្លែង។

## អំពី ខណ្ឌ, ខន្ធ, ខាន់ ឬ ខ័ន

**ខណ្ឌ** *ន.* (**បា. សំ.**) សង្កាត់, ប៉ែក, កំណត់, ប៉ែកអាណាខេត្ត។ នាទីដែលមានឃុំច្រើន ហើយដែលមានចៅហ្វាយខណ្ឌមួយកាន់កាប់រាជការ, ខណ្ឌត្រូវឡើងស្រុក ហើយស្រុកត្រូវឡើងខេត្ត, ជួនកាលខណ្ឌត្រូវឡើងផ្ទាល់ទៅខេត្តក៏មាន :

- ខណ្ឌភ្នំពេញ។

❖ កម្រិត, បម្រាមផ្ដាច់មិនឱ្យធ្វើ :

- ព្រះរាជខណ្ឌ

- ទៅបានឥតមានខណ្ឌទេ។

**ខន្ធ** *ន.* (**បា.**) ក; ដើម; គំនរ :

- ពួក

- កង

- ប្រជុំ

- កំណត់។

ខន្ធ៥ : រូបក្ខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, វិញ្ញាណក្ខន្ធ។

ទម្លាយខន្ធ : ស្លាប់, រំលាងខន្ធ។

រំលោងខន្ធ : ស្លាប់, ទម្លាយខន្ធ។

រំលត់ខន្ធ : ចូលនិព្វាន។

**ខាន់** ឬ **ខ័ន** *ន.* គ្រឿងសស្ត្រាមួយប្រភេទផ្លែមានមុខទាំងពីរខាង មានសណ្ឋានដូចផ្លែលំពែង ប៉ុន្តែធំវែងជាងផ្លែលំពែង ដងខ្លីច្រើនជាងដងលំពែង មានស្រោមសម្រាប់ស៊កសៀតចង្កេះបាន ដោយមានខ្សែចងស្រាក់ភ្ជាប់នឹងស្រោមនោះ, ខ្មែរហៅគ្រឿងសស្ត្រានេះតាមសំនៀងសៀមថា **ខ័ន** (**ព្រះខ័ន** ឬ **ព្រះខាន់**) ព្រោះសៀមសរសេរ **ខរគ៍** ដោយបំប្លែងពីសំស្ក្រឹតថា **ខឌ្គ**។ យើងហៅថា **ព្រះខ័ន** យូរណាស់ហើយ :

- ព្រះខ័នរាជ

- មន្ទីរព្រះខ័ន ឬ ហោព្រះខ័ន។

☞ យើងសរសេរជា **ព្រះខាន់** ក៏បាន ប៉ុន្តែបើពួកកវីខ្មែរត្រូវការប្រើក្នុងការតែងកាព្យ **ខឌ្គ** ឬ **ព្រះខឌ្គ** តាមសម្ផស្សកាព្យដែលចាប់ជួនគ្នាខ្លះ

វិញក៏អាចប្រើបានព្រោះយើងមានពាក្យ **ខ្ចុ** ក្នុងវចនានុក្រមខ្មែររបស់ប្រទេស
យើងហើយ។

**ពាក្យភាព្យ**

| | | |
|---|---|---|
| ព្រហ្មទត្តមហាក្សត្រ | ទតឃើញព្រះខគ្គនៅដៃកុមារ | ឈ្មោះទីឃាវុ |
| ដូចនឹងប្រហារ | លុះទ្រង់ជ្រាបការណ៍ | ទើបក្សាន្តព្រះទ័យៗ |

**អំពី ខ្ចូ, ខ្ចូរ**

**ខ្ចូ** *កិ.* ធ្វើសម្លមួយឈ្មោះ **ខ្ចូ**។

❖ *ន.* ឈ្មោះសម្លមួយយ៉ាងដែលគេយកក្តាមឬបង្កងមកបុកឱ្យល្អិត
ហើយលាយនឹងទឹកពូតយករសជាតិមកចម្អិន :

- ខ្ចូក្តាម
- ខ្ចូបង្កង។

**ខ្ចូរ** *ន* អាការៈនៅក្នុងក្បាលឬក្នុងឆ្អឹងខាប់ដូចចាហួយ :

- ខ្ចូរឆ្អឹង
- ខ្ចូរក្បាល។

**អំពី ខោ, ខោរ**

**ខោ** *ន* (**ចិ.** «ខូវ») សម្លៀកបំពាក់ធ្វើដោយសំពត់ មានសណ្ឋានផ្សេងៗ
មានជើង មានចង្កេះ :

- ខោជើងវែង

- ខោស្នាប់ភ្លៅ។

**ខោរ** *ន.* ឈ្មោះស្វាមួយពួកសម្បុរខ្មៅជាងសត្វក្រិសរូបធំមុខខ្លី :

- ស្វាខោរ។

**អំពី គ, គរ**

**គ** *គុ.* ពតសម្គី :

- មនុស្សគ។

❖ ប្រើជាមួយនឹងលោហជាតិវិញថា **គគស្វរ** :

- ប្រាក់គ។

❖ *ន.* ឈ្មោះឈើជាដំណាំ ផ្លែមានសរសៃជាប៉ុយសំឡីសម្រាប់ច្រក ញាត់ខ្នើយ, កែប, ពូកជាដើម : ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តហាមភិក្ខុសាមណេរមិនឱ្យប្រើប្រាស់ពូកញាត់សំឡីគ, ទ្រង់អនុញ្ញាតឱ្យប្រើប្រាស់ពូកញាត់ស្មៅ, ញាត់ជក់ដូងជាដើមបាន, ឯកែប, ឱ្យញាត់សំឡីគបាន។

**គរ** *កិ.* ធ្វើឱ្យជាគំនរ។

**អំពី គត់, គុត**

**គត់** *គុ.* ដែលត្រឹម, ដែលត្រឹមកំណត់មិនលើសមិនខ្វះ :

- មានតែ១០គត់។

❖ ដែលជិតមិនលេច, ដែលមិនជ្រាបទឹក :

- ឆត្រនេះគត់ភ្លៀងល្អណាស់។

**គុត** *កិ.* ប្រហារ, កាប់, ពិឃាត, ធ្វើឃាត, សម្លាប់; ច្រើននិយាយថា វាយគុត, ធ្វើគុត។

❖ *ន.* ការប្រហារ, ការពិឃាត, ការធ្វើឃាត, ការសម្លាប់មនុស្ស។ អ្នកខ្លះនិយាយថា **គត់** ប៉ុន្តែក្នុងពាក្យកាព្យបុរាណថា **គុត** ដូចមានពាក្យកាព្យថា លុះដល់ទីធ្វើគុត ឱ្យនាងលុតព្រះជង្ឃា...(សាស្ត្រាលក្ខណវង្ស)។

**អំពី គុណ, គុន**

**គុណ** *ន.* (បា. សំ.) ដំណើរធ្វើឱ្យចម្រើនកើនឡើង :

- លេខគុណ

- គុណ១០ជា២០។

❖ សេចក្តីចម្រើន; ថ្នាក់; ជាន់; លក្ខណៈ; ចំណែក; សេចក្តីល្អ; សភាព; បែបបទ...។ សភាវធម៌ដែលចម្រើនឡើងដោយលក្ខណៈរបស់ខ្លួន គួរគោរពតបស្នងនឹងខានពុំបាន :

- គុណគ្រូ

- គុណបិតា

- គុណមាតា

- គុណលោកអ្នកមានឧបការៈលើខ្លួន។

❖ ធម៌ដែលគួរនឹក, ធម៌គួររំពឹងដល់ :

- គុណព្រះពុទ្ធ

- គុណព្រះធម៌

- គុណព្រះសង្ឃ។

✣ បើរៀងភ្ជាប់ខាងដើមសព្ទដទៃ, ដូចជា :

គុណកថា : ការថ្លែងអំពីគុណ, ការនិយាយអំពីគុណ, ការចរចាអំពីគុណ : គុណកថានេះពីរោះណាស់គួរតែស្ដាប់។

គុណកម្ម : អំពើ គឺគុណ, អំពើជាគុណប្រយោជន៍។

គុណជាតិ : គុណគ្រប់យ៉ាង, គុណជាត : គុណជាតិ៣យ៉ាងគឺ សីល, សមាធិ, បញ្ញា ហៅថា ត្រៃសិក្ខា ព្រោះដំណើរជាលំអានគួរបុគ្គលសិក្សាហាត់រៀនបំពេញឱ្យមានបរិបូណ៌ដើម្បីជាផ្លូវរំងាប់ទុក្ខ។

សីល : គុណជាតញុំាងកាយវាចាឱ្យបរិសុទ្ធ។

សមាធិ : គុណភាពញុំាងចិត្តឱ្យស្ងប់។

បញ្ញា : គុណជាតិនាំឱ្យស្គាល់ខុសត្រូវ, គុណជាតិនាំឱ្យស្គាល់ការណ៍ពិត។

គុណធម៌ : ធម៌ដែលមានដំណើរចម្រើនសេចក្ដីសុខទុក្ខតាមជាន់តាមថ្នាក់ បានខាងអំពើល្អអាក្រក់ គឺបុណ្យបាបដែលបុគ្គលធ្វើ :

- ប្រណី

- សេចក្ដីល្អ

- សេចក្ដីបរិសុទ្ធិ

- សេចក្ដីអាណិត...។

គុណនាម : នាមសព្ទដែលប្រាប់ដំណើរនាមនាម ឱ្យឃើញលក្ខណៈផ្សេងៗគ្នា ដូចពាក្យថា ខ្មៅ, ស, តូច, ធំ, វែង, ខ្លី, ខ្ពស់, ទាប, វៀច, ត្រង់...។

គុណបទ : បទដែលជាវិសេសនៈរបស់នាមនាម ដូចពាក្យថា ផ្ទះខ្ពស់, ផ្ទះទាប, ផ្ទះចាស់, ផ្ទះថ្មី ជាដើម; ខ្ពស់, ទាប់, ចាស់, ថ្មីជាគុណបទរបស់ ផ្ទះ។

គុណភាព : ភាពនៃគុណ, ដំណើរដែលមានគុណ; របស់ដែលមានអានុភាពសក្ដិសិទ្ធិ :

- ឱសថនេះមានគុណភាពវិសេសណាស់។

គុណវិបត្តិ : វិបត្តិនៃគុណ, ការប្រាសចាកគុណ, ការខ្វះសេចក្ដីល្អ, ការគ្មានផលប្រយោជន៍ :

- មនុស្សម្នាក់ៗតែងមានគុណវិបត្តិខ្លះ មានគុណសម្បត្តិខ្លះ។

គុណវិសេស : ដំណើរប្លែករបស់គុណ គឺដំណើរប្រព្រឹត្តល្អដោយកាយវាចាចិត្តឥតសៅហ្មង។

គុណវុឌ្ឍិ : សេចក្ដីចម្រើនដោយគុណ, ដំណើរចម្រើនដោយសេចក្ដីល្អ, ដោយសេចក្ដីរុងរឿង, ដោយសេចក្ដីបរិសុទ្ធ។

គុណសព្ទ : សម្ដីដែលប្រាប់ដំណើរនាមនាមឱ្យឃើញលក្ខណៈផ្សេងៗគ្នា។

គុណសម្បត្តិ : សេចក្ដីដល់ព្រមដោយគុណ គឺការបរិបូណ៌ដោយសេចក្ដីល្អ, សេចក្ដីបរិសុទ្ធ; មនុស្សនេះមានគុណសម្បត្តិគួរឱ្យសរសើរ, គុណសម្បទា ។

គុណសម្បទា : សេចក្ដីដល់ព្រមដោយគុណ គឺការបរិបូណ៌ដោយសេចក្ដីល្អ, សេចក្ដីបរិសុទ្ធ; មនុស្សនេះមានគុណសម្បត្តិគួរឱ្យសរសើរ, គុណសម្បត្តិ ។

គុណាករ : អណ្ដូង, កំណប់នៃសេចក្ដីល្អ, នៃសេចក្ដីបរិសុទ្ធ; ប្រជុំនៃសេចក្ដីល្អ, សេចក្ដីបរិសុទ្ធគ្រប់យ៉ាង; បុគ្គលអ្នកបរិបូណ៌ដោយសេចក្ដីបរិសុទ្ធ។

គុណានិសង្ស : ដំណើរបង្ហូរផលផ្ដល់ឱ្យបានសម្រេចប្រយោជន៍ដោយសារគុណ, ផលនៃសេចក្ដីល្អ, ផលដែលឱ្យតាមដំណើរសេចក្ដីបរិសុទ្ធ។

គុណានុភាព : អានុភាពនៃគុណ គឺអំណាច, តេជះ, ឫទ្ធិនៃសេចក្ដីល្អ, សេចក្ដីបរិសុទ្ធ។

គុណូបការៈ : សេចក្ដីទំនុកបម្រុង,គុណោបការៈ, អនុគ្រោះដោយគុណ គឺសេចក្ដីទំនុកបម្រុងឱ្យល្អ, ឱ្យដុះដាលចម្រើន; ហៅថា ឧបការគុណ វិញក៏បាន...។

គុណោបការៈ : សេចក្ដីទំនុកបម្រុង, គុណូបការៈ,អនុគ្រោះដោយគុណ គឺសេចក្ដីទំនុកបម្រុងឱ្យល្អ, ឱ្យដុះដាលចម្រើន។

**គុន** *ន.* ឈ្មោះសិល្បៈខាងគ្រឿងអាវុធសម្រាប់ចូលប្រលូកលោតហក់តយុទ្ធផ្ទាល់ខ្លួន, ជាចំណេះវិសេសម្យ៉ាងរបស់អ្នកចម្បាំងពីក្នុងសម័យបុព្វបុរសរាល់ប្រទេស :

- គុនដំបង
- គុនដាវខ្លី
- គុនខែល
- គុនដាវវែង
- គុនកាំបិតគ្រលុក...។

## អំពី គុម្ព, គុំ, គំ

**គុម្ព** *ន.* (**បា. សំ.**) ពួក, ប្រជុំ, បន...។ ពួក, ប្រជុំដើមឈើឬដំណាំផ្សេងៗ :

- គុម្ពឈើ
- ចេក១គុម្ព។

**គុំ** *កិ.* ប៉ងដោយអាក្រក់, ប៉ងធ្វើការបៀតបៀនគេ, ចងចិត្តព្យាបាទគេ, ចងគំនុំ :

- គុំវាយ
- គុំបម្រុងនឹងសងសឹកវិញ។

គុំក្គួន : គុំយ៉ាងខ្ជាប់ខ្ជួនមិនបណ្ដាលឱ្យភ្លេច :

- វាគុំក្គួនយូរហើយ បម្រុងនឹងលបវាយមិត្តចាស់របស់វា។

**តំ *កិ.*** ចាក់ទឹកត្រាំឱ្យរបើកបាយក្តាំងដែលនៅជាប់នឹងបាតឆ្នាំង។ បាយក្តាំងដែលរបើកនោះហៅថា ឫាយតំ ឬ ឫាយតំទឹក។

**អំពី តួ, តួរ**

**តួ *ន.*** ស្នាមភ្លោះព័ទ្ធជុំវិញបន្ទាយឬវាំង; ពាក្យបុរាណហៅ **កសិណ** ដូចយ៉ាង **កសិណ** ព័ទ្ធជុំវិញនគរវត្តជាដើម ជាប់ហៅរៀងមករហូតដល់សព្វថ្ងៃនេះ។

✧ ចំនួនពីរផ្ទឹមគ្នា, ចំនួនមួយគូ, ចំនួនពីរគូ :

គូកម្ម : បុរសនិងស្ត្រីបានគ្នាជាប្តីប្រពន្ធ ហើយព្រាត់គ្នាទៅវិញក្នុងកាលឆាប់រហ័ស។

គូព្រេង : បុរសនិងស្ត្រីដែលយល់ថា បានកសាងជាមួយគ្នាអំពីអតីតជាតិមកហើយ បានគ្នាជាប្តីប្រពន្ធនៅឋិតថេរជាមួយគ្នាជាសុខតទៅហៅថា **បុព្វេសន្និវាស**។

គូស្រករ : ប្តីប្រពន្ធដែលមានអាយុស្រករគ្នា : មានគូស្រករ។

**តួរ *កិ.*** ធ្វើឱ្យកើតជាគំនូរតំណាងរូបរាងសរពើដោយដីខ្មៅ, ប៉ាកកា ឬ ជក់ :

- គូររូប
- គូរគំនូរ
- គូរវាស
- គូរផែនទី។

✧ (ប.) ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ គិត :

- គិតគូរ

- គិតហើយសឹមគូរ។

## អំពី គូថ, គូទ

**គូថ** *ន.* (បា. សំ.) អាចម ឬ អាចម៍, ឧច្ចារៈ, លាមក :

- អង្គុយបន្ទោគូថក្នុងបង្គន់។

**គូទ** *ន.* (បា. សំ.) អវយវៈត្រង់ចំណែកកាយខាងក្រោយជិតវច្ចទ្វារ :

- ដាក់គូទអង្គុយ។

❖ ប៉ែកអវយវៈនេះបុរាណពីដើមហៅថា **តពោក** ឬ **ត្រពោក**, សូម្បីសព្វថ្ងៃនេះអ្នកបាត់ដំបង, អ្នកសៀមរាបជាដើម ក៏នៅប្រើពាក្យនេះដែរ :

- ដាក់តពោកអង្គុយ។

## អំពី គេ, គេហ៍

**គេ** *ទុ. ស.* សម្រាប់និយាយចំពោះអ្នកដទៃដោយមិនចេញចំឈ្មោះអ្នកណាមួយឡើយ :

- ខ្ញុំមិនបានរកគេទេ

- កុំអាលទៅចាំគេមកជួបសិន។

គេយើង : ទាំងគេ ទាំងយើង។

គេឯង : ទាំងគេផង ទាំងខ្លួនឯងផង : ធ្វើយ៉ាងហ្នឹងមិនល្អទេនាំឱ្យខូចកេរ្តិ៍ឈ្មោះគេឯងអស់ហើយ។ បើមិនមានដំណើរទាក់ទងមកខ្លួនឯងផងទេ

កុំប្រើពាក្យថា **គេឯង** ត្រូវនិយាយត្រឹមពាក្យ **គេ** ប៉ុណ្ណោះ និង **ឯង** ឬ **គ្នាឯង** ប៉ុណ្ណោះទើបទុកជាត្រឹមត្រូវ។

**គេហ៍** *ចុ. ស.* (**បា. សំ.** «**គេហ** *ន.* ផ្ទះ, អ្នកផ្ទះ») ពាក្យសម្រាប់ប្ដីប្រពន្ធហៅគ្នាទៅវិញទៅមកដោយស្មោះស្មើ, ជាពាក្យរាបសារបស់ប្រជាជន, មានសេចក្ដីថា "អ្នកផ្ទះ" :

- គេហ៍អើយបាយឆ្អិនហើយឬនៅ?

## អំពី គ្រា, គ្រាហ៍

**គ្រា** *ន.* កាល, សម័យ :

- គ្រាក្រ
- គ្រានេះ
- គ្រានោះ
- គ្រាក្រោយ
- គ្រាអំណាត់...។

**គ្រាហ៍** *ន.* (**សំ. គ្រាហ**) ដំណើរអង, ការអបអង, ការកៀកអង។ ប្រើក្លាយមកជា *កិ.* :

- គ្រាហ៍មនុស្សឈឺ
- គ្រាហ៍មនុស្សមានរបួស។

## អំពី ងា, ងារ

**ងា** *កិ.* លើកដៃឡើងជន្លួឬលើកដៃវាសរងលំនាំគុន :

- ងាដៃ

- ងាដៃជន្លួ។

**ងារ** *ន.* មុខការ, ទីតំណែងរាជការតាមបណ្ដាសក្ដិ, តាមក្រសួង, បណ្ដាសក្ដិ, យសសក្ដិ, ឋានន្ដរ :

- លោកហ្នឹងមានងារជាអ្វី

- មានងារជាលោងពិភក្ដិអក្សរ។

❖ ភាគដីល្មមកម្លាំងបុរសធ្វើមួយពេលហើយការ :

- ដីមួយងារ

- ភ្ជួរស្រែមួយព្រឹកបានពីរងារ។

❖ ការដែលចែកដោយមុខ, ដោយឡែកក៏ហៅថា **ងារ** ដែរ :

- ភ្ជួរកាន់ងារ

- ធ្វើការកាន់ងារ

- ធ្វើការតាមមុខងារ

- ធ្វើការកាន់មុខងារ។

❖ (ប.) ពាក្យនិយាយផ្សំជាមួយនឹងពាក្យការ :

ការងារ : កិច្ចការដែលត្រូវធ្វើដោយមុខ។

## អំពី ចក្រ, ចាក់

**ចក្រ** *ន.* (**សំ.**) ចក្ក, កង់, កង់មានកាំ; អាវុធមានសណ្ឋានជារង្វង់មូលមានងៀងជាបន្លាជុំវិញមានមុខមុត; មណ្ឌល, រង្វង់មូល; ប្រទេស, អាណាខេត្ត; ពួក, ហ្វូង; កងទ័ព; កណ្ដាប់ព័ទ្ធជុំវិញ...:

- ពុទ្ធចក្រ
- អាណាចក្រ។

**ចាក់** *កិ.* បុះដោយគ្រឿងប្រហារមានមុខស្រួច។ យកអ្វីៗក្រៅអំពីគ្រឿងប្រហារបុះឬរុក :

- ចាក់ក្រឡេក
- ចាក់ប្រលែង...។

❖ ចាក់រលាក់អ្វីមួយចេញពីអ្វីមួយដាក់ទៅក្នុង, ទៅលើវត្ថុឬទៅលើទីកន្លែងផ្សេង :

- ចាក់ទឹក
- ចាក់សំរាម។

## អំពី ចណ្ឌា, ចន្ទ ឬ ចន្ទ្រ, ចន្ទន៍

**ចណ្ឌា** *គុ.* (**បា. សំ.**) កាច, ក្ដៅ, ហើរ...។

❖ *ន.* កំណាច់, សេចក្ដីក្រោធ, កំហឹង...។

ទឹកចណ្ឌា (រ. ស.) : សុរា។

**ចន្ទ** *ន.* (**បា.**) សភាវៈសម្រាប់បំភ្លឺជាចម្បងជាងពន្លឺទាំងអស់ដែលភ្លឺក្នុងវេលាយប់, ចន្ទ្រ :

- ព្រះចន្ទពេញវង់ហៅតាមពាក្យធម្មតាថា លោកខែ, ខែរះ, ខែលិច, ខែភ្លឺ។

**ចន្ទន៍** *ន.* (**បា. សំ. ចន្ទន**) ឈ្មោះឈើមានខ្លឹមក្រអូប :

- ចន្ទន៍ស
- ចន្ទន៍ក្រហម។

## អំពី ចិត, ចិត្ត ឬ ចិត្រ

**ចិត** *កិ.* កាត់ជាចំណិត :

- ចិតបន្លែ

ចិតប្រួម : ចិតសម្រួលឱ្យរួមតូចខាងចុង :

- ចិត្តប្រួមខ្មៅដៃ។

**ចិត្ត** *ន.* (**បា. សំ.**) ចិត្រ, ធម្មជាតសម្រាប់សន្សំអារម្មណ៍, ធម្មជាតសម្រាប់គិត គឺ វិញ្ញាណ :

- ចិត្តល្អ
- ចិត្តត្រង់
- ចិត្តវៀច
- ចិត្តអាក្រក់...។

❖ *គុ.* ដែលគេវិចិត្តហើយ, ដែលគេធ្វើដោយផ្ចិតផ្ចង់រួចស្រេចហើយ។ ច្រើនប្រើជា *គុ.* ជាង, ផ្សំជាមួយនឹងនាមសព្ទដទៃឱ្យជាបទសមាសបានតាមគួរដល់ការប្រកប, ដូចជា :

ចិត្តកម្ម : រូបភាព, រូបដែលគេគូរ, ដែលគេឆ្លាក់, គំនូរ, ចម្លាក់...។

ចិត្តការ : ជាងគំនូរ, ចិត្រករ, ចិត្តការ្យ, ជាងលាបថ្នាំរំលេចពណ៌។

ចិត្តការ្យ : ជាងគំនូរ, ចិត្តការ, ចិត្រករ, ជាងលាបថ្នាំរំលេចពណ៌។

ចិត្រករ : ជាងគំនូរ, ចិត្តការ, ចិត្តការ្យ, ជាងលាបថ្នាំរំលេចពណ៌។

ចិត្តការិកា : ស្ត្រីជាងគំនូរ, ស្ត្រីជាងលាបថ្នាំរំលេចពណ៌។

ចិត្តវិជ្ជា : វិជ្ជាខាងការវិចិត្រ...។

ចិត្តវិទ្យា : វិទ្យាខាងការវិចិត្រ...។

## អំពី **ចោត, ចោទ, ចោទក៍**

**ចោត** *គុ.* ទីទៃពីទេរ គឺចំហុង :

- ច្រាំងចោត។

❖ ឈ្មោះក្តាមសមុទ្រមួយពួក :

- ក្តាមចោត។

**ចោទ** *កិ.* (បា.) តឿន, ដាស់តឿន; សួរដណ្តឹង; ដាក់ចំណោទ, ដាក់ប្រស្នាឱ្យរក; ប្តឹង, ប្តឹងប្រកាន់។

**ចោទក៍** *ន.* (បា. **ចោទក**) អ្នកចោទ : ខាងចោទក៍អាងថា...។

## អំពី ចំណោត, ចំណោទ

**ចំណោត** *ន.* ទីដែលចោត, កន្លែងដែលចោត :

- ចំណោតភ្នំ
- ចំណោតច្រាំង។

**ចំណោទ** *ន.* សេចក្តីចោទ, ពាក្យចោទ, ប្រស្នា :

- រកចំណោទ
- ដោះចំណោទ
- ចំណោទលេខ។

## អំពី ឆន្ទ, ឆាន់

**ឆន្ទ** *ន.* (**បា. សំ.**) ឈ្មោះដំណើរកាព្យមានកំណត់ដោយអក្សរដែលត្រូវរៀបរៀង...។

**ឆាន់** *កិ.* បរិភោគ, ស៊ី :

- ឆាន់ចង្ហាន់
- និមន្តលោកឆាន់។

❖ **ឆ. បុ. ស.** (**ស.**) ពាក្យសម្រាប់ព្រះថេរៈនិយាយចេញឈ្មោះខ្លួនថា ខ្ញុំចេញទៅរកភិក្ខុខ្ចីវស្សាឬសាមណេរ (ប្រើដោយទម្លាប់)។

## អំពី ឆ្មា, ឆ្មារ

**ឆ្មា** *ន.* បសុសត្វចតុប្បាទមួយប្រភេទជាសត្រូវនឹងកណ្តុរ :

## ពាក្យទំនឹមបុរាណ

☆ ឆ្មាមិននៅកណ្តុរឡើងរាជ្យ : អ្នកធំមិននៅអ្នកតូចតែងតែឡើងចាង។

**ឆ្មារ** *គុ.* តូចបំផុត; សម្រាប់ហៅវត្ថុដែលតូចវែងឬសំឡេងតូចស្រួច :

- ក្រូចឆ្មារ

- សំឡេងឆ្មារ

- សរសៃអំបោះឆ្មារ។

### អំពី ឆ្វេង, ឈ្វេង

**ឆ្វេង** *ន.* ទីទៃពីស្តាំ។ មនុស្សឆ្វេង គឺមនុស្សដែលនិយាយឬធ្វើការមិនចុះបែប។

**ឈ្វេង** *គុ.* ផ្កាជ្រះឥតមន្ទិល :

- ទឹកផ្កាឈ្វេង។

### អំពី ជន, ជន់, ជន្ទ

**ជន** *ន.* (**បា. សំ**) សព្វសត្វដែលកើតក្នុងលោក, មនុស្ស, អ្នកផង :

- ជនផង

- ជនទាំងពួង

- បណ្តាជនទាំងប្រុសទាំងស្រី។

❖ ប្រដាប់នេសាទមច្ឆជាតិមួយប្រភេទ។

**ជន់** *កិ.* ឡើងសាយភាយ, ទឹកជំនន់។

❖ **ព. ប្រ.** បរិបូរ, ពោរពាស; ច្រើននិយាយតែអំពីភោជនាហារឬលាភសក្ការៈដែលមានបរិបូរណាស់បរិភោគឬចែករំលែកមិនខ្វាត់ មិនចេះរលស់។

**ជន្ម** *ន.* (សំ.) កំណើត, ជីវិត, ប្រាណ :

- ព្រះជន្ម
- ជីពជន្ម
- ទ្រង់គង់ព្រះជន្មនៅឡើយ។

## អំពី ជី, ជីរ

**ជី** *ទុ. ស.* អ្នក, ឯង; ពាក្យគួរសមសម្រាប់ហៅក្មេងប្រុសដែលទើបសឹកពីសាមណេរឬសម្រាប់អ្នកធំ, នឹងអ្នកចាស់ហៅអ្នកតូចជាងឬក្មេងជាងដោយរាប់អាន។

❖ *ន.* ស្ត្រីដែលកោរសក់ស្លៀកដណ្ដប់សំពត់សកាន់សីល១០។

❖ *ន.* គ្រឿងដាំត្បូងរាងសណ្ឋានស្លឹកសីមាសម្រាប់ពាក់កូនក្មេង។ ទម្ងន់អនុភាគអំពីតម្លឹង :

- មាសទម្ងន់មួយជី។

❖ *ន.* អ្វីៗដែលមានរសជាតធ្វើឱ្យដំណាំលូតលាស់ល្អ :

- ចាក់ជីក្នុងស្រែ។
- ជីមានប្រយោជន៍សម្រាប់គ្រប់ដំណាំទាំងអស់។

**ជីរ** *ន.* (**បា. សំ.**) ឈ្មោះដំណាំមួយពួកសម្រាប់ប្រើស្លឹកជារបោយឬបំបាត់ក្លិនរសឆ្អាប; ជីរមានច្រើនយ៉ាង :

- ជីរអង្កាម
- ជីរនាងវង
- ជីរស្លឹកគ្រៃ
- ជីរលើងលាក់...។

❖ បណ្ដាជីរទាំងនុះ ជីរខ្លះមានគ្រាប់ទុំប្រើត្រាំទឹកឱ្យរីកហើយលាយស្ករធ្វើជាបង្អែមបាន។

## អំពី ជីប, ជីព

**ជីប** *កិ.* រឹតរួមបត់បង្រួញជាផ្នត់ :

- ជីបស្លា
- ជីបសំពត់...។

❖ ច្រើនប្រើជា *គុ.* ក៏មាន :

- សំពត់ជីប។

**ជីព** *ន.* (**បា. សំ. ជីវ**) ជីវិត; ច្រើននិយាយថា **ជីពជន្ម** ឬ **ជន្មជីព**។

## អំពី ជួ, ជួរ

**ជួ** *គុ.* ដែលអាក្រក់, ដែលឆ្គងមិនស្គាល់ក្ដីគួរសម :

- មនុស្សជួ។

ជូជង : ដែលជូដូចជង។

ជូជាតិ : ដែលមានរសជាតិទន់ទាប, ថោកថយ, អាក្រក់ជូជាតិ, គឺអាក្រក់ណាស់។

ជូរ : ដែលជូពន់ពេក។

**ជួរ** *ន.* របៀបរៀបរៀងគ្នា :

- ឈរជាជួរ

- ពោត៥០ជួរ។

❖ តំណវង្សត្រកូលនៃបុព្វបុរស, ជំបួរ :

- ជួរខាងម្ដាយ

- ជួរខាងឪពុក។

**អំពី ដ, ដរ, ដ៏**

**ដ ន.** ទីចម្លង, កំពង់ចម្លង :

- កំពង់ដ។

❖ ទូកសម្រាប់ចម្លងនៅកំពង់នោះក៏ហៅ **ដ** ដែរ។

- ទូកដ។

**ដរ** *កុ.* អំពីរោគដែលរើឡើងដោយប៉ះទង្គិច :

- ដំបៅដរ

- បូសដរ...។

**ដ៏** *និ.* ដែល, ដែលជា; ពាក្យជាវិសេសនៈ, មានសំឡេងខ្លីកំបុតសម្រាប់និយាយផ្សំនឹងគុណនាម ប្រើរៀងរបៀបត្រង់ខាងដើមគុណនាមដែលគួរប្រកបជាមួយផងបាន :

- ធម៌ដ៏បវរ
- ទ្រព្យដ៏ប្រសើរ។

❖ មិនប្រើជាវិសេសនៈជាចំពោះមនុស្សសត្វផងទេ កុំប្រើជាមនុស្សដ៏ស្រែ, ដ៏ចម្ការ ត្រូវប្រើពាក្យថា :

- មនុស្សអ្នកស្រែ
- មនុស្សអ្នកចម្ការ...។

### អំពី ដា, ដារ

**ដា** *ន.* បន្ទះថ្មធំរាបដូចក្ដារបែន; និយាយថា **ថ្មដា**។

**ដារ** *ន.* (**បា. សំ. តារ**) ឈ្មោះបុណ្យតូចម្យ៉ាងក្នុងពុទ្ធសាសនាជាបុណ្យទក្ខិណានុប្បទាន, ទាយកនិមន្តព្រះភិក្ខុសង្ឃស្វូត្រ **សត្តប្បករណាភិធម្ម** និង **តិរោកុឌ្ឌសូត្រ** ហើយគេរាប់បាត្ររួចឧទ្ទិសចំណែកបុណ្យជូនទៅបុព្វបេតបុគ្គលដែលចែកឋានទៅកាន់បរលោកហើយ :

- ធ្វើបុណ្យដារ
- និមន្តលោកដារ។

## អំពី ដុស, ដុះ

**ដុស** *កិ.* ខាត់, រំលីង, ពូត, ជម្រះដោយសាប៊ូ :

- ដុសក្អែល
- ដុសខោអាវ។

❖ ដុះខាត់ជម្រះឱ្យស្អាត, ឱ្យរលីង, ឱ្យជ្រះអស់មន្ទិល។

**ដុះ** *កិ.* ចាប់កំណើត, កកើត, មានពន្លក, មានដើមដងឡើង :

- ស្រូវដុះ។

❖ ចម្រើនឡើង :

- ដីដុះ
- ពុកចង្កាដុះ។

## អំពី ត្លុក, ថ្លុក

**ត្លុក** *ន.* អ្នកកំប្លែង, អ្នកក្រមាច់ក្នុងល្បែងរបាំដើម្បីឱ្យគេសើច :

- រាំចាក់ត្លុក
- រាំក្រមាច់ក្រមើម។

**ថ្លុក** *ន.* ទីដីក្រហូងដែលដក់ទឹកភ្លៀងក្នុងរដូវវស្សាតែតូចជាងត្រពាំង, ច្រើនកើតដោយសារក្របីដេក, ដោយសារទឹកហូរច្រើនឬមានកាប់ដីឱ្យមានជាក្រហូង។

ថ្លុកជង្ហុក : ទីដែលមានក្រហេងក្រហូងខ្លះ, មានជង្ហុកខ្លះ។

## អំពី ត្លុម, ត្លុំ

**ត្លុម** *ន.* ឈ្មោះសត្វស្លាបមួយប្រភេទជើងវែង សម្បុរដូចក្អែកគ្រោកមាន
វារិជជាតិជាចំណី។

**ត្លុំ** *គុ.* ដែលមូលណាស់ :

- មូលត្លុំ។

## អំពី ត្នូ, ត្នូរ

**ត្នូ** *ន.* ឈ្មោះឈើធំសាច់ស្វិតច្រើនដុះនៅទំនាប នៅព្រៃបឹងឬមាត់ទន្លេ, ស្ទឹង,
ព្រែក ជាឈើសម្រាប់ប្រើធ្វើជាឧស ជាគូគ្នានឹងរទាំង :

- ឧសត្នូមានរងើកល្អ។

**ត្នូរ** *កិ.* ដែលមានមុខជួរសំយ៉ុងចុះដោយទាស់ចិត្ត, ខុសអធ្យាស្រ័យ :

- មុខត្នូរ
- ធ្វើមុខត្នូរ។

## អំពី ទ, ទរ

**ទ** *ន.* ប្រដាប់ធ្វើដោយឈើ, ឬស្សីឬដោយស័ង្កសីជាដើមសម្រាប់រង, សម្រាប់
បង្ហូរទឹក :

- ទឹកហូរតាមទ
- ផ្ទះភ្លោះ៥ខ្នងមានទ៤កន្លែង។

❖ ផ្ទាទឹកភ្លៀងដែលធ្លាក់ពីអាកាស :

- ទន្លៃទឹកភ្លៀង។

❖ **ឆ** នេះជាសព្ទកំព្រា, ត្រូវសរសេរទទឹក (ទន្លៃទឹក) កុំច្រឡំនឹងភ្លៀងទទឹក, សំពត់ទទឹក។

**ឆរ** *កិ.* កិន, ជេរ, ស្ដីឱ្យ, បន្ទោស, វាយ, ទះ, តប់... :

- ខ្ញុំឥតដឹងរឿងហ្នឹងសោះស្រាប់តែគាត់មកដល់ភ្លាមតាំងទរខ្ញុំតែម្ដង។

**អំពី ឆស, ឆស់, ឆស្សន៍, ឆោះ**

**ឆស** *ម. សំ.* (ឆា.) ដប់ (១០) : យើងខ្ញុំបង្គំទ្រង់យសដោយម្រាមទាំងទសផ្ដង់គោរពព្រមដោយសក្ការៈទាំងគ្រប់សូមឱ្យឧបទ្រពចៀសចេញឆ្ងាយ។

ទសកណ្ឋ *ន.* (បា.) អ្នកដែលមាន-ក១០គឺ រាពណ៌ :

- ព្រះបាទទសកណ្ឋ (ក្នុងរឿងរាមកេរ្ដិ៍)។

ទសធម្ម *ន.* (បា.) ធម៌១០។ ឈ្មោះសូត្រមួយក្នុង សុត្តន្តបិដក សម្ដែងពីធម៌១០ប្រភេទ។

ទសប្បារមី *ន.* (បា.) បារមី១០ គឺចរិយាដ៏លើសលន់ឬគុណជាតិដ៏ល្អដែលគួរបំពេញមាន១០យ៉ាង :

១- ទាន : ការធ្វើអំណោយ

២- សីល : ការរក្សាកាយវាចាឱ្យបរិសុទ្ធប្រពៃ

៣- នេក្ខម្ម : ការចេញចាកកាម គឺចេញបួស

៤- បញ្ញា : ការដឹងច្បាស់នូវសេចក្ដីពិត

៥- វិរិយ : ការព្យាយាម

៦- ខន្តិ : សេចក្តីអត់ធន់

៧- សច្ច : ការកាន់សម្តីពិតមិនវេរុះ

៨- អធិដ្ឋាន : ការអធិដ្ឋានឱ្យឃើញជាក់ស្តែងតាមហេតុពិត

៩- មេត្តា : ការផ្សាយសេចក្តីរាប់អានចំពោះសព្វសត្វមិនរើសមុខ

១០- ឧបេក្ខា : ដំណើរតាំងចិត្តជើយព្រងើយដោយស្មោះស្មើ។

☞ បារមីទាំង១០នេះឯង ដែលពោធិសត្វរាល់ព្រះអង្គបំពេញឱ្យបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ។

ទសពល *គុ.* ឬ *ន.* (បា.) ដែលមានកម្លាំង១០ គឺមានកម្លាំងស្មើនឹងដំរីវិសេស១០ (ព្រះសម្មាសម្ពុទ្ធ) :

- ព្រះទសពល។

ទសពិធ *គុ.* (បា. ទសវិធ, វិ > ពិ = ទសពិធ) ដែលមាន១០យ៉ាង, មាន១០ប្រការ។

ទសពិធរាជធម៌ *ន.* (បា. ទសវិធ + រាជធម្ម) រាជធម៌ទាំង១០យ៉ាងគឺធម៌១០ប្រការសម្រាប់ព្រះរាជាទ្រង់ប្រព្រឹត្ត ព្រមទាំងណែនាំពួកសេនាបតីមន្ត្រីធំតូចនិងពួករាស្ត្រប្រជាឱ្យប្រព្រឹត្ត។

**ទសពិធរាជធម៌របស់ព្រះមហាក្សត្រមាន :**

១ - ទាន : ការធ្វើអំណោយ

២ - សីល : ការរក្សាសីល៥ជានិច្ចឬរក្សាសីល១០មួយដងមួយកាល

៣ - បរិច្ចាគ : ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ

៤ - អាជ្ជវ : ការមានសេចក្តីត្រង់

៥ - មទ្ទវ : ការមានសេចក្តីទន់ភ្លន់សុភាពរាបសា

៦ - តប : ការកាន់ឧបោសថសីលតាមកាលកំណត់ម្តងៗ

៧ - អក្កោធន : ការមានកម្តៅក្រហាយអ្នកដទៃ

៨ - អវិហឹសា : ការមិនបៀតបៀនអ្នកដទៃ

៩ - ខន្តិ : ការមានសេចក្តីអត់ធន់

១០ - អវិរោធន : ការមិនបំពានលើធម៌ច្បាប់។

ទសមុខ *ន.* ឬ *គុ.* (បា.) មុខ១០; ដែលមានមុខ១០ (រាពណ៍) :

- ព្រះបាទទសមុខ (ក្នុងរឿងរាមកេរ្តិ៍)។

**ទស់** ***កិ.*** រាំងដោយផ្ទស់ :

- ទស់ផ្ទស់

- ទស់ទឹកឱ្យចាល់។

ទស់ទ័ព : រាំងមុខទ័ពមិនឱ្យចូលមកបាន។

ទប់ទល់ : រារាំង, មើលទៅឃើងទស់គេមិនឈ្នះទេ។

រារាំង : ទប់ទល់, មើលទៅឃើងទស់គេមិនឈ្នះទេ។

❖ ទាញយកដោយតាំងសញ្ញាថារបស់ដែលគេចោលឬឥតម្ចាស់ :

- ទស់បន្ទុង

- ភិក្ខុទស់សំពត់បង្សុកូល។

**ទោះ** *និ.* ទុកជា, បើជា, បើទុកជា :

- ទោះល្អក្តីអាក្រក់ក្តី

- ទោះខ្ញុំបានមកក្តី មិនបានមកក្តី ត្រូវតែអ្នកចាត់ការនុ៎ះទៅចុះ។

**អំពី ទា, ទារ**

**ទា** *ន.* ឈ្មោះសត្វស្លាបស្រុកពួកមួយមានម្រាមជើងជាប់គ្នាស្រដៀងនឹងប្រវឹកតែមានរូបធំជាងប្រវឹក។

ដំណើរទា : ដំណើរអ៊ីកអ៊ាក តិញតុញស្រដៀងនឹងទាដើរ។

ទាកាប៉ា : ឈ្មោះទាមួយប្រភេទមានរូបរាងខ្ពស់ជាងទាធម្មតា នៅត្រង់ក្បាលមានពកជាសិរទាប សម្បុរក្របាម សណ្ឋានស្រដៀងនឹងពកផ្កែស្រុះទុំ, ចេះហើរបានប្រហែលនឹងមាន់ស្រុក។

ទាព្រៃ : ឈ្មោះបក្សីព្រៃមួយប្រភេទរូបដូចទា តែហើរខ្ពស់បានដូចពួកកុក។

**ទារ** *កិ.* ស្រដីក្រើនយករបស់ដែលគេជំពាក់, ក្រើនតឿនបន្តឹងយកប្រាក់តាមកំណត់ដែលត្រូវចេញ, ត្រូវបង់ :

- ទារប្រាក់

- ទារប្រាក់ពន្ធ។

## អំពី ទាល់, ទ័ល

**ទាល់** ***កិ.*** ឬ ***គុ.*** មិនរហូត, ទញ់ត្រុះ, ទើសផ្លូវ, ទើសដំណើរ; ខ្វះខាត, មិនគ្រប់គ្រាន់ :

- ផ្លូវទាល់
- ទាល់ច្រក
- ទាល់គំនិត
- ទាល់សោហ៊ុយ
- ទាល់ប្រាក់ចាយ។

### ភាសិតបុរាណថា

| | | |
|---|---|---|
| ដប់ទាល់ម្ដៃទាល់ | កុំឱ្យទាល់គំនិត | ដប់គិតម្ដៃគិត |
| កុំគិតការណ៍ឆ្វេង | ដប់លេងម្ដៃលេង | កុំលេងល្បែងភ្នាល់ |
| បើជ្រុលលេងហើយ | ឃើញទោសក្រទ័ល | ត្រូវកត់សម្គាល់ |
| | ស្បែស្បួចរាងចាល។ | |

❖ ***ន.*** ឈ្មោះត្រាវគោកមួយប្រភេទពួកផ្ទៅ, ដើមប្រើធ្វើជាបន្លែស្លបាន។

**ទ័ល** ***កិ.*** ទើសផ្លូវ, ទើសដំណើរ :

- ទ័លផ្លូវ
- ទ័លគំនិត
- ទ័លទ្រព្យ។

❖ *ន.* ដែលក្រីក្រទ្រព្យ, ដែលខ្សត់ទ្រព្យ :

- មនុស្សទ័ល

- អ្នកទ័ល

ទ័លប៉ុច *កិ.* ទ័លត្រឹមដូចគេចាប់ច្បុច ឬទ័លកើលទើសមិនមានផ្លូវទៅទៀត។

## អំពី ទុក, ទុក្ខ

**ទុក** ***កិ.*** ដាក់វត្ថុអ្វីក្នុងទីណាមួយដើម្បីឱ្យគង់នៅឬរក្សាអ្វីៗឱ្យគង់ :

- ទុកទ្រព្យ។

❖ បម្រុងឱ្យ, ផ្គងឱ្យ :

- ទុកបាយឱ្យ

- ទុកប្រាក់ឱ្យ។

☞ ទុកដាក់, ទុកដាក់អីវ៉ាន់មានរបៀប, ទុកឱ្យប្រយ័ត្ន។ ទុកដាក់កូនចៅរៀបចំឱ្យកូនឬឱ្យចៅមានគូស្រករ។

## ពាក្យទំនឹមបុរាណ

❖ ធ្វើស្រែមើលស្មៅ ទុកដាក់កូនចៅ មើលផៅសន្តាន។ មួយយ៉ាងថា ទុកដាក់កូនចៅ ត្រូវពិនិត្យផៅពង្ស; មួយយ៉ាងទៀតថា : មុននឹងទុកដាក់កូនត្រូវសួរបងប្អូននិងចិត្តកូនសិន។

យកចិត្តទុកដាក់ : ផ្ចង់ចិត្តប្រុងប្រយ័ត្នជានិច្ច។

**ទុក្ខ** *ន.* (បា.) សេចក្ដីព្រួយ, សេចក្ដីលំបាក (កាយនិងចិត្ត) :

- កើតទុក្ខ

- មានទុក្ខ។

❖ ឈ្មោះអរិយសច្ចទី១ បានខាងសេចក្ដីទុក្ខដែលកើតអំពីជាតិ, ជរា, ព្យាធិ, មរណៈ, សេចក្ដីសោកស្ដាយ, ខ្សឹកខ្សួល, លំបាកកាយ, តូចចិត្ត, ទង្គឹះតានតឹងចិត្ត; ហៅឱ្យពេញថា **ទុក្ខអរិយសច្ច** ឬ **ទុក្ខសច្ច**។

ទុក្ខក្ខន្ធ *ន.* (បា.) គំនរទុក្ខ, កងទុក្ខ គឺប្រជុំនៃសេចក្ដីទុក្ខគ្រប់យ៉ាង។

ទុក្ខក្ស័យ *ន.* ដំណើរអស់ទុក្ខ, ទីអស់ទុក្ខ (ព្រះនិព្វាន) :

- ព្រះនិព្វានជាទុក្ខក្ស័យ

- ព្រះអរហន្តទាំងឡាយលោកបានដល់នូវទុក្ខក្ស័យហើយ។

ទុក្ខនិរោធ *ន.* (បា.) សេចក្ដីរំលត់ទុក្ខ, ទីរំលត់ទុក្ខ, ជាឈ្មោះនៃអរិយសច្ចទី៣ បានខាងដំណើររំលត់តណ្ហាអស់មិនមានសល់ ហៅឱ្យពេញថា **ទុក្ខនិរោធអរិយសច្ច** ឬ **ទុក្ខនិរោធសច្ច**។

ទុក្ខនិរោធគាមិនី *ន.* (បា.) សេចក្ដីប្រតិបត្តិជា ផ្លូវ ឬជា ឧបាយ ឱ្យរំលត់ទុក្ខ (អដ្ឋង្គិកមគ្គ), ជាឈ្មោះនៃអរិយសច្ចទី៤ បានខាងផ្លូវមានអង្គ៨ :

១- សេចក្ដីយល់ត្រូវ

២- តម្រិះត្រូវ

៣- ការស្ដីនិយាយត្រឹមត្រូវ

៤- ការងារត្រឹមត្រូវ

៥- ការចិញ្ចឹមជីវិតត្រឹមត្រូវ

៦- ការព្យាយាមត្រូវ

៧- ការរលឹកត្រូវ

៨- ដំណើរតាំងចិត្តខ្ជាប់ខ្ជួនត្រូវ។

☞ ហៅពេញថា **ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច** ឬ **មគ្គសច្ច** ក៏បាន។

ទុក្ខនិរោធសច្ច *ន.* (បា.) សេចក្ដីរំលត់ទុក្ខជាធម៌មានពិត។

ទុក្ខបរិញ្ញា *ន.* (បា.) កំណត់ដឹងច្បាស់នូវទុក្ខ, កំណត់បានថាជាទុក្ខ, ប្រាជ្ញាដែលកំណត់សម្គាល់យល់ថាជាទុក្ខ។

ទុក្ខប្បទាន *ន.* (បា.) ការលះសេចក្ដីទុក្ខ គឺការរលាស់សេចក្ដីទុក្ខចោលមិនឱ្យទំនេរនៅក្នុងចិត្ត :

- ទុក្ខប្បហានជាហេតុនាំឱ្យមានសេចក្ដីសុខ។

ទុក្ខវេទនា *ន.* (បា.) ដំណើរដឹងនូវសេចក្ដីព្រួយ, លំបាក; ដំណើររងអារម្មណ៍ឬទទួលអារម្មណ៍ជាទុក្ខ, សេចក្ដីសោយទុក្ខ។ ហៅត្រឹមតែវេទនាប៉ុណ្ណោះក៏គង់សំដៅសេចក្ដីថា ទទួលរងអារម្មណ៍ជាទុក្ខដែរ :

- រងវេទនា។

✧ ខ្មែរយើងប្រើជា *កិ.* ក៏មាន :

- វេទនាម្ល៉េះទេ !

- វេទនាណាស់ !

- វេទនាអ្វីម្ល៉េះហ្ន៎ !

ទុក្ខសច្ច *ន.* (បា.) សេចក្តីទុក្ខជាធម៌មានពិត។

ទុក្ខសមុទយ *ន.* (បា.) ហេតុដែលនាំឱ្យកើតទុក (តណ្ហា) ជាឈ្មោះអរិយសច្ចទី២ បានខាងតណ្ហាដែលជាហេតុនាំបណ្តាលឱ្យកើតទុក្ខ ហៅឱ្យពេញថា **ទុក្ខសមុទយអរិយសច្ច** ឬ **ទុក្ខសមុទយសច្ច**។

**អំពី ទូ, ទូរ**

**ទូ** *ន.* ចំនួនវត្ថុដែលដាក់ជាក្រយាតំណាងក្នុងល្បែងភ្នាល់គ្នានីមួយៗ :

- ខ្ញុំឥតវាទូទេដាក់ប៉ុន្មានក៏ដាក់ចុះ។

❖ ប្រដាប់ធ្វើដោយឈើឬដែកមានសណ្ឋានជាហឹប មានទ្វារមានជើងសម្រាប់ដាក់វត្ថុទាំងពួង :

- ទូដែក

- ទូកញ្ចក់។

**ទូរ** *កិ.* ផ្ទៀបគ្នា, សាកគ្នាដើម្បីឱ្យឃើញណាប្រសើរជាង :

- របស់ខ្ញុំថ្លៃតែប្រាំរៀលទៅទូរនឹងរបស់អ្នកដែលថ្លៃដល់ទៅដប់រៀលដូចម្តេចបាន។

## អំពី ឆេ, ឆេរ

**ឆេ** *និ.* ពាក្យបដិសេធជាទំនាស់ផ្ទុយគ្នានឹងពាក្យ **អើ** :

- ទេ
- មិនមែនទេ
- ខ្ញុំមិនដឹងទេ
- ខ្ញុំមិនទៅទេ
- ខ្ញុំមិនព្រមទេ។

**ឆេរ** *គុ.* ដែលទ្រេត, ជ្រេ, ជ្រាល :

- ច្រាំងទេរ
- ព្រះអាទិត្យជ្រេទេរទាបទៅទិសបស្ចិម។

## អំពី ឆោ, ឆោរ

**ឆោ** *ឞ.* ពីរ។ ខ្មែរយើងប្រើតាមទម្លាប់ជាបូរណសំខ្យាថា **ទីពីរ** ក៏បាន :

| | |
|---|---|
| ថ្នាក់ទោ | : ថ្នាក់ទីពីរ |
| យ៉ាងទោ | : យ៉ាងទីពីរ |
| សម្រាប់ទោ | : សម្រាប់ទីពីរ |
| ជាន់ទោ | : ជាន់ទីពីរ (ថ្នាក់លេខពីរ)។ |

**ឆោរ** *គុ.* ឬ *កិ. វិ.* ដែលទ្រេតឈោងទៅខាងនាយឬមកខាងអាយ :

- ស្រវឹងទោរ

- មែកឈើទោរទៅរកផ្លូវ។

ទោរទន់ : ដែលអនុលោមតាម; ទន់ភ្លន់, ទន់ទោរ។

ទន់ទោរ : ដែលអនុលោមតាម; ទន់ភ្លន់, ទោរទន់ :

- មានចិត្តទោរទន់ទៅរក...។

### អំពី **ទុំ, ទំ**

**ទុំ** *៦.* ទីទៃពីខ្ចីពីចាស់ដែលដល់កំណត់ជិតជ្រុះពីមែក, ពីទង :

- ផ្លែឈើទុំ

- ស្លឹកឈើទុំ។

❖ រោគដែលដល់កំណត់នឹងបែកនឹងធ្លាយឬរោគដែលកើតយូរទាំងជ្រុលណាស់ហើយក៏ហៅ **ទុំ** ដែរ :

- បូសទុំ

- ឫសដូងបាតទុំ

- រោគទុំណាស់ទៅហើយគ្មានពេទ្យណាមើលជាទេ។

**ទុំ** *២.* ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ ចាស់ :

ចាស់ទុំ : មនុស្សដែលមានវ័យចាស់ណាស់ហើយ។

**ទំ** *ក.* ឋិតលើទ្រនំ :

- ក្អែកទំលើមែកអម្ពិល

- ព្រាបទំរហង់លើដំបូលសាលា។

❖ *ឝ.* ដែលចាប់ឈឺមិនស្រាកស្រាន្ត :

- ជំងឺទំ

- រោគទំ។

❖ ដែលងំនៅមិនស្រាក :

ទុក្ខទំ : ទុក្ខដែលនៅទំជាប់ជានិច្ច។

❖ អង្គុយ, ចូលកាន់ទីអង្គុយ :

ប្រើទំលែងខ្ពស់ : កុំអាលប្រញាប់អង្គុយលើទីខ្ពស់មុនគេអញ្ជើញ។

**ពាក្យភាព្យ**

| | |
|---|---|
| កុំទុកចិត្តបរទេស | កុំទុកចិត្តអភិនេស្រ្កម៍ |
| កុំទុកចិត្តអភិប្រាយ | ប្រើទំលែងខ្ពស់ |
| រំពឹងឱ្យឆ្ងាយ | ស្តាប់ពាក្យបរិយាយ |

បណ្តាំមេជី។

**អំពី ទ្រព្យ, ទ្រាប់**

**ទ្រព្យ** *ន.* (**សំ. ទ្រវ្យ, វ > ព =** ទ្រព្យ) វត្ថុ, ធនធាន, សម្បត្តិ។ ខ្មែរយើងប្រើពាក្យនេះចំពោះតែវត្ថុមាសប្រាក់ជាដើមដែលមានម្ចាស់ :

- ទ្រព្យធន

- ទ្រព្យសម្រាប់ប្រើប្រាស់

- ទ្រព្យសម្បត្តិ គឺទ្រព្យផ្សេងៗ។

**ទ្រោប់** ***កិ.*** រង, កល់ពីក្រោម, ដាក់ទ្រនាប់ :

- ទ្រាប់ស្លឹកចេកនៅបាតកញ្ជេ។

**អំពី ទ្រុស្ត, ទ្រុះ**

**ទ្រុស្ត** ***កិ.*** (**សំ. ទុស្ត**) ប្រទូស្ត, ធ្វើអាក្រក់ :

- មនុស្សទ្រុស្តមិត្រ។

**ទ្រុះ** ***កិ.*** បៀតបៀន, ព្យាយាមរករឿងបៀតបៀន, ស្អប់, ចងគំនុំ។

❖ ***ន.*** ឬ ***គុ.*** អ្នកបៀតបៀន; ដែលរករឿងបៀតបៀន :

- មនុស្សទ្រុះមិត្ត។

**អំពី ធន, ធន់**

**ធន** ***ន.*** (**បា. សំ.**) ទ្រព្យ, សម្បត្តិ។

**ធន់** ***កិ.*** ទ្រាំ, អត់ធ្មត់; ស៊ូ :

- ធន់ជំងឺ

- ធន់ក្ដៅ

- ធន់ត្រជាក់

- គាត់ប្រើឱ្យធ្វើការធ្ងន់ណាស់ ខ្ញុំធន់មិនបានទេ។

**អំពី ធុំ, ធំ**

**ធុំ** ***កិ.*** ចាប់ក្លិន, ដឹងក្លិនដោយច្រមុះ :

- ធុំក្លិនស្អុយ។

**ធំ** *គុ.* ទីទៃពីតូច គឺមានរូបមានសំណុំសំនួនច្រើនជាងគេ។ ធំធាត់ដែលធំផងធាត់ផង។

❖ (ព.ប្រ.) ដែលកាន់តែដុះដាលកើតកាលវាលគុម្ពតាមលំដាប់កាលឡើង :

- ឥឡូវនេះវាកាន់តែធំធាត់ក្រៃលហើយ។

❖ *ទុ. ស.* ពាក្យសម្រាប់ក្មួយហៅបងប្រុសឬបងស្រីរបស់បិតាឬរបស់មាតាក្នុងទីចំពោះមុខឬក្នុងទីកំបាំងមុខក៏ហៅបាន :

- អញ្ជើញធំអង្គុយ។

❖ ពាក្យទំយើថា **អ៊ំ**; បើក្នុងទីកំបាំងច្រើនហៅថា **ឪពុកធំ** គឺ **ធំប្រុស**, **ម្ដាយធំ** គឺ **ធំស្រី**; អ្នកដទៃមិនមែនជាញាតិដែលមានអាយុច្រើនស្រករនឹង **ឪពុកធំ** ឬ **ម្ដាយធំ** ក៏ហៅ **ធំ** ឬ **អ៊ំ** បានដែរ។

## អំពី នា, នារ

**នា** *អា. និ.* ឰដ៏, ឯ, ត្រង់ :

- នាដងព្រៃ

- នាទ្រូងផ្លូវ

- នាអាកាស។

**នារ** *កិ. វិ.* ឬ *គុ.* ដែលមានអាការៈទេរដោយដំណើររត់ដោយជ្រាលស្រួលមិនចោត :

រត់នារ : រត់បន្ទេរខ្នងបន្តិច។

រត់ខ្នងនារ : រត់បន្ទេរខ្នងបន្តិច។

ដីនារ : ដីដែលមានសណ្ឋានជ្រាលស្រួល។

**អំពី នាក់, អ្នក**

**នាក់ (សំខ្យានុត្រោះ)** ពាក្យសម្រាប់ប្រើដាក់ខាងចុងសំខ្យាដើម្បីឱ្យដឹងចំនួនមនុស្ស :

- ស្រីពីរនាក់
- ប្រុសមួយនាក់
- ក្នុងផ្ទះនេះមានមនុស្សប៉ុន្មាននាក់?

**អ្នក** *ចុ. ស.* (ពាក្យខ្មែរបុរាណព្រេងព្រឹទ្ធសព្វថ្ងៃនេះប្រើជាអញ្ញត្រសព្ទ) ពាក្យប្រើជាជំនួសឈ្មោះបុគ្គល ដែលត្រូវនិយាយទៅរកក្នុងទីចំពោះមុខសម្រាប់ប្រជាពលរដ្ឋហៅគ្នា ដោយសេចក្តីគួរសមមិនចេញឈ្មោះបុគ្គលនោះ (ប្រើបានទាំងបុរសទាំងស្ត្រី) :

- អ្នកអញ្ជើញទៅណា?
- អញ្ជើញអ្នកអង្គុយលេងសិន !
- អ្នកស្រីសុខសប្បាយទេឬ?

❖ សាធារណជនហៅបងថ្លៃក៏ប្រើពាក្យ **អ្នក** ដែរ។ ប្រើពាក្យនាំមុខឈ្មោះបុគ្គលក៏បាន :

- អ្នកនន្ទ
- អ្នកចន្ទ
- អ្នកទេព
- អ្នកសុខ។

☞ ទំនៀមសាធារណជនខ្មែរក្នុងសម័យដើមមុនសម័យបច្ចុប្បន្ននេះ, បើបុរសណាបានបួសជាភិក្ខុហើយសឹកមកត្រូវហៅ **អ្នក** (អ្នកសោម, អ្នកសម); បើបានបួសជាសាមណេរហើយសឹកមកត្រូវហៅជា **ជី** (ជីមាស, ជីមិត្រ); បើមិនបានបួសសោះទេត្រូវហៅ **ចៅ** (ចៅមាស, ចៅប្រាក់); បើនៅជំទង់ឬកំលោះត្រូវហៅ **អា**។ ដោយហេតុនេះទើបមានពាក្យចាស់ទុំខ្លះនិយាយបង្អាប់គ្នាថា បួសឱ្យតែព្រះពុទ្ធឱ្យងារ គឺបួសហើយសឹកមកគ្មានចេះអ្វី បួសយកតែងារ **អ្នក** ឬ **ជី** ប៉ុណ្ណោះ។

❖ *ន.* (ជាអញ្ញត្រសព្ទ) បុគ្គល, ជន, មនុស្ស។ ពាក្យសម្រាប់នាំមុខសព្ទដទៃ, ប្រើបានតាមគួរដល់ការប្រកប, ដូចជាអ្នកការឬអ្នកកាន់ការ :

អ្នកខ្លះ : ជនខ្លះ។

អ្នកជា : ភុជិស្សជន។

អ្នកដឹង : ជនដែលដឹង។

អ្នកអស់ហ្នឹង : ជនអស់ហ្នឹង។

អ្នកខ្លាច : ជនដែលខ្លាច។

| | | |
|---|---|---|
| អ្នកក្លាហាន | : | បុគ្គលក្លាហាន។ |
| អ្នកខ្លៅ | : | បុគ្គលដែលខ្លៅ។ |
| អ្នកក្រ | : | ជនដែលក្រទ្រព្យ។ |
| អ្នកឆ្លើយ | : | ជនដែលឆ្លើយ។ |
| អ្នកស្រែ | : | ជនដែលធ្វើស្រែ។ |
| អ្នកឈ្លប | : | បុគ្គលដែលឈ្លប។ |
| អ្នកជំនួញ | : | ជនដែលធ្វើជំនួញ។ |
| អ្នកចេះ | : | បុគ្គលមានចំណេះ។ |
| អ្នកស៊ើប | : | ជនដែលស៊ើបការណ៍។ |
| អ្នកចម្ការ | : | មនុស្សដែលធ្វើចម្ការ។ |
| អ្នកក្រុង | : | ជនដែលនៅក្នុងក្រុង។ |
| អ្នកទាប | : | បុគ្គលដែលទាបថោក។ |
| អ្នកតូច | : | បុគ្គលដែលតូចជាងគេ។ |
| អ្នកធំ | : | បុគ្គលជាធំ (ឥស្សរជន)។ |
| អ្នកបួស | : | ជនដែលបួស (បព្វជិត)។ |
| អ្នកព្រៃ | : | ជនដែលនៅក្នុងស្រុកព្រៃ។ |
| អ្នករាជការ | : | មនុស្សដែលធ្វើការរាជការ។ |
| អ្នកទេសន៍ | : | បព្វជិតដែលចេះទេសន៍ (ធម្មកថិក)។ |

អ្នកប្រាជ្ញ : បុគ្គលដែលមានប្រាជ្ញាស្គាល់ខុសត្រូវ។

អ្នកផ្សារ : ជនដែលមានលំនៅក្នុងប្រជុំផ្សារ។

អ្នករៀន : ជនដែលកំពុងរៀន, សិស្សរៀន។

អ្នកធ្វើការ : បុគ្គលដែលធ្វើការឬដែលកាន់ការ។

អ្នករក : ជនដែលរក; ជនដែលខំប្រឹងធ្វើការរកស៊ី។

អ្នកភ្លេង : មនុស្សដែលចេះលេងភ្លេងឬដែលលេងភ្លេង។

អ្នកចោទ : បុគ្គលដែលចោទប្រកាន់ឬដែលដាក់ចំណោទ។

អ្នកខ្វះការ : អ្នកចេះត្រួតត្រាមុខការក្នុងក្រសួងឬនាទីរបស់ខ្លួន។

អ្នកគ្រួ : ជនដែលចម្អិនភោជនាហារ (អាវាលិក ឬ អាឡារិក)។

អ្នកស្រុក : ជនដែលនៅក្នុងស្រុក; ប្រជុំជនឬពួកជនក្នុងស្រុកនីមួយៗ។

អ្នកលេង : ជនដែលលេងល្បែង; ជនដែលប្រព្រឹត្តតែខាងការលេង ... (មានច្រើនប្រភេទ)។

អ្នកមុខអ្នកការ: ជនដែលមានមុខមានឈ្មោះនិងជនដែលមានមុខការ ឬដែលជាប្រមុខក្នុងកិច្ចការ។

អ្នកកីឡា : បុគ្គលដែលលេងល្បែងកម្សាន្តចិត្ត។ ជនអ្នកលេងល្បែងមានប្រយោជន៍តាមសម័យនិយម។

## អំពី និង, នឹង, ហ្នឹង

**និង** *ឆ.* សព្ទជាសន្ធានជាទ្វន្ទសម្រាប់និយាយតពាក្យឬតឃ្លារបះពីមួយទៅមួយដែលមានដំណើរសេចក្ដីថា ទាំង, ព្រមទាំង, ផង, នេះផង, នុះផង :

- អ្នកនិងខ្ញុំ
- សុខនិងទុក្ខ
- គោនិងក្របី
- ឱ្យនិងមិនឱ្យ
- ទៅនិងមិនទៅ
- ផ្ទះនេះផ្ទះនុ៎ះនិងផ្ទះឯណោះ
- យកចាននិងផ្តិលមកផង...។

**នឹង** *កិ. វិ.* ពាក្យជាកិរិយានុគ្រោះសម្រាប់និយាយនាំមុខកិរិយាសព្ទប្រាប់អនាគតកាលទៅខាងមុខថា មុខជា, ប្រាកដជា, គង់, គង់តែ :

- ស្អែកនឹងទៅផ្ទះអ្នក
- យើងគង់តែនឹងបានជួបគ្នាទៀតក្នុងថ្ងៃណាមួយពុំខាន។

❖ *វិ.* ឬ *កិ. វិ.* ស្ងៀម, ដើយ, មិនកម្រើក :

អង្គុយនឹងថ្កល់ : អង្គុយនឹងដូចគេថ្កល់។

❖ មិនប្រែប្រួល, មិនឡើងមិនចុះ, នៅដូចដែល :

- ជំងឺនុ៎ះនៅនឹង។

ទឹកនឹង : ទឹកដែលមិនឡើងមិនស្រកឬមិនហូរ។

❖ *អា. និ.* ពាក្យប្រាប់ដំណើរសម្រេចនូវអំពើ, សម្រាប់ប្រើនិយាយនាំមុខនាមសព្ទមានន័យថា ដោយ; ជាមួយ, ដោយសារ; ព្ធដ៏, នៅត្រង់ :

ដួសសម្លនឹងវែក : ដួសសម្លដោយវែក

ដាំបាយនឹងឆ្នាំង : ដាំបាយដោយឆ្នាំង

កាប់ឈើនឹងពូថៅ : កាប់ឈើដោយពូថៅ

ទៅនឹងខ្ញុំ : ទៅជាមួយនឹងខ្ញុំ

នៅនឹងគេ : ដេកដោយសារគេ

ដេកនឹងគេស៊ីនឹងគេ : ស៊ីដោយសារគេ

ព្យួរអាវនឹងដៃកែវ : ព្យួរអាវព្ធដ៏ដៃកែវ

បោះដែកគោលនឹងជញ្ជាំង : បោះដែកគោលនៅត្រង់ជញ្ជាំង...។

❖ *អា. និ.* ជា អកថិតកម្ម គឺកម្មរងបន្ទាប់ពី *អា. និ.* កថិតកម្ម ដែលនិយាយថា **នូវ** គឺ **នូវ** ជាទី១ **នឹង** ជាទី២ ដើម្បីកុំឱ្យថា **នូវ** ទាំង២ដង :

- ពីម្សិលមិញគេបាននិយាយពាក្យនេះនឹងខ្ញុំថា...។ ធៀបនឹងបាលីថា **ហិយ្យោ សោ មំ ឯតនវោច។**

**ហ្នឹង** *ទ. ស.* នុះ :

ហ្នឹងឯង : នុះឯង។

ហ្នឹងហើយ : នុះហើយ។

ដំណើរហ្នឹង : ដំណើរនុះ។

❖ *និ. (ព. សា.)* ដូច្នឹង, អ៊ីចឹង; អើ (អ្នកម្នាក់ប្រាប់ថា) :

- ទៅកុំខានហ្ន៎ះ !, (អ្នកម្នាក់ឆ្លើយតបថា) ហ្នឹង ! ។

ហ្នឹងហើយ ! : អ៊ីចឹងហើយ !។

ហ្នឹងឯង ! : អ៊ីចឹងឯង !។ បើនិយាយមានសំឡេងខ្ពស់ស្រួចខ្លាំង ត្រូវសរសេរដាក់ជើងក្អែក (+) នេះពីលើជា ហ្នឹ៎ងហើ៎យ !; ហ្នឹ៎ងឯ៎ង ! (សម្រាប់សម្ដីសាមញ្ញ)។

**អំពី នូវ, នៅ**

***នូវ*** *និ.* នឹង, ហើយនិង :

- ព្រះរាជវង្សានុវង្សនិងមន្ត្រីតូចធំនូវអស់ប្រជាជនទាំងពួង។

❖ *អា. និ.* ពាក្យប្រាប់ដំណើរសម្រេចអំពើដែលគេត្រូវធ្វើ :

- បុគ្គលធ្វើនូវអំពើល្អដោយកាយវាចាចិត្តនឹងបាននូវផលល្អ។

***នៅ*** *កិ.* ឋិត, ស្ថិត, មាន :

- នៅផ្ទះ

- នៅឯណា?

- នៅក្នុងបន្ទប់។

❖ *កិ. វិ.* ដែលមិនទាន់, ដែលមានទៀត :

- នៅ !

- នៅទេ

- នៅឡើយ

- អស់ហើយឬនៅ?

**អំពី នុះ, នុំះ, នោះ**

**នុះ** *សព្វ.* ពាក្យសម្រាប់និយាយចង្អុលប្រាប់នូវអ្វីៗឬមនុស្សសត្វដែលនៅក្រៅហត្ថបាសមើលទៅឃើញប៉ុន្តែមិនឆ្ងាយពេកទេ :

- បន្ទាត់អ្នកណានុះ?

- សុំអ្នកមេត្តាឱ្យក្រដាសជិតដៃអ្នកនុះមកខ្ញុំ។

**នុំះ** *សព្វ.* ហ្នឹង; ពាក្យសម្រាប់និយាយចង្អុលនាមសព្ទដែលនៅឃ្លាតឆ្ងាយច្រើនពីខ្លួនតែមើលទៅឃើញ, ជាពាក្យមានសូរសំឡេងខ្ពស់ស្រួចជាងពាក្យថា **នុះ** និង **នោះ**, ដូចពាក្យថា :

- អ្នកណានុំះ? អ្នកណាដើរនុំះ?

- នុំះន៏ !

- នុំះហើយ

- នុំះឯង

- នេះផ្ទះរបស់ខ្ញុំ

- នុំះផ្ទះរបស់ប្អូនប្រុសខ្ញុំ

- ឯណោះផ្ទះបងស្រីខ្ញុំ។

**នោះ** *ទ. ស.* ពាក្យសម្រាប់បង្ហាញ, សម្រាប់ចង្អុលអ្វីៗដែលនៅឆ្ងាយតែប្រាកដ; ជាពាក្យមានសូរសំឡេងស្មើនឹង **នុះ** ប៉ុន្តែទាបជាង **នុ៎ះ**, ដូចជា :

- ផ្ទះនោះ
- សេចក្ដីនោះ
- សំបុត្រនោះ
- អ្នកនោះជាដើម។

## អំពី ន័យ, នៃ

**ន័យ** *ន.* (**បា. នយ**) ការណែនាំ; អធិប្បាយ, សេចក្ដីពន្យល់; ហេតុ, ទំនង, លំនាំ, ... :

- គួរអ្នកយល់តាមន័យនេះចុះព្រោះត្រឹមត្រូវគួរយល់បានហើយ។

**នៃ** *អា. និ.* របស់ :

| | |
|---|---|
| សភាពនៃបណ្ឌិត | : សភាពរបស់បណ្ឌិត។ |
| នោះនៃ | : នោះឯង។ |
| ឡើយនៃ | : ឡើយហោង។ |

## អំពី បត់, បទ

**បត់** *កិ.* ត្រលប់តាមទំនង, តាមផ្លូវដដែលមកវិញ, ត្រលប់ប្រសព្វមុខ :

- បត់ស្លឹក
- បត់សំពត់

- បត់ក្រដាស

- បត់តាមផ្លូវដើមមកវិញ

បត់បែន *កិ.* ធ្វើឱ្យបត់ពង់ពេន។

❖ *គុ.* ដែលបត់ពង់ពេន, ដែលវៀចពេនព័ទ្ធជាល្បត់ :

- ផ្លូវបត់បែន។

**បទ** *ន.* (**បា. សំ.**) ឧបាយ; រឿង, ហេតុ; ទី; ការរក្សា; ចំណែក; ជើង; ស្នាមជើង; ផ្លូវ; ទំនង, ដំណើរទំនង, ដើមទង។ ក្លាម, លំនាំនៃសំឡេងដែលសូត្រឬដែលច្រៀង។

- បទសរភញ្ញ។

❖ *និ.* ដ្បិត (ព. បុ.); (ព. កា.) ចង្អុលប្រាប់ពាក្យ **បទ** (ដ្បិត) :

**ពាក្យកាព្យ**

ប្រពន្ធឃើញយាត់ទៅ ប្ដីមិនត្រូវថាកុំអ្នក ឯងខឹងលោវ៉ាយធាក់

ដោយចិត្តធំបទបានស្រា។

**អំពី បាឋ, បាត, បាត្រ, បាន**

**បាឋ** *ន.* (**សំ**) ការរៀន; ការថ្លែងរឿង; រឿងរ៉ាវ; បាលី។

**បាត** *ន.* ប៉ែកខាងក្រោមនៃជម្រៅ :

- បាតដី

- បាតខ្ទះ

- បាតបឹង

- បាតទន្លេ

- បាតឆ្នាំង

- បាតសមុទ្រ

❖ ផ្ទៃដៃឬជើង :

- បាតដៃ

- បាតជើង។

❖ គូទ :

- ឈើបាត

- ឫសដូងបាត។

**បាត្រ** *ន.* (សំ.) ភាជនៈធ្វើដោយដែកឬដោយដីមានរាងជ្រៅក្រឡូមសម្រាប់បព្វជិតក្នុងពុទ្ធសាសនាប្រើការទទួលចង្ហាន់ :

- បាត្រដី

- បាត្រដែក។

ស្លោកបាត្រ : ថង់សម្រាប់ច្រកបាត្រ។

ជើងបាត្រ : ប្រដាប់សម្រាប់ថ្កល់បាត្រ។

គ្របបាត្រ : ប្រដាប់សម្រាប់គ្របពីលើមាត់បាត្រ។

គម្របបាត្រ : ប្រដាប់សម្រាប់គ្របពីលើមាត់បាត្រ។

ឃោគបាត្រ  : ប្រដាប់ចងរឹតភ្ជាប់នឹងស្លោកបាត្រសម្រាប់ស្ពាយ។

☞ នៅជម្ពូទ្វីប (ប្រទេសឥណ្ឌា) ទោះបីគ្រហស្ថសាមញ្ញក៏ប្រើបាត្រដីដាក់បាយបរិភោគដែរ, គេហៅថា ប៉ាត្រ:។ ដោយហេតុនេះបានជាកាលដែលព្រាហ្មណ៍ទាំង៥នាក់នោះ មានឈ្មោះកោណ្ឌញ្ញៈជាដើមដែលហៅថា បញ្ចវគ្គិយ  នាំគ្នាទៅទិញបាត្រនិងចីវរពីផ្សារយកមកអធិដ្ឋានផ្នួសតាមព្រះសិទ្ធត្ថសក្យមុនីគោតម។  ឯចីវរក្នុងសម័យណាក៏មានព្រោះអ្នកបួសខាងលទ្ធិព្រាហ្មណិកគេប្រើកាសាវៈគឺសំពត់ជ្រលក់អម្ចត់ដែរ...។

**បាទ** *ន.* (**បា. សំ.**) ជើង (វ. ស.) :

- ព្រះបាទ។

❖ ឃ្លាសង្កាត់របស់គាថា, របស់កាព្យឃ្លោង:

- បាទទី១
- បាទទី២...។

❖ ឈ្មោះប្រាក់បុរាណតម្លៃ៦០សេន :

- ប្រាក់បាទ។

❖ *ន.* អើ; ពាក្យសម្រាប់បុរសឆ្លើយ :

- ឆ្លើយបាទ
- ទៅកុំខានហ្ន៎!, បាទ!

ខ្ញុំព្រះបាទម្ចាស់ *ទ្រ.* ខ្ញុំ, ខ្លួនខ្ញុំ; ពាក្យសម្រាប់មន្ត្រីសក្តិតូចឬរាស្ត្រប្រជានិយាយទៅរកសេនាបតី, រដ្ឋមន្ត្រី; សរសេរជាខ្ញុំប្របាទម្ចាស់ក៏មាន។

ខ្ញុំព្រះបាទ *ទ្រ.* ខ្ញុំ, ខ្លួនខ្ញុំ; ពាក្យសម្រាប់មន្ត្រីសក្តិធំតែមិនមែនសេនាបតី, មិនមែនជារដ្ឋមន្ត្រី និយាយទៅរកសេនាបតីឬមន្ត្រីសក្តិតូចឬក៏ប្រជារាស្ត្រនិយាយទៅរកមន្ត្រីសក្តិធំក្រៅពីសេនាបតី; សរសេរជា ខ្ញុំប្របាទ ក៏មាន។

ខ្ញុំបាទ *ទ្រ.* ខ្ញុំ, ខ្លួនខ្ញុំ; ពាក្យសម្រាប់មន្ត្រីសក្តិតូចឬរាស្ត្រនិយាយទៅរកមន្ត្រីដែលមានសក្តិធំជាងខ្លួនឬក៏រាស្ត្រ និយាយទៅរករាស្ត្រផងគ្នាដោយសេចក្តីគោរព។

## អំពី បិត, បិទ

**បិត** ***កិ.*** កាន់ទប់ដោយដៃទាំងពីរក្ងួត, ប្រួម, សម្រួចដោយមុខកាំបិតបន្ទោះឬកាំបិតឯទៀតក៏បាន :

- បិតផ្តៅ
- បិតបន្ទោះ
- បិតសម្រួច
- បិតឈើស្រួច។

❖ ចំហុយយកញើសឱ្យស្រក់ចុះក្នុងតម្រងឱ្យកើតបានជាសុរា :

- បិតស្រា។

**បិទ** ***កិ.*** (**បា.**) ខ្ទប់, រាំង, ធ្វើឱ្យជិត :

- បិទផ្លូវ

- បិទទ្វារ។

❖ ដាក់បិទភ្ជាប់, ទឹប :

- បិទមាស។

## អំពី បុស្ស, បុះ

**បុស្ស** *ន.* (**បា. សំ.**) ឈ្មោះខែទី២ (ខាងចន្ទគតិ) :

- ខែបុស្ស។

**បុះ** *កិ.* បុកទល់មុតដល់មានរបួស :

- ដង្គត់បុះបាតជើង។

❖ បុកដោយអ្វីៗដែលស្រួច :

- បុះរណ្ដៅដាំពោត

- បុះនឹងកាំបិទបន្ទោះ។

❖ រុកឱ្យជ្រុះ, ឱ្យធ្លាក់ :

- យកគ្នោលបុះផ្លែឈើ។

❖ **ស៊ី** ពាក្យទ្រគោះមើលងាយថា ស៊ីដូចគេបុះអ្វីៗ :

- ហ៏បុះចុះ !

- ចុះបុះដល់ណាទៀតទៅ !

❖ *គុ.* ចាស់, ដែលគេឈប់ប្រើប្រាស់, ដែលគេបោះបង់លែងត្រូវការ (ចំពោះតែទី, ដី, ស្រែ, ចម្ការ, ភូមិលំនៅ, ...) :

- វត្តបុះ
- ស្រែបុះ
- ចម្ការបុះ។

☞ ចម្ការ, ស្រែ, ភូមិ, វត្ត, ដែលគេបោះបង់ចោលក៏មានស្មៅនឹងផ្លែឈើតូចៗដុះទ្រុបទ្រុលប៉ុន្តែមានសណ្ឋានចាស់ប្រាកដនៅឡើយ; ជួនកាលគេបែរជាត្រូវការដូចកាលពីមុននោះវិញក៏នៅមានឈ្មោះថា...បុះ ដែរ។

### អំពី **បូ, បូព៌**

**បូ** *ន.* សំពត់ពណ៌ចងកាច់ជាស្រទាប់, សណ្ឋានស្រដៀងនឹងផ្កាឈើរីក, ប្រើចងផ្នួងឬកម្រងសក់ឬក៏សំណុំសក់ស្ត្រីជាគ្រឿងធ្វើលម្អតាមបែបសម័យថ្មី :

- ចងបូ
- សក់ចងបូ។

**បូព៌** *ន.* (**សំ. បូវ៌, បូវ៌ា**) ខាងដើម, ខាងមុខ, ខាងកើត :

- ទិសបូព៌។

### អំពី **បួ, បួរ**

**បួ** *ក.* បឹងបួបឹងតូចៗឬបឹងរាយរងគួរយល់ថាបឹងបួ គឺបឹងឈូក។

**ថ្នួរ** *ន.* ថែបធ្វើដោយមែកឈើទាំងស្លឹក សម្រាប់ឱ្យដង្កូវនាងតោងវារព័ទ្ធសំបុក (ហៅតាមទម្លាប់ស្រុក, អ្នកស្រុកខ្លះហៅ ថែបនាង)។

✣ សរីរាវយវៈរបស់សត្វពួកខ្លះ មានគោជាដើមនៅត្រង់ក្រោម-កមានសណ្ឋានយារចុះស្រដៀងនឹងផ្កិតឃ្មុំ :

- ប្ធូរគោ

✣ ឈ្មោះក្បាច់ឬកម្រងមានសណ្ឋានស្រដៀងនឹងប្ធូរដាក់ស៊ែមសំយុងជាលម្អដោយខ្សែក :

- ស៊ែម

- ដាក់ប្ធូរ

- ក្បាច់ប្ធូរ។

**អំពី បន្ទុំ, បន្ទុំ**

**បន្ទុំ** *គិ.* ធ្វើឱ្យទុំ :

- បន្ទុំចេក

- បេះផ្លែទៀបពេញចំណាស់យកមកបន្ទុំ។

បន្ទុំក្រចក : យកស្លឹកក្រពេនដែលបុកឬដែលដំឱ្យល្អិតមករុំត្រង់ក្រចកដៃឱ្យជិតឡើងសម្បុរក្រហមទុំរាប់ថាជាលម្អរបស់អ្នកដែលត្រូវការ។

បន្ទុំបារមី : បំពេញបារមីទាំង១០ឱ្យពេញបរិបូរហាក់ដូចជាផ្លែឈើដែលដល់កំណត់ទុំ ដើម្បីឱ្យសម្រេចពោធិញ្ញាណ។

**បន្ទំ** *កិ.* ធ្វើឱ្យទំ, ចាប់ដាក់ឱ្យទំ, ចាប់ដាក់ឱ្យតោង :

- បន្ទំលខ័

- បន្ទំនាង។

## អំពី **បម្រាស់, បម្រះ**

**បម្រាស់** *ឲ.* ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ **បម្រើ** ថា :

បម្រើបម្រាស់ : ទទួលភារៈតាមកិច្ចដែលគេប្រើប្រាស់ឬទទួលរ៉ាប់រងកិច្ចការខ្ពស់ទាបគ្រប់យ៉ាងតាមពាក្យដែលគេប្រើ :

- ក្មួយឯងជាអ្នកទ័លក្រ, ឯងខំបម្រើបម្រាស់លោកទៅ...។

**បម្រះ** *កិ.* ប្រះចុះប្រះឡើងរឿយៗ :

- ដេកបម្រះខ្លួន

បម្រះនឿ្យល : ប្រះប្រាណននៀលរឿយៗ ប្រើជា បង្រះ ក៏បាន។

## អំពី **ប្រញ្ញប្ត, ប្រញ្ញប្តិ, ប្រញ្ញាប់**

**ប្រញ្ញប្ត** *កិ.* បញ្ញត្ត :

- ព្រះសម្មាសម្ពុទ្ធទ្រង់ប្រញ្ញប្តសិក្ខាបទ។

**ពាក្យភាព្យ**

| | | |
|---|---|---|
| សង្វាតសរសេរ | អស់អញ្ញកុំខ្ជិល | ទើបបានជាគាត់ |
| សង្វាតសូត្ររៀន | ដោយគ្រូប្រញ្ញប្ត | កុំធ្វើលេលាប់ |
| | ដោយចិត្តមាក់ងាយ។ | |

**ប្រញត្តិ** *ន.* បញ្ញត្តិ :

- ពុទ្ធប្រញប្តិ (ពាក្យនេះមិនសូវគេប្រើ)។

**ប្រញាប់** *កិ.* ឬ *កិ. វិ.* ឬក៏ *គុ.* បង្ខំឱ្យញាប់, ធ្វើឱ្យញាប់, ធ្វើឱ្យឆាប់; ដែលញាប់, ដែលឆាប់ :

- ការប្រញាប់
- កុំប្រញាប់ពេក
- ប្រញាប់ឱ្យទាន់ការ
- ដើរប្រញាប់បន្តិចឡើង។

## អំពី ប្រថម, ប្រថំ

**ប្រថម** *គុ.* (សំ.) ដំបូង, មុន, មុនគេ, ទី១, គ្រាបឋម។ ពាក្យនេះច្រើនជាបទសមាសរួមភ្ជាប់ជាមួយនឹងសព្ទដទៃដូចជា :

បឋមជ្ឈាន *ន.* (បា.) ឈានទី១។

បឋមយាម *ន.* (បា.) យាមទី១។

បឋមវ័យ *ន.* (បា. បឋមវយ) វ័យទី១។

បឋមកប្ប *ន.* (បា.) កប្បដំបូង គឺសម័យដែលទើបនឹងកទឹកដីជាដំបូងដែលមានជាប់ជាដរាបមកដល់សព្វថ្ងៃនេះ។

បឋមពុទ្ធវចនៈ *ន.* (បា.បឋមពុទ្ធវចន) ពុទ្ធវចនៈដែលទ្រង់ត្រាស់បន្លឺជាដំបូងបំផុតកាលក្នុងកាលដែលព្រះពុទ្ធទ្រង់ទើបបានត្រាស់ថ្មីៗ។

បឋមសង្គាយនា *ន.* (បា.) ការប្រជុំផ្ទៀងរួបរួមធម្មវិន័យព្រះពុទ្ធសាសនាជាដំបូង បំផុតក្នុងកាល ដែលព្រះសក្យមុនីសម្ពុទ្ធទ្រង់ចូលព្រះនិព្វានទៅបាន៨៩ថ្ងៃ...។

បឋមសម្ពោធិ *ន.* (បា.) ការទើបបានត្រាស់នៃព្រះសព្វញ្ញុពុទ្ធ។ ឈ្មោះគម្ពីរ និយាយអំពីប្រវត្តិ (ពង្សាវតារ) នៃព្រះសម្ពុទ្ធ។

បឋមហេតុ *ន.* (បា.) ហេតុដំបូង គឺហេតុដែលកប្ឈផ្ដើមឡើងជាដំបូង...។

**ប្រចំ** ***កិ.*** បង្ខំដោយប្រញ៉ឹកខ្លាំង, បង្ខំដោយបន្ទាន់ :

- កុំប្រចំពេក។

**អំពី ប្រមាថ, ប្រមាទ**

**ប្រមាថ** *ន.* (សំ.) ការបៀតបៀនគេ, ការញាំញីគេ, ការធ្វើទុក្ខបុកម្នេញឱ្យគេលំបាក; ការមើលងាយគេ។ ប្រើជា ***កិ.*** ក៏បាន :

មនុស្សប្រមាថសត្វ : មនុស្សបៀតបៀនសត្វ។

មនុស្សប្រមាថចាស់ : មនុស្សមើលងាយចាស់។

ប្រមាថកាតទាន : មើលងាយបៀតបៀនឱ្យគេខាតលាភខាតប្រយោជន៍។

**ប្រមាទ** *ន.* (សំ.) ការភ្លេចស្មារតី, ការធ្វេសស្មារតី, សេចក្ដីប្រហែស, ការប្រហែសធ្វេស។

❖ ***កិ.*** ភ្លេច, ធ្វេស, ប្រហែសស្មារតី :

**ពាក្យកាព្យ**

ជនណាប្រមាទ ប្រព្រឹត្តឃ្លៀងឃ្លាត ចាកធម៌សុចរិត
ជននោះទោះបី នៅមានជីវិត តាមដោយការណ៍ពិត
ថាស្លាប់ស្រេចហើយ។

☞ **ត្រូវត្រង់គ្នានឹងព្រះពុទ្ធភាសិតថា** : ជនណាប្រមាទជននោះទុកដូចជាបុគ្គលស្លាប់ គឺស្លាប់ប្រយោជន៍ក្នុងលោកនេះនឹងក្នុងបរលោក។

**អំពី ប្រស់, ប្រោះ**

**ប្រស់** ***កិ.*** បង្ខាំងរក្សាទុកឱ្យរស់នៅបានយូរដើម្បីនឹងពិឃាតក្នុងថ្ងៃខាងមុខ :

- ប្រស់ត្រី
- ប្រស់ក្តាម
- ប្រស់លលក។

ត្រីប្រស់ *គុ.* ត្រីដែលគេប្រស់ទុក។

❖ (ព. ប្រ.) ស្រោចស្រង់, សង្គ្រោះ, ដោះទុក្ខឱ្យមានជីវិតតទៅទៀតក៏ទុកដូចជាប្រស់ឱ្យរស់ដែរ :

- កូនហ្នឹង, កាលពីឆ្នាំទៅមួយនាយវាលង់ទឹកឈ្លក់កខក់រកកល់នឹងស្លាប់ទៅហើយ, បានអ្នកបង់សំណាញ់ពីរនាក់គេស្រង់ទាន់, វាក៏បានរស់នៅរៀងមកដោយសារអ្នកស្រង់នោះគេប្រស់វា។

គ្រូប្រស់ (ព. ប្រ.) គ្រូពេទ្យដែលព្យាបាលអ្នកឈឺធ្ងន់គួរស្លាប់ឱ្យបានជារស់តមកទៀត :

- ពេទ្យជាគ្រូប្រស់មនុស្ស

- ពេទ្យសត្វជាគ្រូប្រស់សត្វ...។

ប្រោសប្រស់ : សង្គ្រោះឱ្យបានរួចផុតចាកគ្រោះថ្នាក់ធ្ងន់ឬឱ្យបានរួចផុតពីទ័លក្រ។

ឥសីប្រស់ : ឥសីសក្តិសិទ្ធិប្រស់មនុស្សឬសត្វដែលស្លាប់ហើយឱ្យរស់ឡើងវិញ (មានតំណាលក្នុងរឿងព្រេងឬក្នុងរឿងប្រតិដ្ឋ), ទេវតាប្រស់។

ទេវតាប្រស់ : ទេវតាសក្តិសិទ្ធិប្រស់មនុស្សឬសត្វដែលស្លាប់ហើយឱ្យរស់ឡើងវិញ (មានតំណាលក្នុងរឿងព្រេងឬក្នុងរឿងប្រតិដ្ឋ), ឥសីប្រស់។

ព្រះពុទ្ធទ្រង់ប្រោសប្រស់ (ព. ប្រ.) ព្រះពុទ្ធទ្រង់ប្រៀនប្រដៅឱ្យមនុស្សលះទិដ្ឋិខុសចេញបាន (ដោយហេតុមនុស្សនោះមានសេចក្តីប្រមាទជ្រុលដែលទុកដូចជាស្លាប់ស្រេចទៅហើយឱ្យដឹងខុសត្រូវឡើង ទុកដូចជារស់ឡើងវិញ; មានរឿងអហឹសបុរសដែលហៅថា **អង្គុលិមាល** ជាឧទាហរណ៍)។

**ប្រោះ** ***កិ.*** រលាស់ទឹករឿយៗដោយផ្ទាត់នឹងម្រាមដៃដោយចម្រៀកស្លឹកចេកជាដើម :

- ប្រោះទឹកអប់

- ប្រោះទឹកក្រអូប។

❖ *ឈ.* ឈ្មោះប្រទាលមួយប្រភេទមានមើមក្រអូប, ស្លឹកក្រអូប, គេច្រើនដាំយកមើមប្រើជាថ្នាំ, ជាគ្រឿងក្រអូបឬសម្រាប់លក់ឱ្យអ្នកដែលត្រូវការ :

- មើមប្រោះ។

## អំពី ប្រូសប់, ប្រូសព្វ

**ប្រូសប់** *គុ.* ថ្នឹក; ប៉ិន, ប៉ិនខាងស្ទង់, លៃ, គ្នេរ :

- មនុស្សប្រសប់។

## ពាក្យទំនឹមបុរាណ

☆ ចេះដប់ពុំស្មើនឹងប្រសប់មួយ : អ្នកចេះតាមរបៀបការរៀនទោះបីមានច្រើននាក់ បើមិនទាន់ថ្នឹកព្រោះមិនទាន់ដែលធ្លាប់កាន់ការនៅឡើយទេក៏ពុំស្មើនឹងអ្នកដែលប្រសប់ឬដែលថ្នឹកម្នាក់។

**ប្រូសព្វ** *ន.* ឬ *កិ* ការធ្វើហោមពិធី; ការបានសម្រេចប្រយោជន៍; ការបានប្រទះ; ការសម្រាលកូន; ជួបប្រទល់មុខគ្នា; រួមចិត្តគំនិតគ្នា; នៅរួមសុខទុក្ខនឹងគ្នា :

- ប្ដីប្រពន្ធគេទាំងពីរនាក់នុះមានអធ្យាស្រ័យល្អណាស់ តាំងពីប្រសព្វគ្នាមកមិនដែលឮឈ្លោះទាល់ទែងខ្វែងគំនិតគ្នាដល់ម្ដងសោះឡើយ។

❖ *គុ.* ឬ *កិ. វិ.* ដែលមានមុខប្រទល់រួមចូលគ្នា :

- ទឹកប្រសព្វគ្នា

- ទន្លេប្រសព្វមុខ។

## អំពី ប្រាស់, ប្រះ

**ប្រាស់** *ម.* ពាក្យសម្រាប់ប្រើផ្សំជាមួយនឹងពាក្យ ប្រើ ថា ប្រើប្រាស់។

**ប្រះ** *កិ.* ផ្អៀងខ្លួនដេក, រំលំខ្លួនឬផ្ដួលខ្លួនដេកប្រះដេក។

គេចចេញ : គេចចៀសចេញ : រត់ប្រះទៅខាងឆ្វេង។

ប្រះដៃប្រះជើង : បោះដៃបោះជើងរឿយៗដោយហេតុរសេះរសោះខ្លាំង ឬដោយអន្ទះអន្ទែងក្នុងខ្លួន។

ប្រះប្រាណ : ផ្ដួលខ្លួនបម្រះនទៀល។

- យំប្រះប្រាណ។

### ពាក្យកាព្យ

យំសោកប្រះប្រាណ ដួលដូចគេច្រាន ព្រោះក្ដីអាល័យ
ជ្រុលជ្រប់ស៊ប់ពេក សង្រេងសង្រៃ ទាំងយប់ទាំងថ្ងៃ
ភ្លេចបាយភ្លេចទឹក។

## អំពី ប្រុស ប្រុះ

**ប្រុស** *ន.* មនុស្សជាតមានភេទផ្សេងទីទៃពីស្រី មានអត្ថន័យថាមនុស្សអ្នកបំពេញបំណងប្រាថ្នារបស់ម្ដាយអាពុក។ តាមទម្លាប់ខ្មែរត្រូវប្រើពាក្យជាគូស្របគ្នាថាប្រុសស្រីឬស្រីប្រុស, បុរសស្ត្រីឬស្ត្រីបុរស, កុំប្រើថាបុរសស្រីឬស្រីបុរសឡើយ។

**ប្រុះ** *គុ.* ឬ *កិ.* *១.* ព្រោងព្រាយ, ដែលភ្លឹចម្រុះគ្នា :

- ភ្លឺប្រុះ
- ពន្លឺប្រុះ។

## ពាក្យភាព្យ

| | | |
|---|---|---|
| សេពគប់ប្រាជ្ញប្រុះ | ប្រាជ្ញនាំឆ្លុះឃើញក្ដីខុសត្រូវ | សេពគប់ជនពាល |
| រែងរាលខុសផ្លូវ | នាំឱ្យអាស្រូវ | បង់កេរ្ដិ៍បង់ឈ្មោះ។ |

## អំពី ប្រួញ, ព្រួញ

**ប្រួញ** *កិ.* រួញ, ថយប្រវែងនៅខ្លី :

- ប្រួញខ្លួន
- ប្រួញសេចក្ដី។

**ព្រួញ** *ន.* សរ, កូនសរ, កាំស្នា, កាំធ្នូ :

- ពត់ព្រួញ
- បំពង់ព្រួញ។

## អំពី ប្រៀប, ព្រាប, ព្រៀប

**ប្រៀប** *កិ.* ផៀប, ប្រដូច។

| | |
|---|---|
| ពាក្យប្រៀប | : ពាក្យប្រដូច។ |
| ប្រៀបផ្ទឹម | : ផ្ទឹមប្រដូចគ្នា។ |
| ប្រៀបធៀប | : ប្រៀបប្រដូច, ប្រដូចដោយផៀបគ្នា។ |
| ប្រៀបប្រាយ | : ដែលផ្សែផ្សំប្រដូចគ្នា : |

- សម្ដីប្រៀបប្រាយ

- និយាយប្រៀបប្រាយ។

ចាញ់ប្រៀបគេ : ចាញ់គេដោយការប្រៀបផ្ទឹមនឹងគេឃើញថា អន់ជាងគេដោយកលឧបាយណាមួយ ចាញ់កលឧបាយគេ។

មានប្រៀបលើគេ : មានតម្លៃលើគេដោយការប្រៀបផ្ទឹម គឺបើប្រៀបផ្ទឹមនឹងគេឃើញថាគ្រាន់បើជាងគេ។

**ព្រាប** *ន.* ឈ្មោះបក្សីមួយប្រភេទរូបរាងស្រដៀងនឹងលលក តែសម្បុរផ្សេងគ្នា, មានច្រើនបែប, ច្រើននៅអាស្រ័យនឹងដំបូលផ្ទះឬដំបូលកុដិ, សាលា, វិហារជាដើម; ព្រាបឃុំ ហៅថា ព្រាបថ្ងូរ ព្រោះវាឃុំឮសូរក្រអួនរនរន្ទាន់ដូចគេថ្ងូរ។

**ព្រៀប** *គុ.* ឬ *កិ. វិ.* ដែលពេញកំពុងរកកល់ហៀរ :

- ពេញព្រៀប

- ទឹកជន់ព្រៀបច្រាំង។

**អំពី ប្រេង, ព្រេង**

**ប្រេង** *ន.* វត្ថុរាវសម្រាប់លាប, វត្ថុរាវសម្រាប់អុជ :

- ប្រេងល្ង

- ប្រេងដូង

- ប្រេងកាត

- ប្រេងសណ្ដែក...។

**ព្រេង** *ន.* បុរាណ, ដែលមានក្នុងកាលពីដើម, ដែលជាយូរអង្វែងហើយ។

គូព្រេង : គូសំណាងដែលបានសាងសូមប្រាថ្នាជាមួយគ្នាពីជាតិមុនមក (ប្រើចំពោះបុរសនិងស្ត្រី)។

ទ្រព្យព្រេង : ទ្រព្យដែលកុសលឱ្យផលតាមអំពើកសាងពីជាតិមុន។

បុរាណព្រេង : បុណ្យដែលបានធ្វើទុកពីជាតិមុន។

ពាក្យព្រេង : ពាក្យដែលគេនិយាយតៗគ្នាតាំងពីព្រេងនាយមក។

ភ័ព្វព្រេង : ភ័ព្វសំណាងដែលជាប់មកពីជាតិមុន។

រឿងព្រេង : រឿងតំណាលពីព្រេងនាយ។

ព្រេងសំណាង : សំណាងពីព្រេងនាយ។

❖ ប្រើជា *ឧ.* ក៏បាន :

រកស៊ីតាមព្រេង : រកស៊ីតាមសំណាង។

រកស៊ីផ្សងព្រេង : ផ្សងសំណាងពីព្រេងនាយ។

ប្រថុយតាមព្រេង : ប្រថុយតាមសំណាង។

## **ពាក្យភាព្យ**

ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់
ទោសគេតូចសោតសល់ មើលទៅយល់ប៉ុននឹងភ្នំ។

## អំពី ផ្សា, ផ្សារ

**ផ្សា** *កិ.* ឬ *គុ.* ឈឺចាប់ពើតរោលរាលឆៀបៗដោយមុខសស្ត្រា, របួស, ដាច់, រលាស់, ប៉ះពាល់, ប្រទះនឹងជាតិជូរ, ប្រៃ, ហឹរ។

ផ្សាខ្លោច : កើតទុក្ខសង្រេងដោយសេចក្ដីស្ដាយស្រណោះ ឬដោយសេចក្ដីអាល័យហាក់ដូចជាឆេះខ្លោចឈឺផ្សាក្នុងចិត្ត, ខ្លោចផ្សា។

ខ្លោចផ្សា : កើតទុក្ខសង្រេងដោយសេចក្ដីស្ដាយស្រណោះ ឬដោយសេចក្ដីអាល័យហាក់ដូចជាឆេះខ្លោចឈឺផ្សាក្នុងចិត្ត, ផ្សាខ្លោច។

❖ **ព. បុ.** (*អា. និ.*) ព្រោះ, ហេតុតែ, ដោយហេតុ, តាមតែ, តាមតែចង់, ព្រោះតែចំណង់ :

- ផ្សានឹងបានចង់តែនឹងបាន។

### ពាក្យកាព្យ

លោកថាស្រីនោះ ចិត្តអាក្រក់ស្មោះ ស្អប់ដំបូន្មាន
ផ្សាដោយសារចិត្ត ទុច្ចរិតសន្ដាន បង្ខិនធនធាន
ចើកអាសមាយា។

❖ *កិ.* ផ្សងតាមកម្ម, ផ្សងព្រេង, ទ្រាំទ្រ, ទ្រាំអត់, កាន់ក្ដីសន្ដោសតាមមានតាមបាន :

- ផ្សាជាអ្នកកម្សត់ទុគ៌ត។

**ផ្សារ** *ន.* ទីប្រជុំលក់ទិញរបស់ផ្សេងៗ គឺប្រជុំផ្ទះឬរានតូចៗដែលគេដាក់ទំនិញលក់ដូរ។ បុរាណប្រើពាក្យនេះថា **អាប័ណ**។

ផ្សារផ្សៀ : ផ្សារស្អុកស្អម្កនិងផ្សាររាយរងចម្រុះគ្នា។

❖ *កិ.* ភ្ជាប់ភ្ជិតដោយទឹកបន្សារ :

- ផ្សារឆ្អាំងស្ពាន់

- ផ្សារឡូតស័ង្កសី។

**អំពី ព, ពរ, ពណ៌, ព័រ**

**ព** *កិ.* លើកដាក់លើចង្កេះកៀកនឹងដៃ ឈរឬដើរ :

- ពកូន។

❖ **ព. ប្រ.** ពផែនដី រក្សាផែនដី គឺគ្រប់គ្រងអាណាចក្រនីមួយៗ។ ទទួលរងធ្វើកិច្ចការរបស់អ្នកដទៃឱ្យនៅលើខ្លួនទាំងអស់; ទទួលរ៉ាប់រងទុក្ខលំបាកជាងគេឬជាជំនួសអ្នកដទៃ :

- ពរវល់

- ពកិច្ចការ

- ពគំនរទុក្ខ

- ពការនឿយហត់។

**ពរ** *ន.* (**បា. សំ. វរ**) គុណជាតដ៏ប្រសើរ គុណជាតឬអ្វីៗដែលគួរប្រាថ្នា, គួរចង់បាន, គួរជ្រើសរើសតាមគាប់ចិត្ត សូមពរ, ទទួលពរ, ឱ្យពរ។

ឱ្យពរសព្ទសាធុការ : បញ្ចេញសូរសព្ទថា សាធុសូមឱ្យ...បានប្រកបតាមបំណង ! ...។

ស្រែកឱ្យពរឱ្យជ័យ : ស្រែកឱ្យពរថាសូមឱ្យ...មានជ័យជម្នះ ! ដូចយ៉ាងស្រែកថា ជយោ ! ឬ ជយោ ! ជយោ ! ជាដើម។

☞ ពាក្យនេះ **បា. សំ.** ប្រើជា *គុ.* ក៏បានប្រែថា "ប្រសើរ; ដែលគួរប្រាថ្នា, គួរចង់បាន, គួរជ្រើសរើសយកតាមគាប់ចិត្ត; ខ្មែរប្រើក្លាយមកជាព្រះក៏មាន, នៅជា វរ ឬ វរ: តាមរូបដើមក៏មាន។

❖ *កិ.* លាបប្លូកព្រលាំងដោយជ័រឱ្យក្រាស់ជិតសាច់ពុំឱ្យជ្រាបទឹកបាន :

- ពរទូក

- បិទពរ។

**ពណ៌** *ន.* (**សំ. វណ៌** "សម្បុរ; ពួក; ថ្នាក់ត្រកូល; ភេទ; ពាក្យសរសើរ; គុណដែលគួរសរសើរ; អក្សរ...") សម្បុរ :

- ពណ៌ស

- ពណ៌ក្រហម...។

❖ ពាក្យនេះខ្មែរយើងប្រើចំពោះតែសម្បុរនៃវត្ថុផ្សេងៗ មានសំពត់ជាដើម, បើចំពោះមនុស្សឬសត្វប្រើពាក្យថា សម្បុរ, គេនិយាយថា :

- គោសម្បុរត្នោត

- មនុស្សសម្បុរស...។

**ព័រ** *ន.* មនុស្សចុងស្រុកមួយពួកកើតនៅក្នុងអាណាខេត្តកម្ពុជរដ្ឋមានភាសាសម្ដីផ្សេងពីខ្មែររាប់បញ្ចូលក្នុងពួក កួយ, រដែ, ស្មៀង :

- ជាតិព័រ
- ពួកព័រ (ក្នុងសម័យឥឡូវរាប់ថាជាខ្មែរដូចគ្នាស្មើគ្នាទាំងអស់)។

**អំពី ពស់, ពោះ**

**ពស់** *ន.* សត្វពួកទីឃជាតិអាសីរពិសផ្សេងៗ :

- ពស់ព្រៃ
- ពស់រនាម
- ពស់ក្រាយ
- ពស់ពព្លាក់
- ពស់ព្រលឹត
- ពស់ទងត្រូវ
- ពស់សង់សឿ
- ពស់វែកដំបូក
- ពស់វែកស្រងៃ
- ពស់សម្លាប់កង្កែប...។

**ពោះ** *ន.* ប៉ែករាងកាយដែលមានក្រពះពោះវៀននៅខាងក្នុង :

- ឈឺពោះ

- ចុកពោះ

- ហើមពោះ

- សៀតពោះ

- ចម្អែតពោះ។

ពោះគោពោះក្របី (ព. ប្រ.) និយាយពីមនុស្សល្មោភស៊ីដែលបរិភោគអាហារញឹកញយពេក បន្តិចស៊ីនេះបន្តិចស៊ីនោះខុសពេលខុសទម្លាប់ឬមនុស្សដែលបរិភោគអាហារច្រើនហួសប្រមាណ។

ពោះគោ : ពោះវៀនឬក្រពះគោ :

- បបរពោះគោ។

ពោះជ្រូក : ពោះវៀនឬក្រពះជ្រូក :

- បបរពោះជ្រូក។

ដុះពោះ : ដែលមានសាច់ពោះក្រាស់ឡើងខ្ពស់ទទុង។ ប៉ែកផ្ទៃខាងក្នុងឬពីខាងក្រោមទល់គ្នានឹងខ្នង, បណ្ដូល :

- ពោះឫស្សី

- ពោះត្រឡាច

- ពោះផាងត្នោត...។

**អំពី ពាន, ពាន្យ, ពាធ**

**ពាន** ***កិ.*** ឬ ***កិ. ១.*** ដាក់ពាសខ្វែងពីលើ :

- ចងពាត

- ដាក់ពាត។

វ៉ាយពាត  : វាយប៉ាតពីលើឬពីខាងឬក៏វាយប៉ាតឱ្យជិតសាច់រំពាត់ទាំងមូលមិនឱ្យសល់ :

- វាយពាតពង្រីកសាច់ដែកឱ្យជិតជាប់គ្នា។

**ពាទ្យ** *ន.* (**សំ.**) គ្រឿងភ្លេងប្រគំ, គ្រឿងតន្ត្រីដេញផ្លុំកូតឬគ្រឿងតន្ត្រីទូទៅគ្រប់យ៉ាង។ ពាក្យនេះខ្មែរយើងប្រើជាបរិវារសព្ទផ្សំនឹងពាក្យថា "**ពិណ**" អានថា ពិណពាទ្យ :

- គ្រឿងភ្លេងដេញផ្លុំមានពិណ គឺចាប៉ីជាដើម។

**ពាធ** *កិ.* (**បា. សំ. ពាធ** "បៀតបៀន, សង្កត់, គ្របសង្កត់; ប្រហារ, សម្លាប់") ប្រើជា *ន.* ក៏បាន :

- ការពាធា

- អំពើពាធា។

## អំពី ពាន់, ព័ន្ធ

**ពាន់** *ឋ. សំ.* ចំនួន១00ដប់ដង (១00 X ១0 = ១ 000)។

**ព័ន្ធ** *ន.* (**បា. ពន្ធ**) ចង, ជាប់, ជំពាក់; ទាក់ឆ្វាក់ព័ន្ធលើគ្នា, ឆ្វាក់ប្រទាក់ជាប់គ្នា :

- ព័ន្ធខ្សែ

- ព័ន្ធសម្ពី

- ព័ន្ធជើង

- ព័ន្ធគំនិត

- ព័ន្ធដំណើរ

- ព័ន្ធសេចក្ដី។

## អំពី ពារ, ពៀរ

**ពារ** *កិ.* (**បា. សំ. វារ** "ឃាត់, រាំង, ទទឹងទាស់") ប៉ះលើ, ប៉ះត្រូវទាំងស្រុង :

- ពាររបង

- ដើរពារគល់ឈើ។

ការពារ : រាំង។

ពារលើគ្រោះកាច : ប្រទះលើគ្រោះកាច។

❖ *ន.* (**បា. សំ. វារ**) ថ្ងៃ :

- ថ្ងៃពុធ។

**ពៀរ** *ន.* (**សំ. វៃរ**) ចំណងចិត្តក្រោធដែលចងដោយព្យាបាទបម្រុងនឹងសងសឹកវិញ, ចំណងចិត្តជាសត្រូវ :

- ចងពៀរ

- ស្រាយពៀរ

- មនុស្សមានពៀរ។

❖ រួចចាកពៀរព្រោះស្រាយពៀរ កាលបើបានចងពៀររួចទៅហើយ ដែលបានរួចរដោះចាកពៀរលែងមានតទៅទៀត ព្រោះស្រាយចំណងពៀរនោះឱ្យជ្រះស្រលះចេញ បើមិនស្រាយចេញទេពៀរក៏ចេះតែមានតៗទៅទៀត។

## ពាក្យកាព្យ

| | |
|---|---|
| ទីឃាវុកុមារ | មានវិចារណ៍ចៀសពៀរបាន |
| ទើបមានសុខក្សេមក្សាន្ត | បានសោយរាជ្យគ្រងរដ្ឋពីរ។ |

## អំពី ពី, ពីរ

**ពី** *និ. ឬ អា. និ.* អំពី; ខាង, ឯ :

- ពីមុខ
- ពីស្ដាំ
- ពីលើ
- ពីឆ្វេង
- រួចពីដៃ
- ពីក្រោម
- មកពីផ្ទះ
- ពីក្រោយ
- ទៅពីព្រឹក
- មកពីណា?

- បានពីណាមក?

- សម្ដីចេញពីមាត់...។

**ពីរ** *ឞ. សំ.* មួយគួបគ្នា គឺមួយនិងមួយ។

**អំពី ពុទ, ពុទ្ធ, ពុធ**

**ពុទ** *ឧ.* ដំណើរបាំងទោសខ្លួន; ដំណើររបិញរបុញ, កិច្ចកលមាយា, ការក្លែងបង្វែងដំណើរឱ្យឃ្លាតចាកសេចក្ដីពិត ដូចយ៉ាងមិនឈឺធ្វើជាឈឺ។

- ពុតត្បុតពុតរបិញរបុញច្រើនបែបយ៉ាង

- ពុតញ្ញាយពុតខ្វូចវៀចវេរចចេះរបិញរបុញ។

**កំណាព្យ**

| | | |
|---|---|---|
| ពុតញ្ញាយមានបី | មួយដូចដំរី | សាហាវឥតបទ |
| អាចផ្សះផ្សាំងបាន | កង្វេរកាន់កត់ | ដាលដេញគោតគត់ |

ប្រាំមួយហត្ថហោង...។

**ពុទ្ធ** *ឧ.* (**បា. សំ.**) លោកអ្នកត្រាស់ដឹងធម៌ដែលកំបាំងដូចយ៉ាងអរិយសច្ចៈ ៤ជាដើមរហូតដល់មគ្គផលនិព្វាន, ឬលោកអ្នកភ្ញាក់រឭកគឺមានសតិសម្បជញ្ញៈសព្វកាល, ឬលោកអ្នករីកពេញទីដូចជាផ្កាឈូកដែលរីកគ្រប់ស្រទាប់ គឺមានព្រះហឫទ័យរីកដោយអំណាចនៃបរិសុទ្ធិ ព្រោះកម្ចាត់កិលេសអស់ហើយ (ព្រះសម្មាសម្ពុទ្ធ) :

- ព្រះពុទ្ធ

- ព្រះពុទ្ធជាបរមគ្រូ

- ព្រះពុទ្ធជាម្ចាស់...។

ពុទ្ធកាល : កាល, កាលដែលព្រះពុទ្ធទ្រង់គង់ព្រះជន្មនៅ; ហៅថា ពោធិកាល។

ពុទ្ធសម័យ : សម័យ, កាលដែលព្រះពុទ្ធទ្រង់គង់ព្រះជន្មនៅ; ហៅថា ពោធិសម័យ។

ពុទ្ធកិច្ច : កិច្ចរបស់ព្រះពុទ្ធ, ការរវល់សម្រាប់ព្រះសព្វញ្ញុពុទ្ធ មានស្តេចយាងចេញបិណ្ឌបាត ពីព្រលឹមនិងទ្រង់ត្រាស់សម្តែងធម៌ប្រទាន ពុទ្ធបរិស័ទជាដើម; ពុទ្ធកិច្ចមានប្រាំយ៉ាង :

១- **បុរេភត្តកិច្ច** : កិច្ចដែលព្រះពុទ្ធត្រូវបំពេញមុនភត្ត គឺតាំង ពីពេលអរុណរះទៅដល់នឹងពេលថ្ងៃត្រង់។

២- **បច្ឆាភត្តកិច្ច** : កិច្ចដែលព្រះពុទ្ធត្រូវបំពេញក្នុងពេលខាង ក្រោយភត្ត គឺតាំងពីថ្ងៃបែរពីត្រង់ទៅទល់នឹងល្ងាច (ព្រលប់)។

៣- **បុរិមយាមកិច្ច** : កិច្ចដែលព្រះពុទ្ធត្រូវបំពេញក្នុងយាមខាង ដើមនៃរាត្រី គឺតាំងពីពេលព្រលប់ទៅទល់នឹងពេលកណ្តាលអធ្រាត្រ។

៤- **មជ្ឈិមយាមកិច្ច** : កិច្ចដែលព្រះពុទ្ធត្រូវបំពេញក្នុងយាមកណ្តាល នៃរាត្រី គឺពេលកណ្តាលអធ្រាត្រ។

៥- **បច្ឆិមយាមកិច្ច** : កិច្ចដែលព្រះពុទ្ធត្រូវបំពេញក្នុងយាមខាងចុងនៃរាត្រី គឺតាំងពីពេលបន្ទាប់អំពីកណ្ដាលអធ្រាត្រទៅទល់នឹងពេលអរុណរះ។

ពុទ្ធគារវតា : សេចក្ដីគោរពចំពោះព្រះពុទ្ធ។

ពុទ្ធគុណ : គុណព្រះពុទ្ធ។

ពុទ្ធង្កូរ : ពន្លកព្រះពុទ្ធ គឺព្រះពោធិសត្វដែលបម្រុងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលជាប្រាកដ។

**ពាក្យគំរូ**

ម្នាលភិក្ខុទាំងឡាយ សុមេធតាបសនេះជាពុទ្ធង្កូរ

នឹងបានត្រាស់ជាព្រះពុទ្ធ មាននាមថាគោតម...។

ពុទ្ធចក្រ : អំណាចព្រះពុទ្ធសាសនាដែលដឹកនាំពុទ្ធសាសនិកជនឱ្យលឿនទៅកាន់សេចក្ដីបរិសុទ្ធហាក់ដូចជារទេះ ដែលមានកង់ជាគ្រឿងវិលនាំទៅ (ជាគូគ្នានឹងអាណាចក្រ)។

ពុទ្ធជិនោរស : ពាក្យសម្រាប់ហៅបុព្វជិតអ្នកប្រតិបត្តិត្រឹមត្រូវតាមពុទ្ធោវាទដោយប្រៀបថា ដូចជាបុត្របង្កើតរបស់ព្រះអង្គ; ហៅថា ពុទ្ធបុត្រក៏បាន។

ពុទ្ធញ្ញាណ : ញាណរបស់ព្រះពុទ្ធ។

ពុទ្ធដីកា : ព្រះបន្ទូលព្រះពុទ្ធ, សំដៅចំពោះពុទ្ធវចនៈ គឺបាលីដែលជាគោលដើមនៃព្រះពុទ្ធសាសនា : អដ្ឋកថា "កែព្រះពុទ្ធដីកា"។

ពុទ្ធដំណើរ : ដំណើរព្រះពុទ្ធ គឺការសម្រេចឥរិយាបថដើររបស់ព្រះពុទ្ធ :

- ទ្រង់ធ្វើពុទ្ធដំណើរទៅ។

ពុទ្ធតម្រាស់ : វាចាដែលព្រះពុទ្ធទ្រង់ត្រាស់ គឺសម្ដីដែលព្រះពុទ្ធទ្រង់ពោលទៅរកបុគ្គលណាមួយ :

- ទ្រង់មានព្រះពុទ្ធតម្រាស់ថា...។

ពុទ្ធទំនាយ : ពាក្យដែលព្រះពុទ្ធទ្រង់ទាយ, ពុទ្ធព្យាករណ៍។

ពុទ្ធធម៌ : ធម៌ដែលធ្វើពោធិសត្វឱ្យបានត្រាស់ជាព្រះពុទ្ធ។

ពុទ្ធន្តរ : កាលឬសម័យជាចន្លោះនៃព្រះពុទ្ធ គឺរវាងពីព្រះពុទ្ធមួយព្រះអង្គទៅមួយព្រះអង្គទៀត :

- មួយពុទ្ធន្តរ។

ពុទ្ធប្បញ្ញត្តិ : បម្រាមព្រះពុទ្ធ គឺវិន័យដែលព្រះពុទ្ធទ្រង់ត្រាស់ហាមមិនឱ្យពួកបព្វជិតប្រព្រឹត្តកន្លង ព្រោះទ្រង់យល់ថាជាទោសដែលអ្នកបួសត្រូវវៀរ។ ព. ផ្ទ. ពុទ្ធានុញ្ញាត។

ពុទ្ធប្បដិមា : រូបតំណាងអង្គព្រះពុទ្ធ (ព្រះពុទ្ធរូប)។

ពុទ្ធបណ្ដាំ : បណ្ដាំព្រះពុទ្ធ, បច្ឆិមពុទ្ធវចនៈ, ពុទ្ធសាសនា :

- ប្រតិបត្តិតាមពុទ្ធបណ្ដាំ។

ពុទ្ធបរិនិព្វាន : ដំណើររលត់ខន្ធនៃព្រះពុទ្ធ (ដំណើរដែលព្រះពុទ្ធទ្រង់អស់ព្រះជន្ម)។

ពុទ្ធបរិស័ទ : បរិស័ទនៃព្រះពុទ្ធ, ពុទ្ធបរិសទ្យ។

ពុទ្ធបរិសទ្យ : បរិសទ្យនៃព្រះពុទ្ធ, ពុទ្ធបរិស័ទ។

ពុទ្ធប្បវត្តិ : សេចក្ដីតំណាលអំពីរឿងរ៉ាវព្រះពុទ្ធ, រឿងព្រះពុទ្ធ (ពង្សាវតារព្រះពុទ្ធ); សរសេរជា ពុទ្ធប្រវត្តិ ក៏បាន។

ពុទ្ធបាត : ព្រះបាទព្រះពុទ្ធ។ ស្នាមចម្លាក់ជារូបព្រះបាទ គឺរូបដានព្រះបាទនៃ ព្រះសម្មាសម្ពុទ្ធ ខ្មែរក៏ហៅថា ពុទ្ធបាទ ឬ ព្រះបាទ ដែរ។

ពុទ្ធបិតា : បិតារបស់ព្រះពុទ្ធ : ព្រះបាទស្រីសុទ្ធោទនៈជាពុទ្ធបិតា។

ពុទ្ធបុត្រ : បុត្រនៃព្រះពុទ្ធ : រាហុលកុមារជាពុទ្ធបុត្រ។

ពុទ្ធបូជា : ការបូជាចំពោះព្រះពុទ្ធ។

ពុទ្ធភាសិត : ពាក្យដែលព្រះពុទ្ធទ្រង់សម្ដែង, ព្រះពុទ្ធដីកា, ...។

ពុទ្ធភូមិ : ទីឬតំណែង, នាទីសម្រាប់ព្រះពុទ្ធ គឺបារមីដែលជាធម៌ធ្វើបុគ្គលឱ្យបានត្រាស់ជាព្រះពុទ្ធ :

- បំពេញពុទ្ធភូមិ។

ពុទ្ធមន្ត : មន្តរបស់ព្រះពុទ្ធ គឺពុទ្ធភាសិត :

- រៀនពុទ្ធមន្ត

- ចម្រើនពុទ្ធមន្ត

- ស្វាធ្យាយពុទ្ធមន្ត។

ពុទ្ធមាតា : មាតានៃព្រះពុទ្ធ :

- ព្រះនាងស្រីមហាមាយាជាពុទ្ធមាតា។

ពុទ្ធមាមកៈ : អ្នករាប់អានស៊ប់ចិត្តថាព្រះពុទ្ធជារបស់អាត្មាអញ គឺអ្នកជឿព្រះពុទ្ធសាសនាស៊ប់; បើស្ត្រីជា ពុទ្ធមាមិកា, គេតែងនិយាយថា ខ្ញុំជា ពុទ្ធមាមកៈ, ភរិយារបស់ខ្ញុំជា ពុទ្ធមាមិកា (ហៅថា ពុទ្ធមាមកជន ក៏បាន)។

ពុទ្ធរស្មី : រស្មីព្រះពុទ្ធ គឺពន្លឺដែលភ្លឺចេញអំពីសរីរកាយនៃព្រះពុទ្ធ។

ពុទ្ធរតនៈ : រតនៈ គឺព្រះពុទ្ធ, កែវ គឺព្រះពុទ្ធ (ព្រះពុទ្ធបានជាហៅថា រតនៈព្រះអង្គបរិសុទ្ធប្រសើរដូចជាកែវឬពេជ្រដែលបរិសុទ្ធឥតមន្ទិល), គេច្រើននិយាយថា ព្រះពុទ្ធរត្ន, ព្រះធម៌រត្ន, ព្រះសង្ឃរត្ន។

ពុទ្ធរូប : រូបព្រះពុទ្ធ, រូបដែលសាងជាតំណាងព្រះពុទ្ធ :

- សាងព្រះពុទ្ធរូប។

ពុទ្ធវចនៈ : ពាក្យព្រះពុទ្ធ, ព្រះត្រៃបិដក :

- រៀនពុទ្ធវចនៈ

- ប្រតិបត្តិតាមពុទ្ធវចនៈ។

ពុទ្ធវង្ស : វង្សព្រះពុទ្ធ។ ពាក្យសម្រាប់ហៅពោធិសត្វដែលបានពុទ្ធទំនាយហើយ :

- ព្រះអង្គជាពុទ្ធង្កុរបណ្ឌូលពុទ្ធវង្ស (ព. ទេ.)។ ឈ្មោះសុត្តន្តបិដក១ គម្ពីរប៉ែកខាងខុទ្ទកនិកាយ សម្តែងរឿងពោធិសត្វដែលបានទំនាយអំពីព្រះសព្វញ្ញុពុទ្ធម្ភៃបួនព្រះអង្គនិងការចែក ព្រះសារីរិកធាតុ ព្រមទាំងគ្រឿងបរិក្ខារនៃ ព្រះសក្យមុនីសម្មាសម្ពុទ្ធ។ ឋានន្តរជាសមណសក្តិទីរាជាគណៈសម្រាប់ត្រីក្នុងកម្ពុជប្រទេស :

- ព្រះពុទ្ធវង្ស។

ពុទ្ធវេនេយ្យសត្វ : សត្វដែលព្រះពុទ្ធគួរទូន្មានបាន, សត្វដែលមានឧបនិស្ស័យបានតែព្រះពុទ្ធទើបប្រៀនប្រដៅបាន។

ពុទ្ធសករាជ : ចំនួនថ្ងៃខែឆ្នាំរាប់តាំងពីក្រោយថ្ងៃដែលព្រះពុទ្ធទ្រង់ចូលបរិនិព្វានទៅបានមួយថ្ងៃរៀងមក។ ព្រះសក្យមុនីគោតម ទ្រង់ចូល បរិនិព្វាននៅថ្ងៃអង្គារ ១៥កើត ខែពិសាខ ឆ្នាំម្សាញ់ រាប់ពីត្រឹមថ្ងៃ១រោច ខែពិសាខនោះមកជាពុទ្ធសករាជ។ ទំនៀមរាប់ពុទ្ធសករាជដោយទៀងទាត់របស់ពួកពុទ្ធសាសនិកជន សម្រាប់ប្រើខាងរបៀបទេស្នាដែលហៅថា បកសករាជរាប់យកចំណែកខាងរនោចខែមួយមុនប៉ះរួមនឹងខ្នើតខែបន្ទាប់នោះ ជា១ខែគឺត្រូវរាប់ពីថ្ងៃ១រោច ខែពិសាខ មកដល់ថ្ងៃ១៥កើត ខែជេស្ឋ ជាមួយខែ...។ ពីថ្ងៃ១រោច ខែចេត្រមកដល់ថ្ងៃ១៥កើត ខែពិសាខជាមួយខែ (ពេញជា១ឆ្នាំ) រាប់យ៉ាងនេះរៀងរាល់ឆ្នាំ, បើរាប់ពីលើមកដល់ត្រឹមណា ត្រូវទុកថ្ងៃខែឆ្នាំនោះជាបច្ចុប្បន្នកាលមិនទាន់រាប់ពេញថា ជាសករាជដែលកន្លងទៅហើយ

ទេ, ដូចជាកាលពីក្នុងថ្ងៃ១៥រោច ខែស្រាពណ៍ ឆ្នាំមមី បន្ទាប់ឆ្នាំពុទ្ធបរិនិព្វានត្រូវរាប់ថា ពុទ្ធសករាជទៅហើយកន្លងបាន១ឆ្នាំ ៣ខែ ១៤ថ្ងៃ (កន្លងទៅហើយបានប៉ុន្មានត្រូវថាតែត្រឹមប៉ុណ្ណោះ); តែបើប្រើខាងការ សរសេរសំបុត្រចុតហ្មាយ, កត់ត្រាចុះក្នុងគម្ពីរក្បួនច្បាប់ទាំងពួងឬនិយាយស្ដីប្រាប់គ្នាតាមធម្មតានោះ ត្រូវរាប់ចេញចំនួនសករាជយកត្រឹមឆ្នាំមមីដែលចូលក្នុងរវាងឆ្នាំគម្រប់២ន៉ុះឯងថា ពុទ្ធសករាជ២ឆ្នាំ ឬ ពុទ្ធសករាជ២; បើប្រើអក្សរសង្ខេបត្រូវសរសេរថា ព. ស. ២។

ពុទ្ធសាសនកាល : កាលឬសម័យដែលមានព្រះពុទ្ធសាសនា គឺការដែលព្រះពុទ្ធទ្រង់ចូលបរិនិព្វានទៅហើយ តែនៅមានធម៌វិន័យជាព្រះពុទ្ធសាសនានិងពួកពុទ្ធសាសនិក :

- កើតទាន់ពុទ្ធសាសនកាល (ហៅថា ពុទ្ធសាសនសម័យ ក៏បាន)។

ពុទ្ធសាសនា : ពាក្យប្រៀនប្រដៅរបស់ ព្រះពុទ្ធ, ពុទ្ធបណ្ដាំ (ពុទ្ធវចនៈ) :

- អ្នកកាន់ពុទ្ធសាសនា

- ប្រតិបត្តិតាមលំអានពុទ្ធសាសនា។

ពុទ្ធសាសនិក : អ្នកកាន់ពុទ្ធសាសនា :

- ពួកពុទ្ធសាសនិក; បើស្ត្រីជា ពុទ្ធសាសនិកា :

- នាងនោះជា ពុទ្ធសាសនិកា; ហៅថា ពុទ្ធសាសនិកជន ក៏បានទាំងបុរសនិងស្ត្រី។

ពុទ្ធអង្គ : អង្គព្រះពុទ្ធ។ ពាក្យសម្រាប់ហៅព្រះពុទ្ធដោយសេចក្ដីគោរព (តាមទម្លាប់ប្រើ) :

- ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្ដែងធម៌...។

ពុទ្ធឱវាទ : ដូចគ្នានឹងពុទ្ធោវាទដែរ។

ពុទ្ធឱស្ឋ : ព្រះឱស្ឋព្រះពុទ្ធ :

- ពាក្យទាំងនេះចេញពីព្រះពុទ្ធឱស្ឋ។

**ពុធ** *ន.* (**បា. សំ.**) អ្នកមានប្រាជ្ញា, អ្នកប្រាជ្ញ។ ឈ្មោះថ្ងៃទី៤ (ក្នុងសប្ដាហ៍) : ថ្ងៃពុធ (ហៅតាមឈ្មោះផ្កាយពុធ) ...។

### អំពី ពុរ, ពុល

**ពុរ** *គុ.* ដែលជោរជ្រាយសាច់ដោយទង្គិច, ប៉ះ, ច្របាច់ :

- ពុរសាច់

- ផ្លែឈើពុរ។

ពុរចិត្ត : ជ្រោកចិត្ត, ខ្វល់ចិត្តខ្លាំង។

ពុរពង : ពងជោរឡើងសាច់ជោរជ្រោក។

**ពុល** *គុ.* ដូចគ្នានឹង ពុរ។

❖ *គុ.* ដែលមានពិសអាចបណ្ដាលឱ្យរង៉ាប់រងើ, ឱ្យក្អួតចង្អោរឬធ្វើទុក្ខខ្លាំងដល់ឈឺស្លាប់ក៏មាន :

- ថ្នាំពុល

- ផ្សិតពុល

- គ្រឿងពុល។

❖ ដែលក្រពុលមុខ, ងងឹតមុខ, វិលមុខ, រង៉ាប់រងើបណ្ដាលពីការបរិភោគផ្អែតពេក, អំពីបរិភោគអាហារមានពិស, អំពីរលាក់ខ្លាំង, អំពីរលកយោកខ្លាំង, អំពីអួអាប់ខ្លាំង :

- ពុល

- ពុលរទេះ

- ពុលផ្សិត

- ពុលបាយ

- ពុលរលក...។

❖ **ព. ប្រ.** ពុលល្បែងដែលវក់នឹងល្បែង, ងងុលឬឈ្លក់នឹងល្បែង។

**អំពី ពេចន៍, ពេជ្រ**

**ពេចន៍** *ន.* (**បា. សំ.**) ពាក្យ, សម្ដី។ ខ្មែរប្រើជា *ក.* សម្រាប់និយាយផ្សំនឹងពាក្យថា :

ពាក្យពេចន៍ : ពាក្យសម្ដីផ្សេងៗ, ពាក្យសម្ដីដែលមានបែបមានយ៉ាងឬសម្ដីថ្វីមាត់, អ្នកចេះពាក្យពេចន៍។

**ពេជ្រ** *ន.* ឈ្មោះត្បូងពិសេសមួយប្រភេទមានសាច់រឹងមានពន្លឺចាំងផ្លុះព្រាតៗ :

- ចិញ្ចៀនពេជ្រ។

## អំពី ព្រឹក, ព្រឹក្ស

**ព្រឹក** *ន.* វេលាចាប់តាំងពីព្រះអាទិត្យបំព្រាងដល់ថ្ងៃពេញពន្លឺធំ; ឬដរាបដល់ថ្ងៃត្រង់ក៏ហៅ **ព្រឹក** បានដែរ :

- ព្រឹកល្ងាច
- ទាំងព្រឹកទាំងល្ងាច។

ព្រឹកស្អែក : វេលាព្រឹកក្នុងថ្ងៃស្អែក។

ព្រឹកព្រាង : វេលាដែលព្រះអាទិត្យរះព្រាងៗ, វេលាបំព្រាង។

**ព្រឹក្ស** *ន.* ឈើ។ ពាក្យនេះខ្មែរច្រើនប្រើតែដែលផ្សំជាបទសមាសរៀងជាខាងចុងនៃនាមសព្ទដែលជាឈ្មោះឈើផ្សេងៗដូចជា :

- ជម្ពូព្រឹក្ស
- ពោធិព្រឹក្ស
- កល្បព្រឹក្ស
- និគ្រោធព្រឹក្ស...។

## អំពី ឥប់, ឥព

**ឥប់** *កិ.* ជួប, ប្រទះ; ប្រសព្វ; ច្រើននិយាយថា **ឥប់ប្រសព្វ** គឺបានគ្នាជាគូស្រករ, នៅរួមសុខរួមទុក្ខ។

ឥប់ឥាន់ : ប្រព្រឹត្តល្មើសដោយភាន់ច្រលំ; ដើរហើរ, ស្មន់អន្ទករ, ភប់ភ័ន្ត ។

ទប់ទ័ត្ត : ប្រព្រឹត្តល្មើសដោយភាន់ច្រលំ; ដើរហើរ, ស្មន់អន្ធករ, ភប់ភាន់។

**ភព** *ន.* សេចក្ដីចម្រើន; ដំណើរកើត; ប្រទេសឬទីសម្រាប់សព្វសត្វកើតស្លាប់, លោក :

- សត្វទាំងឡាយតែងអន្ទោលកើតស្លាប់ក្នុងភពតូចធំ។

នៅក្នុងភព : នៅក្នុងលោក។

ទាំងផែនភព : ទាំងពិភពលោក, ទាំងភពផែន ។

ទាំងភពផែន : ទាំងពិភពលោក, ទាំងផែនភព ។

## អំពី មី, មីរ

**មី** *ន.* (ចិ.) ឈ្មោះម្សៅមួយប្រភេទ សម្បុរលឿង សាច់ស្វិតបន្តិចជាងគុយទាវ។ ឈ្មោះម្ហូបដែលចម្អិនដោយម្សៅមី ព្រមទាំងគ្រឿងសម្រាប់ផ្សំផង :

- ឆាមី
- មីឆា
- មីទឹក
- មីគោក។

❖ *ម្. ស.* សម្ដីក្លាយឃ្លាតមកពី មេ ប្រើជាសម្ដីសាមញ្ញថា :

- មីនេះ
- មីនោះ។

❖ គួរកុំប្រើ **មី**, គួរប្រើ **មេ** វិញ :

- មេនេះ

- មេនោះវិញ។

**មីរ** *គុ.* ច្រើន, តាន់តាប់, កកកុញ, ត្រៀបត្រា; ផេរ :

- ក្បាលមីរ

- មនុស្សមីរ

- មីរដេរដាស។

❖ ប្រើជា *កិ. វិ.* ក៏បាន :

- ឈរមីរ

- កន្ទុំរុយហើរមីរ។

❖ ទូទឹមឈ្លប់, ងងឹតឈ្លប់រកកលភ្លៀង (ប្រើចំពោះតែមេឃ) :

**ពាក្យកាព្យ**

| | | |
|---|---|---|
| មេឃមីរស្រទំ | មៀងមើលទៅភ្នំ | ឃើញសុទ្ធតែអ័ព្ទ |
| ងងឹតបែកផ្សេង | ក្រែងភ្លៀងធ្លាក់ឆាប់ | ខំរត់ប្រញាប់ |
| | ស្រោប់តែភ្លៀងទាន់។ | |

**អំពី ម្លូ, ម្លូរ**

**ម្លូ** *កិ.* ក្នាញ់, ខឹងខ្វល់ក្នុងចិត្ត :

- ម្លូចិត្ត, នាំឱ្យម្លូ។

ម្ហូម៉ៅ : ខឹងក្នាញ់, ក្ដៅក្ដួល, ខឹងដាលវ៉ាល។

- ម្ហូម៉ៅក្ដៅចិត្ត

- ចេះតែម្ហូម៉ៅឥតស្រាក។

ម្ហូហ្មង : ខឹងក្នាញ់ល្អក់ចិត្ត។

**ម្លូរ** *ន.* ស្រូវដែលដុះពីគ្រាប់ជ្រុះក្នុងស្រែតាំងពីខែចម្រូត :

- ស្រូវម្លូរ

- ដកម្លូរស្ទូងត្រពាំង។

❖ **ព. ប្រ.** ស្រែម្លូរបុណ្យសំណាងចាស់ គឺបុណ្យដែលបានកសាងទុកមកពីព្រេងនាយឬចំណេះវិជ្ជាចាស់ គឺចំណេះដែលបានរៀនចេះមកយូរហើយ។

## ពាក្យទំនឹមបុរាណ

☆ រក្សាតែស្រែម្លូរ : រក្សាតែចំណេះវិជ្ជាចាស់កុំឱ្យវិនាស។

☆ សង្ឃឹមតែស្រែម្លូរ : សង្ឃឹមតែបុណ្យសំណាងចាស់ឬសង្ឃឹមតែចំណេះវិជ្ជាចាស់។

## អំពី ម្រ័ក្សណ៍, ម្រាក់

**ម្រ័ក្សណ៍** *ន.* (សំ. **ម្រក្សណ**) ឈ្មោះជ័រកើតពីដើមគ្រើលមានសម្បុរខ្មៅក្លិនហាងឆ្លួលសម្រាប់ប្រើការលាបលន :

- លាបម្រ័ក្សណ៍។

ម្រ័ក្សណ៍ប្លារាំង : ម្រ័ក្សណ៍នាំមកពីប្រទេសបារាំង។

ម្រ័ក្សណ៍រោល : ចំហាយម្រ័ក្សណ៍ដែលរោលស្បែកមនុស្សឱ្យឡើងផេរកន្ទឹស ស្មៀបខ្លាំងបណ្ដាលឱ្យចង់តែរអេះ។

**ម្រាក់** *ន.* (ព. បុ.) ក្ដីស្រី គឺក្ដីស្រីនិងស្រីឬពាក្យប្រុសហៅស្រីជាប្រពន្ធរបស់ក្ដី :

- ម្រាក់អើយ ! សុខសប្បាយទេឬ?

ក្ដីម្រាក់ : ក្ដីប្រុសនិងក្ដីស្រី។

- សុំគ្នាជាក្ដីម្រាក់

- ធ្វើក្ដីម្រាក់នឹងគ្នា។

## អំពី យន់, យន្ត ឬ យន្ត្រ

**យន់** *កិ.* ដាបចុះ, ទន់, ទន់ចុះ, ជ្រុល, ជ្រប់ :

- យន់កម្លាំង

- យន់បបូរមាត់

- យន់ត្របកភ្នែក។

យប់យន់ : យប់ជ្រុល, យប់ជ្រៅ។

**យន្ត** *ន.* (ឆា.) គ្រឿងប្រដាប់ដែលកម្រើកបានដោយកម្លាំងចក្រប្រកបគ្នា :

- យន្តដេរ

- រថយន្ត

- ផ្ទៃរយន្ត

- យន្តហោះ

- កម្លាំងយន្ត។

យន្តសាស្ត្រ : ក្បួនប្រាប់វិធីធ្វើយន្ត។

យន្តវិជ្ជា : ចំណេះធ្វើយន្ត វិជ្ជាធ្វើយន្ត។

យន្តការី : អ្នកធ្វើយន្ត, អ្នកធ្វើការយន្ត។

យន្តកម្ម : ការយន្ត, ការធ្វើយន្ត, រៀនយន្តកម្ម។

យន្តសិក្សា : ការរៀនធ្វើយន្ត, ការរៀនកែគ្រឿងយន្ត។

យន្តសាល : រោងយន្ត, រោងដាក់គ្រឿងយន្ត, រោងធ្វើគ្រឿងយន្ត។

**យន្ត្រ** *ន.* (សំ.) គ្រឿងប្រដាប់ដែលកម្រើកបានដោយកម្លាំងចក្រប្រកបគ្នា។

**អំពី រក្ស, រក់**

**រក្ស** *ន.* (សំ.) រក្សា។ ខ្មែរប្រើពាក្យនេះរួមចូលនឹងសព្ទដទៃឱ្យជាបទសមាស ជាឋានន្តរបស់មន្ត្រីឬជាទីតំណែងណាមួយដូចជា :

គទានុរក្ស : អ្នករក្សាដំបង។

ធនានុរក្ស : ការរក្សាទ្រព្យ, អ្នករក្សាទ្រព្យ។

ធម្មានុរក្ស : ការរក្សាធម៌, អ្នកកាន់តាមធម៌។

គ្រឹហានុរក្ស : ការរក្សាគ្រឹហា, អ្នករក្សាផ្ទះ, អ្នកចាំផ្ទះ។

ធនាធិរក្ស : ការរក្សាទ្រព្យ, អ្នករក្សាទ្រព្យ, ធនានុរក្ស។

វាចានុរក្ស : ការរក្សាសម្តី, អ្នករក្សាសម្តី, អ្នកប្រយ័ត្នសម្តី, ប្រយ័ត្នមាត់។

វិនយានុរក្ស : ការរក្សាវិន័យ, ការកាន់ច្បាប់, អ្នកកាន់ច្បាប់។

សច្ចានុរក្ស : ការកាន់ពាក្យពិត, អ្នកកាន់ពាក្យសច្ចៈ។

សត្យានុរក្ស : ការកាន់ពាក្យពិត, អ្នកកាន់ពាក្យសត្យ។

សិក្ខានុរក្ស : ការកាន់សិក្ខា, អ្នកកាន់សិក្ខា។

ហិរញ្ញានុរក្ស : ការរក្សាប្រាក់, ការទុកដាក់ប្រាក់មាស, អ្នករក្សាប្រាក់, អ្នកទុកដាក់ប្រាក់មាស...។

ហិរណ្យានុរក្ស : ការរក្សាប្រាក់, ការទុកដាក់ប្រាក់មាស, អ្នករក្សាប្រាក់, អ្នកទុកដាក់ប្រាក់មាស...។

**រាក់** *៩.* ទីទៃពីជ្រៅ គឺមានជម្រៅតិច :

- ទឹករាក់

- រណ្ដៅរាក់។

ចិត្តរាក់ : ចិត្តសើៗឆាប់ដោយតាមគេ។

សេចក្ដីរាក់ : សេចក្ដីងាយមិនពិបាកយល់។

គំនិតរាក់ : គំនិតសើៗមុជមិនជ្រៅទៅមិនឆ្ងាយ...។

✣ *៦.* ឈ្មោះឈើតូច ស្លឹកក្រាស់សម្បុរ-សប្រផេះដែលយ៉ាងធំប៉ុនៗបាតដៃមានជ័រស, មានពីរប្រភេទគឺ រាក់ស ផ្កាសម្បុរ-ស, រាក់ក្រហម ផ្កា

សម្បុរស្វាយស្រគាំ; ផ្ការាក់ទាំងពីរយ៉ាងនេះមានក្លិនក្រអូបសាយក្រពុលបន្តិចៗ ជនានុជនរាប់អានច្រើនដោតក្រងជាភ្លួងមាលាឬប្រើក្នុងវេលាថ្វាយបង្គំទទួលបាននូវ។

❖ *ឈ.* ឈ្មោះរោគកើតនៅជើងធ្មេញបណ្ដាលឱ្យហើមសាច់ជើងធ្មេញកើតជាខ្ទុះឈាមស្អុយនាំឱ្យធ្មេញឆាប់រង្គើរង្គោះ :

- ធ្មេញកើតរាក់ឬកើតរាក់ធ្មេញ។

❖ *ឈ.* ឈ្មោះរោគឧច្ចារមគ្គបណ្ដាលឱ្យធូន់បាត (ធូន់ទ្វារធំ) ឈឺស្ទុំក្នុងពោះលីងកន្ទាស់អស់កម្លាំងល្វិតល្វៃ, មានពីរយ៉ាងគឺ រាក់សផ្ដាក់សុទ្ធតែរំអិលគ្មានឈាម, រាក់ក្រហមផ្ដាក់រំអិលមានឈាម :

- កើតរាក់

- កើតរាក់បាត។

**អំពី រង់, រង្គ**

**រង់** *កិ.* (**សំ. រង្ក** "យូរ, យឺតយូរ") បង្អង់ចាំ, ឈប់បង្អង់ :

- រង់ចាំបន្តិចសិន

- រង់មួយស្របក់សិន។

**រង្គ** *ន.* (**បា.** គ្រឿងជ្រលក់, ទឹកជ្រលក់; ថ្នាំពណ៌) ជ័រមានសម្បុរលឿងសម្រាប់ប្រើជាថ្នាំគំនូរឬជាថ្នាំរំងាប់រោគខ្លះក៏បាន។

❖ *ន.* (**បា. សំ.**) ការរីករាយសប្បាយ, ល្បែងរបាំ, ល្ខោន; ចម្បាំង :

- ទៅកាន់ទីរង្គ

- អណ្ដាលរឿនរង្គ។

❖ ប្រើជាបទសមាស, ដូចជា :

រង្គភូមិ : ទីលេងមហោស្រព; សមរភូមិ។

រង្គសាលា : រោងរាំ, រោងល្ខោន, រង្គសាល...។

រង្គសាល : រោងរាំ, រោងល្ខោន, រង្គសាលា...។

**អំពី រដ្ឋ, រឋ្ឋ, រថ**

**រដ្ឋ** *ន.* (**បា.**) ដែន, ប្រទេស; អ្នកនៅក្នុងដែន, រាស្ត្រ, ប្រជាជន។

រដ្ឋកម្ម : ការឬកិច្ចសម្រាប់ដែនឬសម្រាប់ប្រទេស, កិច្ចការរបស់រាស្ត្រ, រដ្ឋការ, រដ្ឋកិច្ច, រដ្ឋក្រឹត្យ ។

រដ្ឋការ : ការឬកិច្ចសម្រាប់ដែនឬសម្រាប់ប្រទេស, កិច្ចការរបស់រាស្ត្រ, រដ្ឋកម្ម, រដ្ឋកិច្ច, រដ្ឋក្រឹត្យ។

រដ្ឋកិច្ច : ការឬកិច្ចសម្រាប់ដែនឬសម្រាប់ប្រទេស, កិច្ចការរបស់រាស្ត្រ, រដ្ឋកម្ម, រដ្ឋការ, រដ្ឋក្រឹត្យ។

រដ្ឋក្រឹត្យ : ការឬកិច្ចសម្រាប់ដែនឬសម្រាប់ប្រទេស, កិច្ចការរបស់រាស្ត្រ, រដ្ឋកម្ម, រដ្ឋការ, រដ្ឋកិច្ច ។

រដ្ឋធម្មនុញ្ញ : ច្បាប់បញ្ញត្តសម្រាប់ប្រទេសនីមួយៗ, ច្បាប់ទុកជាគោលចារឹកក្នុងការគ្រប់គ្រងរដ្ឋនីមួយៗ ដែលសភាបានបញ្ញត្តតែងតាំងឡើង។

រដ្ឋធម្មនុញ្ញ : ច្បាប់បញ្ញត្តសម្រាប់ប្រទេសនីមួយៗ, ច្បាប់ទុកជាគោលចារឹកក្នុងការគ្រប់គ្រងរដ្ឋនីមួយៗ ដែលសភាបានបញ្ញត្តតែងតាំងឡើង, រដ្ឋធម្មនុញ្ញ។

រដ្ឋធានី : ទីក្រុងធំរបស់ប្រទេសនីមួយៗជាទីតាំងនៃរដ្ឋាភិបាល ឬជាទីនៅនៃប្រមុខរបស់ប្រទេស។

រដ្ឋនាយក : រដ្ឋាភិបាលអ្នកត្រួតត្រាដែន, អ្នកគ្រប់គ្រងរក្សាប្រទេស (តំណាងក្សត្រទ្រង់រាជ្យ); ព្រះរាជា, រដ្ឋាធិបតី។

រដ្ឋាធិបតី : រដ្ឋាភិបាលអ្នកត្រួតត្រាដែន, អ្នកគ្រប់គ្រងរក្សាប្រទេស (តំណាងក្សត្រទ្រង់រាជ្យ); ព្រះរាជា, រដ្ឋនាយក។

រដ្ឋបាល : អ្នករក្សាដែនឬប្រទេស; ក្រសួងរាជការកាន់កាប់កិច្ចការក្នុងប្រទេសជាគូគ្នានឹងតុលាការ :

- មន្ត្រីខាងរដ្ឋបាល
- ក្របខណ្ឌខាងរដ្ឋបាល។

រដ្ឋបាលន៍ : ការរក្សាដែន, ការរក្សាប្រទេស។

រដ្ឋបុរស : បុរសអ្នកទំនុកបម្រុងប្រទេស, បុរសអ្នកមានចំណេះចេះរក្សាប្រទេស។

រដ្ឋប្បវេណី : បវេណីសម្រាប់ដែន; ឈ្មោះច្បាប់បញ្ញត្តអំពីដំណើរកិច្ចការនិងសណ្ដាប់ធ្នាប់របៀបរបបផ្សេងៗ តាមបវេណីរបស់ប្រជាជនក្នុង

ប្រទេសដែលនៅក្នុងឱវាទនៃរាជប្បញ្ញត្តិ។

រដ្ឋប្រសាន្តិភាព: ការស្ងប់ដែលមានក្នុងដែន, សេចក្ដីសុខសាន្តរបស់ប្រជាជន, រដ្ឋសន្តិភាព។

រដ្ឋសន្តិភាព : ការស្ងប់ដែលមានក្នុងដែន, សេចក្ដីសុខសាន្តរបស់ប្រជាជន, រដ្ឋប្រសាន្តិភាព។

រដ្ឋប្រសាសន៍ : ការប្រិតប្រៀនប្រជាជនឱ្យស្ថិតនៅក្នុងអំណាចច្បាប់, ការគ្រប់គ្រងប្រទេស។

រដ្ឋប្រសាសននន័យ : ការដឹកនាំឬឧបាយណែនាំឱ្យប្រជាជនស្ថិតនៅក្នុងអំណាចច្បាប់; វិជ្ជាឬបែបបទជាគោលចារឹកសម្រាប់គ្រប់គ្រងប្រទេស, រដ្ឋប្រសាសនោបាយ។

រដ្ឋប្រសាសនោបាយ : ការដឹកនាំឬឧបាយណែនាំឱ្យប្រជាជនស្ថិតនៅក្នុងអំណាចច្បាប់; វិជ្ជាឬបែបបទជាគោលចារឹកសម្រាប់គ្រប់គ្រងប្រទេស , រដ្ឋប្រសាសនន័យ។

រដ្ឋប្រហារ : ការចាប់ចងរំលំអ្នកគ្រប់គ្រងរដ្ឋដែលខ្លួនមិនពេញចិត្ត ដើម្បីកាន់កាប់អំណាចខ្លួនឯង, អំពើរបស់អ្នកកាន់កាប់អំណាចដែលទម្លាយបង់ចោលនូវរបបគ្រប់គ្រងរដ្ឋ ដើម្បីឡើងកាន់កាប់អំណាចខ្លួនឯងវិញដោយខ្លួនមិនពេញចិត្តចំពោះរបៀបគ្រប់គ្រងពីមុន :

- ធ្វើរដ្ឋប្រហារ។

រដ្ឋមណ្ឌល : មណ្ឌលរបស់ដែន, ប្រទេសទាំងមូល។

រដ្ឋមន្ត្រី : មន្ត្រីអ្នកទំនុកបម្រុងស្រុកទេស, មន្ត្រីដែលនាយកអ្នកកាន់អំណាចនីតិប្រតិបត្តិ បានជ្រើសរើសឡើងដើម្បីត្រួតត្រាមុខតំណែងរាជការធំៗរបស់រដ្ឋ :

- រដ្ឋមន្ត្រីក្រសួងធម្មការ

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- ការប្រឹក្សាអំពីការរក្សាឬទំនុកបម្រុងប្រទេស។

រដ្ឋលេខាធិការ : លេខាធិការរបស់រដ្ឋ គឺមន្ត្រីជាន់ខ្ពស់ដែលមានមុខតំណែងជារដ្ឋមន្ត្រី។

រដ្ឋលេខាធិការដ្ឋាន : ទីស្ដីការនៃរដ្ឋលេខាធិការ។

រដ្ឋវាសី : អ្នកនៅក្នុងរដ្ឋ, អ្នកអាស្រ័យនៅក្នុងដែន។

រដ្ឋសភា : ទីប្រជុំប្រឹក្សាការសម្រាប់ប្រទេស; សាលាសម្រាប់ប្រជុំប្រឹក្សាការទំនុកបម្រុងឬគ្រប់គ្រងរក្សាស្រុកទេស។

រដ្ឋសភាធិបតី : អធិបតីនាយកនៃរដ្ឋសភា, រដ្ឋសភានាយក។

រដ្ឋសភានាយក : អធិបតីនាយកនៃរដ្ឋសភា, រដ្ឋសភាធិបតី។

រដ្ឋសីមា : ព្រំប្រទល់របស់រដ្ឋ គឺទីខណ្ឌនៃដែនដីរបស់រដ្ឋដែលនៅជិតជាប់គ្នា។

រដ្ឋាករ : អាកររដ្ឋ; កន្លែងរាជការទទួលបន្ទុកខាងហូតពន្ធដារផ្សេងៗ។

❖ ប្រើជាបទសមាសរៀងខាងចុងសព្ទដទៃក៏បាន, ដូចជា :

មហារដ្ឋ : ដែនធំ, ប្រទេសធំ។

ចុល្លរដ្ឋ : ដែនតូច, ប្រទេសតូច។

កម្ពុជរដ្ឋ : ដែនកម្ពុជា, ប្រទេសខ្មែរ។

សាន្តិរដ្ឋ : ដែនឬប្រទេសដែលមានសេចក្តីសុខសាន្ត...។

**រត្ន** *ន.* (**សំ.**) "វត្ថុឬរបស់ដែលញ៉ាំងចិត្តឱ្យរីករាយ;..." កែវ; ពេជ្រ, ត្បូងគ្រប់ប្រភេទ; សូម្បីមាស, ប្រាក់ក៏ហៅ រតនៈ ដែរឬហៅថា រតនវត្ថុ ក៏បាន; វត្ថុ, ធម្មជាតដ៏ប្រសើរវិសេសឬមនុស្សប្រសើរវិសេស, សត្វវិសេសក៏ហៅ រតនៈ បានដែរ។ សព្ទនេះបើប្រើភ្ជាប់ជាមួយនឹងនាមសព្ទដទៃឱ្យជាបទសមាសរៀងពីខាងដើមក៏បានពីខាងចុងក៏បាន, បើរៀងពីខាងដើមដូចជា :

រតនករ : អ្នកធ្វើរតនៈ, អ្នកជីកត្បូង, អ្នកច្នៃត្បូង; ជាងមាសប្រាក់; ព្រះវេស្សវ័ណ។

រតនករណ្ឌ : ទូឬហឹបដាក់រតនៈ, ដាក់ពេជ្រ, ដាក់ត្បូង។

រតនគព្ភ : ផ្ទៃជាទីកើតរតនៈ គឺសមុទ្រ (ព្រោះសមុទ្រជាទីកើតរតនៈផ្សេងៗ); ព្រះបាទកុវេរៈ គឺព្រះវេស្សវ័ណ (ព្រោះព្រះបាទកុវេរៈពួកមនុស្សពីបុរាណយល់ថាជាទេវតាម្ចាស់រតនៈឬម្ចាស់ទ្រព្យ), រត្នគភ៌។

រត្នគតិ : ផ្ទៃជាទីកើតរតនៈ គឺសមុទ្រ (ព្រោះសមុទ្រជាទីកើតរតនៈ ផ្សេងៗ); ព្រះបាទកុវេរៈ គឺព្រះវេស្សវ័ណ (ព្រោះព្រះបាទកុវេរៈពួកមនុស្សពីបុរាណយល់ថាជាទេវតាម្ចាស់រតនៈឬម្ចាស់ទ្រព្យ), រតនគភ៌។

រតនគញ្ញា : រត្នគភ៌ផែនដី (ព្រោះផែនដីជាទីកើតរតនៈផ្សេងៗ), រត្នគ៌ភា។

រត្នគភ៌ា : រត្នគភ៌ផែនដី (ព្រោះផែនដីជាទីកើតរតនៈផ្សេងៗ), រតនគញ្ញា។

រតនត្រ័យ : រតនៈបីយ៉ាងគឺព្រះពុទ្ធ, ព្រះធម៌,ព្រះសង្ឃហៅថាពុទ្ធរតនៈ, ធម្មរតនៈ, សង្ឃរតនៈឬព្រះពុទ្ធរត្ន, ព្រះធម៌រត្ន, ព្រះសង្ឃរត្នក៏បាន, រត្នត្រ័យ, រត្នត្រៃ។

រត្នត្រ័យ : រតនៈបីយ៉ាងគឺព្រះពុទ្ធ, ព្រះធម៌,ព្រះសង្ឃហៅថាពុទ្ធរតនៈ, ធម្មរតនៈ, សង្ឃរតនៈឬព្រះពុទ្ធរត្ន, ព្រះធម៌រត្ន, ព្រះសង្ឃរត្នក៏បាន, រតនត្រ័យ, រត្នត្រៃ។

រត្នត្រៃ : រតនៈបីយ៉ាងគឺព្រះពុទ្ធ, ព្រះធម៌,ព្រះសង្ឃហៅថាពុទ្ធរតនៈ, ធម្មរតនៈ, សង្ឃរតនៈឬព្រះពុទ្ធរត្ន, ព្រះធម៌រត្ន, ព្រះសង្ឃរត្នក៏បាន, រតនត្រ័យ, រត្នត្រ័យ។

រត្នត្រ័យប្រណាម : ការបង្អោនកាយវាចាចិត្តគោរពព្រះរត្នត្រ័យ។

រតននិធិ : កំណាប់រតនៈ គឺសមុទ្រ; ភ្នំព្រះសុមេរុ។

រតនប្បភា : ពន្លឺរតនៈ; ផែនដី, រត្នប្រភា។

រត្នប្រភា : ពន្លឺរតនៈ; ផែនដី, រតនប្បភា។

រតនពាណិជ : អ្នកលក់ពេជ្រ, អ្នកលក់ត្បូង; អ្នកលក់គ្រឿងប្រដាប់ដែលដាំត្បូង។

រតនពាណិជ្ជ : ការលក់ត្បូង, ជំនួញត្បូង (ប្រើជារតនវណិជ្ជ ឬ រតន-វណិជ្ជា ក៏បាន), រតនពាណិជ្យ។

រតនពាណិជ្យ: ការលក់ត្បូង, ជំនួញត្បូង (ប្រើជា រតនវណិជ្ជ ឬ រតនវណិជ្ជា ក៏បាន), រតនពាណិជ្ជ។

រតនម័យ : ដែលប្រដាប់ដោយរតនៈ, ដែលដាំពេជ្រ, ដែលដាំត្បូង។

រតនមាលា : កម្រងកែវ; ខ្សែខ្លួនឬខ្សែកដាំពេជ្រ។

រតនរង្សី : ស្មើរតនៈ, ពន្លឺពេជ្រ។

រតនរាសី : គំនរកែវ; មហាសមុទ្រ។

រតនវត្ថុ : វត្ថុជារតនៈមានកែវ, ត្បូង, មាស, ប្រាក់, រត្នពស្តុ។

រត្នពស្តុ : វត្ថុជារតនៈមានកែវ, ត្បូង, មាស, ប្រាក់, រតនវត្ថុ ។

រតនវិកតិ : ការរចនាដោយរតនៈ, របស់ដាំត្បូង, រតនវិក័តិ។

រតនវិក័តិ : ការរចនាដោយរតនៈ, របស់ដាំត្បូង, រតនវិកតិ។

រតនវិចិត្រ : ដែលវិចិត្រដោយរតនៈ, ការរចនារំលេចដោយត្បូង, រត្នពិចិត្រ។

រត្នពិចិត្រ : ដែលវិចិត្រដោយរតនៈ, ការរចនារំលេចដោយត្បូង, រតនវិចិត្រ។

រតនសុវណ្ណ : មាសប្រដាប់ដោយត្បូង, មាសដាំពេជ្រ, រត្នសុពណ៌។

រត្នសុពណ៌ : មាសប្រដាប់ដោយត្បូង, មាសដាំពេជ្រ, រតនសុវណ្ណ។

រតនសោភា : លម្អរតនៈ។

រតនាករ : អណ្ដូងរតនៈ, កន្លែងដែលកើតពេជ្រ, ដែលកើតត្បូង; សមុទ្រ (ប្រើជា រត្នាករ ក៏បាន)។

រតនាគារ : អគារនៃរតនៈ, ឃ្លាំងរតន៍; ឃ្លាំងប្រាក់។

រតនាលង្ការ : គ្រឿងអលង្ការប្រដាប់ដោយពេជ្រ, ដោយត្បូង។

រតនាលោក : ពន្លឺរតនៈ, ពន្លឺពេជ្រ, រតនោភាស។

រតនោភាស : ពន្លឺរតនៈ, ពន្លឺពេជ្រ, រតនាលោក។

រតនាវលី : ខ្សែកដាំពេជ្រ...។

គហបតីរតន៍ : គហបតីកែវ, នាយឃ្លាំងកែវ (សម្រាប់ស្ដេចចក្រពត្តិ)។

ចក្ករតន៍ : កង់កែវ (សម្រាប់ស្ដេចចក្រពត្តិ), ចក្ររត្ន។

ចក្ររត្ន : កង់កែវ (សម្រាប់ស្ដេចចក្រពត្តិ), ចក្ករតន៍។

ទ្រទ្រូងរត្ន : ទ្រទ្រូងកែវ គឺសមណសក្តិទីរាជាគណៈសម្រាប់ឯកនៅកម្ពុជរដ្ឋពីក្នុងសម័យបុរាណ។

នារីរត្ន : នាងកែវ, ស្រីថ្លៃ, ស្ត្រីមានលម្អប្រហែលដូចពេជ្រ។

បុរសរត្ន : ប្រុសកែវឬប្រុសថ្លៃ, ប្រុសរត្ន...។

ប្រុសរត្ន : ប្រុសកែវឬប្រុសថ្លៃ, បុរសរត្ន...។

ប្រពាលរត្ន : កែវប្រពាល។

មណីរត្ន : កែវមណី, ពេជ្រមានតម្លៃ។

មហាបុរសរត្ន : មហាបុរសថ្លៃថ្លា,...។

ហត្ថិរតន៍ : ដំរីកែវ (សម្រាប់ព្រះរាជាចក្រពត្តិ), ដំរីរត្ន។

ដំរីរត្ន : ដំរីកែវ (សម្រាប់ព្រះរាជាចក្រពត្តិ), ហត្ថិរតន៍ ។

អស្សរតន៍ : សេះកែវ (សម្រាប់ស្ដេចចក្រពត្តិ), សេះរតន៍។

សេះរតន៍ : សេះកែវ (សម្រាប់ស្ដេចចក្រពត្តិ), អស្សរតន៍។

ឥត្ថីរតន៍ : ស្រ្តីកែវ (សម្រាប់ព្រះរាជាចក្រពត្តិ), ស្រ្តីរត្ន...។

ស្រ្តីរត្ន : ស្រ្តីកែវ (សម្រាប់ព្រះរាជាចក្រពត្តិ), ឥត្ថីរតន៍...។

**រថ ៩.** (**បា. សំ.**) រទេះទឹមសេះ (រទេះសេះ) មានទ្រង់ទ្រាយផ្សេងៗទីទៃពីរទេះគោរទេះក្របី :

- បររថ
- ជិះរថ
- រថបន្ទុក
- រថសេះពីរ
- រថសេះមួយ ។

រថការ : អ្នកធ្វើរថ (ជាងរថ)។

រថកេតុ : ទង់សម្រាប់រថ (ទង់រថ)។

រថចរិយា : ការបង្ហាត់រថ គឺការបង្ហាត់សេះឱ្យថ្មឹកអូសរថឬការហាត់បររថ; ដំណើរទៅដោយរថ, រថចរ្យា។

រថចរ្យា : ការបង្ហាត់រថ គឺការបង្ហាត់សេះឱ្យថ្មឹកអូសរថឬការហាត់បររថ; ដំណើរទៅដោយរថ, រថចរិយា។

រថនាយក : អ្នកត្រួតត្រាលើក្រុមរក្សារថ, អ្នកត្រួតពួករថ។

រថបញ្ជរ : រាងរថ, ផ្ទះរថ, តួរថ។

រថប្បាទ : ជើងរថ, កង់រថ។

រថតណ្ឌ : គ្រឿងរថ, ប្រដាប់រថ។

រថយាត្រា : ដំណើរហែដោយរថ, ក្បួនហែដោយរថ, ក្បួនរថ។

រថយុទ្ធ : ការច្បាំងគ្នាដោយជិះរថ។

រថយោធា : ពួកទាហានរថ, ពួកទាហានរក្សារថ។

រថរេណូ : ឈ្មោះគ្រឿងរាប់យ៉ាងល្អិតមួយប្រភេទប្រមាណ៣៦តជ្ជារី។

រថវាហៈ : អ្នកនាំរថ គឺសេះទឹមអូសរថ, អ្នកបរ (សារថី), រថពាហៈ។

រថពាហៈ : អ្នកនាំរថ គឺសេះទឹមអូសរថ, អ្នកបរ (សារថី), រថវាហៈ។

រថវិជ្ជា : វិជ្ជាធ្វើរថ; ចំណេះបររថ, រថវិទ្យា។

រថវិទ្យា : វិជ្ជាធ្វើរថ; ចំណេះបររថ, រថវិជ្ជា។

រថវិថិ : ផ្លូវរថ, រថបថ។

រថបថ : ផ្លូវរថ, រថវិថី។

រថសាលា : រោងរថ។

រថសាស្ត្រ : ក្បួន, ច្បាប់សម្រាប់រៀនឱ្យចេះបររថឬឱ្យចេះធ្វើការរថ។

រថសិក្សា : ការរៀនធ្វើរថ, ការរៀនបររថ។

រថាង្គ : អង្គឬអវយវៈរបស់រថ, រថាវយវៈ។

រថាវយវៈ : អង្គឬអវយវៈរបស់រថ, រថាង្គ។

រថានិក : ពួករថឬក្បួនរថ (ក្បួនរថយោធាក្នុងសម័យបុរាណ, យ៉ាងតិចត្រឹមរថបី រថមួយៗមានទាហានអ្នកកាន់កាប់បួននាក់ៗរួមជា១២នាក់)។

រថាលង្ការ : គ្រឿងប្រដាប់តាក់តែងរថឱ្យល្អរុងរឿង...។ ទោះយានទំនើបថ្មីដែលមិនទឹមសត្វពាហនៈក៏គួរហៅរថបានដែរ, ហៅដោយសន្មតិតាមលក្ខណៈថា រថត្រីចក្ររថធាក់មានកង់តូចបីខាងក្រោយមួយខាងមុខពីរជិះធាក់ពីក្រោយរុញឱ្យលឿនទៅមុខ។

រថធាក់ : យានស្រាលមានកង់តូចពីរ, មានឈ្នាន់, ច្រវាក់ខ្សែពាន, ...សម្រាប់ជិះឱ្យលឿនទៅដោយកម្លាំងជើងធាក់, រថធាក់ទ្វិចក្រ។

រថធាក់ទ្វិចក្រ: យានស្រាលមានកង់តូចពីរ, មានឈ្នាន់, ច្រវាក់ខ្សែពាន, ...សម្រាប់ជិះឱ្យលឿនទៅដោយកម្លាំងជើងធាក់, រថធាក់។

រថផាក់រុញ : រថផាក់មានកង់តូចបីកង់មួយពីក្រោយកង់ពីរពីមុខ, មានតួរងបន្ទុកពីខាងមុខទ្រង់ទ្រាយ ដូចជាហឹបឬមានសណ្ឋានជាទ្រុង សម្រាប់ដាក់នំប៉ុងលក់ឬដាក់ទំនិញឬក៏វត្ថុអ្វីផ្សេងៗ, មនុស្សម្នាក់ជិះផាក់រុញពីខាងក្រោយឱ្យលឿនទៅ។

☞ រថផាក់មួយបែបទៀតមានកង់បីដែរ, ទ្រង់ទ្រាយតួរងបន្ទុកស្រដៀងនឹងរថអូសតែទាបជាង (សម្រាប់មនុស្សជិះ), មានទូកធ្វើដោយដែកចាប់ភ្ជាប់ពីខាងក្រោយរហូតទៅខាងមុខ, មានកន្លែងសម្រាប់មនុស្សម្នាក់ជិះផាក់រុញពីក្រោយឱ្យលឿនទៅ :

- យានបែបនេះក៏ហៅរថផាក់រុញដែរ។

រថផាក់អូស : រថមានកង់តូចបីពីខាងមុខមួយពីខាងក្រោយពីរ, មានទូកធ្វើដោយដែកចាប់ភ្ជាប់ពីខាងក្រោយរហូតទៅខាងមុខ, មានកន្លែងរងបន្ទុកនៅខាងក្រោយសណ្ឋានស្រដៀងនឹងរថអូសតែទាបជាង, មនុស្សម្នាក់ជិះពីខាងមុខផាក់អូសឱ្យលឿនទៅ។

រថបន្តោង : រថផាក់ទ្វិចក្របន្តោងសណ្តោងតួរងបន្ទុក (ដែលសម្រាប់មនុស្សជិះឬដាក់អីវ៉ាន់ក៏បាន, មនុស្សជិះយ៉ាងច្រើនបានបួននាក់) ពីខាងមុខមានមនុស្សម្នាក់ជិះផាក់ទាញអូសឱ្យលឿនទៅ។

រថភ្លើង : រទេះភ្លើង, អយស្ម័យយាន។

រថយន្ត : រថដ៏វិសេសមួយប្រភេទមានទ្រង់ទ្រាយផ្សេងៗច្រើនបែប, មានចង្កូត, មានគ្រឿងទប់, ...បើកឱ្យលឿនទៅមុខឬឱ្យថយមកក្រោយក៏បានដោយកម្លាំងគ្រឿងយន្ត ប្រកបគ្នាអាស្រ័យចំហាយក្តៅដែលឆេះប្រេងវិសេស, ... (ជាយានមានតម្លៃក្នុងសម័យនេះ) :

- បើករថយន្ត
- ជិះរថយន្ត។

រថអូស : យានស្រាលមានកង់ពីររាងខ្ពស់ស្រោងមានកន្លែងជិះមានដំបូលសំពត់ក្រាស់សម្រាប់ដំឡើងបើក ឬតម្លោះបិទបានពីខាងមុខមានដងពីរឃ្លាតឆ្ងាយពីគ្នាសម្រាប់មនុស្សម្នាក់ ចូលក្នុងចន្លោះចាប់សង្កត់ដោយដៃទាំងពីរទាញអូសរត់លឿនទៅយ៉ាងធូរ។

**អំពី រម្យ, រុំ, រំ**

**រម្យ** ***គុ.*** ដែលគួររីករាយ, ដែលគួរចាប់ចិត្ត; ពីរោះ; ល្អ :

- សំឡេងរម្យ។

❖ ច្រើនប្រើផ្សំជាមួយនឹងពាក្យដទៃ, ដូចជា រម្យដ្ឋាន ឬ រម្យស្ថាន ដូចគ្នានឹង រមណីយដ្ឋាន ដែរ។

- បុរីរម្យ
- រម្យទម។

សមរម្យ : ដែលត្រូវបែបត្រូវយ៉ាង, ដែលមិនទាស់ភ្នែក។

- ស្លៀកពាក់សមរម្យ...។

**រុំ** *កិ.* ក្រសោបព័ទ្ធជិតជុំវិញ, ចងព័ទ្ធ, មូរព័ទ្ធ :

- រុំម្ជូ

- រុំខ្សែ

- រុំរបួស។

❖ រុំបុគ្គល រុំមតករូបដោយសំពត់ស្នប (បើសពឥស្សរជនហៅ **ហោ**, គេនិយាយថា **ហោសព**)។

រុំស៊ុំ : រុំដោយជិតដិត។

ផ្សែងរុំ : ផ្សែងកាន់។

និយាយរុំៗ : និយាយមិនលះមិនស្រលះ។

តែងសេចក្ដីរុំៗ : តែងសេចក្ដីមិនលះមិនក្បោះក្បាយ...។

**រំ** *កិ.* ទទូរគ្របខ្លួនបង្អប់កម្សួលចំហាយផ្សែងដែលស្ងោរថ្នាំឱ្យក្ដៅចេញញើសពីសព៌ាង្គកាយដើម្បីឱ្យស្រាលខ្លួន, ឱ្យស្បើយរោគ; ផ្កុងផ្កាលផ្កាល់ :

- រំឱ្យជារោគឫសដូងរិល។

## អំពី រស, រស់

**រស** *ន.* (**បា. សំ.**) សម្ផស្សប្លែកៗដែលប៉ះពាល់ជិវ្ហាបសាទដឹងថាប្រៃ, ជូរ, ចត់, ល្វីង, ផ្អែមជាដើម :

- រសជូរ

- រសប្រៃ

- រសផ្អែម

- អាហារមានរសឆ្ងាញ់។

❖ បើផ្សំជាបទសមាសរៀងពីខាងដើមសព្ទដទៃអានថា **រៈសៈ** ឬច្រួនកាលអានថា **រស់** ក៏មានខ្លះ, បើរៀងពីខាងចុង អានថា **រស់**; សព្ទនេះមានន័យច្រើនយ៉ាងណាស់, ប្រែតាមរូបធាតុគឺប្រភពដើមថា "វិស័យជាទីត្រេកអររបស់សត្វ" ឬថា "វិស័យដែលសត្វទទួលរ៉ាប់រងដោយការដឹង", ប្រែតាមដំណើរសេចក្ដីនៅមានច្រើនយ៉ាងទៅទៀត គឺប្រែថាការដឹងអារម្មណ៍; សម្ពស្សកាម; តម្រេក; វត្ថុរាវ; ទឹកដម; ធាតុទឹកក្នុងរាងកាយ; ទឹកក្នុងសាច់, ក្នុងដើមឬក្នុងផ្លែ; ទឹកបន្សូរ; កិច្ច; នាទី, មុខការ; សម្បត្តិ; ព្យាយាម; មារយាទ...។

រសក : អ្នកចម្អិនអាហារ, ចុងភៅ (បើស្ត្រីជា រសិកា)។

រសគន្ធ : ក្លិនរស (ពាក្យកាព្យប្រើជា រសគន្ធា ក៏មាន)។

រសជាត : ជាតរបស់រស (រសឆ្ងាញ់ពិសា)។

រសញ្ញា : អណ្ដាត, រសនា។ (រសនា ប្រែថា "ខ្សែក្រវាត់ស្ត្រី; តម្រេក; សេចក្ដីឆ្ងាញ់ពិសា; សំឡេង" ក៏បាន)។

រសនា : អណ្ដាត, រសញ្ញា។ (រសនា ប្រែថា "ខ្សែក្រវាត់ស្ត្រី; តម្រេក; សេចក្ដីឆ្ងាញ់ពិសា; សំឡេង" ក៏បាន)។

រសញ្ញូ : អ្នកប្រាជ្ញខាងអក្សរសាស្ត្រ, ខាងតែងសេចក្ដី, ខាងកាព្យឃ្លោង។

រសតេជឹស : ឈាម, រសតេជះ។

រសតេជះ : ឈាម, រសតេជ័ស។

រសធម៌ : ស្ងួវស្ដាប់ទៅគាប់រសធម៌កុំបីបង់, ធម្មរស។

ធម្មរស : ស្ងួវស្ដាប់ទៅគាប់រសធម៌កុំបីបង់, រសធម៌។

- រសធាតុ

- រសនាថ

- រសរាជ

- រសេន្ទ្របរទ។

រសនាលិះ : សុនខ។

រសនាយក : ព្រះសិវៈ (ព្រះឥស្សូរ)។

រសផល : ផ្លែឈើមានរស; ដើមដូង។

រសតង្គ : ដំណើរខូចរស; ដំណើរទាស់អារម្មណ៍, ទាស់ចិត្ត; សេចក្ដីអផ្សុក។

រសវតី : រោងចម្អិនអាហារ, ផ្ទះបាយ។

រសវិទ : អ្នកចេះរសវិទ្យា; អ្នកស្គាល់បរទ; រសវិទូ, រសាយនវិទ។

រសវិទូ : អ្នកចេះរសវិទ្យា; អ្នកស្គាល់បរទ; រសាយនវិទ, រសវិទ។

រសាយនវិទ : អ្នកចេះរសវិទ្យា; អ្នកស្លបរទ; ពេទ្យ, រសវិទ, រសវិទូ។

រសវិជ្ជា : វិជ្ជាប្រែធាតុឬផ្សំធាតុ គឺចំណេះប្រែឬផ្សំធាតុរ៉ែផ្សេងៗ, ធាតុវិជ្ជា, រសវិទ្យា, រសាយនវិទ្យា...។

រសវិទ្យា : វិជ្ជាប្រែធាតុឬផ្សំធាតុ គឺចំណេះប្រែឬផ្សំធាតុរ៉ែផ្សេងៗ, ធាតុវិជ្ជា, រសវិជ្ជា, រសាយនវិទ្យា...។

ករុណរស : រស (កម្លាំង) នៃសេចក្តីអាណិត, អាសូរ, ករុណារស។

ករុណារស : រស (កម្លាំង) នៃសេចក្តីអាណិត, អាសូរ, ករុណរស។

គន្ធរស : រសក្លិន។

ធម្មរស : រសធម៌។

មធុររស : រសផ្អែម; រសឆ្ងាញ់។

រជតរស : ទឹកប្រាក់។

វីររស : កម្លាំងព្យាយាម, សេចក្តីក្លៀវក្លា។

សុគន្ធរស : ទឹកក្រអូប, ទឹកអប់។

សុវណ្ណរស : ទឹកមាស។

ស្រឹង្គាររស : រសសេចក្តីស្រលាញ់, កម្លាំងស្នេហា។

ហាសនរស : រសសេចក្តីរីករាយ, កម្លាំងសេចក្តីត្រេកត្រអាល។

ឱជារស : ទឹកកម្លាំងកាយ; រសឆ្ងាញ់ពិសា។

ឱសថរស : រសឱសថ, ទឹកថ្នាំរំងាប់រោគ, ឱសធរស...។

ឱសធរស : រសឱសថ, ទឹកថ្នាំរំងាប់រោគ, ឱសថរស...។

**រស់ កិ.** មានជីវិតនៅ, មិនទាន់ស្លាប់ :

- បុគ្គលរស់នៅមួយរយឆ្នាំ បើមានសេចក្ដីប្រមាទលោកហៅថារស់នៅឥតអំពើទុកស្មើដូចស្លាប់ទៅហើយ។

**រស់ គុ.** ដែលមានជីវិតនៅ :

- សត្វរស់។

រស់រាន : មានជីវិតរានខែឆ្នាំតទៅ :

- មានអាយុវែងតទៅ

- សូមឱ្យបានរស់រានមានជីវិតតវែងឆ្ងាយទៅ !

❖ **ព. ប្រ.** ស្ថិតនៅ, តាំងនៅ, មិនទាន់វិនាស, មិនទាន់រលំ :

- ជំនួញនៅរស់។

❖ ***ទេស.*** ទ្រង់ព្រះជន្មនៅ, មានឫគង់ព្រះជន្មនៅ, ទ្រទ្រង់នៅ; មានជីវិតនៅ, មានអាយុនៅ។

☞ **ព. ផ្ទុ.** បរិនិញ្វន; សោយទិព្វជង្គត, សោយទិវង្គត; សោយពិរាល័យ; សុគត; ក្ស័យ, ក្សិណក្ស័យ; ទទួលអសញ្ញកម្ម, ទទួលអសញ្ញភាព; ទទួលមរណភាព; ទទួលអនិច្ចធម្ម; ទទួលអនិច្ចកម្ម; ធ្វើកាលកិរិយា; រលត់, រលត់ខន្ធ, រំលាងខន្ធ, ធ្លាយខន្ធ, ធ្លាយសង្ខារឬបែកធ្លាយសង្ខារ; បាត់បង់, ស្លាប់; ដើរ, ផុត, ផុតរលត់; ដាច់ខ្យល់, អស់ដង្ហើម; ងាប់;

តាយសាក; តាយហោង; ស្នឹង, តាយស្នឹង, តេន (ប្រើតាមថ្នាក់ខ្ពស់, កណ្ដាល, ទាបឬសាមញ្ញ)។

**អំពី រាប, រាពណ៍**

**រាប** *គុ.* ដែលមិនរដិបរដុប, ដែលឥតប៉ោង, ដែលឥតផត, ឥតខ្ពស់ទាប :

- ដីរាប

- ផ្លូវរាប

- ឈើមានសាច់រាប។

❖ ដែលពង្រាបបានបទស៊ាំថ្នឹកហើយ :

- គោរាប

- ក្របីរាប។

រាបទាប : ដែលមានតែទាបឥតខ្ពស់, ឥតរដិបរដុបដែលសុភាពទន់ភ្លន់។

- សម្ដីរាបទាប

- ឫកពារាបទាប។

រាបធេង : រាបសព្វអន្លើ។

រាបស្មើ : ដែលរាបស្មើគ្នាឥតមានប្លែក...។

**រាពណ៍** *ន.* (សំ. **រាវណ**) នាមរបស់ព្រះបាទទសកណ្ឋឬទសមុខ (ក្នុងរឿងរាមាយណៈ) ច្រើនហៅថា :

- ក្រុងរាពណ៍។

រាពណាសូរ : រាពណ៍ជាអសុរ...។

## អំពី រឹត, ឫទ្ធិ

**រឹត** *ក.* ធ្វើឱ្យតឹង, ទាញឱ្យតឹង :

- រឹតខ្សែ
- ចងរឹត
- រឹតចំណង។

❖ ចម្រើនឡើង, ខ្លាំងឡើង :

- ជំងឺរឹត។

រឹតដៃ : ខ្លាំងដៃ, ខ្លាំងឡើង :

- កាន់តែរឹតដៃខូចជាងពីដើម។

រឹតរូត : រឹតព័ទ្ធរួតរូប :

- ចងរឹតរួត...។

**រឹត** *ន.* ស្លឹកទ្រាំងដែលកាត់ហាលថ្ងៃស្ងួត ហើយសម្រាប់ប្រើការផ្សេងៗ មានចារសាស្ត្រា, ត្បាញការុងជាដើម។

- ដួនស្លឹករឹត
- ការុងស្លឹករឹត
- សាស្ត្រាស្លឹករឹត។

❖ *និ.* កាន់តែ, ចេះតែ :

- រឹតល្អ
- រឹតខូច
- រឹតតែខ្លាំងឡើង។

រឹតតែរឹត : កាន់តែរឹតឡើង។

**ឫទ្ធិ** *ន.* (សំ.) សេចក្តីសម្រេច, ដំណើរកើតការ; អំណាច; សេចក្តីអស្ចារ្យ, សម្បើម; សេចក្តីក្ដៀវក្លា, សេចក្តីរុងរឿង; សេចក្តីចម្រើន, សេចក្តីល្វតលាស់, ការដុះដាល; សេចក្តីរឹងប៉ឹង, សេចក្តីមាំមួន :

- មានឫទ្ធិ
- ប្រលងឫទ្ធិ
- ប្រើឫទ្ធិអំណាច។

❖ បើរៀងពីខាងដើមសព្ទដទៃជា **បទសមាស** ឬ **បទឥឡិត** :

ឫទ្ធិពល : កម្លាំងរបស់ឫទ្ធិ, ឥទ្ធិពល។

ឥទ្ធិពល : ឫទ្ធិពល, កម្លាំងរបស់ឫទ្ធិ។

ឫទ្ធិម័ត : ដែលមានឫទ្ធិ; អ្នកមានឫទ្ធិ។

ឫទ្ធិវង្គ : ចម្បាំងមានឫទ្ធិ, ចម្បាំងយ៉ាងសម្បើម។

ឫទ្ធិរុទ្រ : ដែលសម្បើម, រឹងប៉ឹងដោយឫទ្ធិ; អ្នកមានឫទ្ធិខ្លាំងពូកែ។

ឫទ្ធិលាភ : ការបានឫទ្ធិ, ការសម្រេចឫទ្ធិ...។

❖ បើរៀងពីខាងចុងសព្ទដទៃក៏បាន :

កាយឫទ្ធិ : ឫទ្ធិរបស់កាយ។

ធ្យានឫទ្ធិ : ឫទ្ធិនៃធ្យាន។

ឈានឫទ្ធិ : ឫទ្ធិរបស់ឈាន។

បុណ្យឫទ្ធិ : ឫទ្ធិរបស់បុណ្យ, បុញ្ញឫទ្ធិ។

បុញ្ញឫទ្ធិ : ឫទ្ធិរបស់បុណ្យ, បុណ្យឫទ្ធិ។

រណឫទ្ធិ : ឫទ្ធិរបស់ចម្បាំង។

រាជឫទ្ធិ : ឫទ្ធិរបស់ព្រះរាជា។

សេនាឫទ្ធិ : ឫទ្ធិរបស់សេនា។

អស្វឫទ្ធិ : ឫទ្ធិរបស់សេះ, អស្សឫទ្ធិ។

អស្សឫទ្ធិ : ឫទ្ធិរបស់សេះ, អស្វឫទ្ធិ។

## អំពី របស់, រលោះ

**របស់** *ន.* វត្ថុ, ទ្រព្យ, អីវ៉ាន់។ ពាក្យសម្រាប់និយាយជាជំនួសនាមនាមដោយមិនបាច់ចេញឈ្មោះឬសម្រាប់ហៅសរពើអ្វីៗដែលមាននៅទីចំពោះមុខ :

- របស់ទំនើប
- របស់ប្រសើរ
- របស់បុរាណ
- របស់ថោកទាប។

របស់ទ្រព្យ : ទ្រព្យធនទាំងពួង, ទ្រព្យរបស់។

ទ្រព្យរបស់ : ទ្រព្យធនទាំងពួង, របស់ទ្រព្យ។

- នេះរបស់អ្នកណា? នេះជារបស់ខ្ញុំ។

របស់របរ : អម្រស់អម្រ...។

❖ ពាក្យសម្រាប់ប្រើជាវិកតិកត្តាឬវិកតិកម្មជាមួយនឹងពាក្យជា, ដូចជា :

- របស់របរ

- របស់ទ្រព្យ

- ទ្រព្យរបស់

- ពេជ្រជារបស់មានតម្លៃ។

❖ ***អា. និ.*** នៃ :

ផ្ទះរបស់ខ្ញុំ : ផ្ទះនៃខ្ញុំ (ផ្ទះខ្ញុំ)...។

**របោះ** ឬ **ល្បោះ** ***គុ.*** ឬ ***កិ. វិ.*** ដែលរង្វើលៗឃ្លាតៗដាច់ៗពីគ្នា : ព្រៃរបោះៗ :

- កូនឈើដុះរបោះៗ។

❖ ***ន.*** ចន្លោះរង្វើលៗឃ្លាតៗពីគ្នា :

- របោះព្រៃ។

## អំពី **ប្ញក**, **ឫក្ស**

**ឫក** ***ន.*** មារយាទ; កិរិយា, អាការកិរិយា, បែបបទ, សណ្ដាប់ធ្នាប់ (របស់រូបកាយ) :

- ឫកល្អ

- ឫកថ្លៃ

- ធ្វើឫក

- វាយឫក

- ឫកចោក

- ឫកសុភាព

- ឫកអាក្រក់

- ឫកពាសមរម្យ។

**ឫក្ស** *ន.* (**សំ**) ផ្កាយក្រពើ; ផ្កាយនព្វគ្រោះ; វេលាមានជោគ, មានមង្គល, មានសួស្តីដែលកំណត់តាមហោរាសាស្ត្រ :

- ថ្ងៃមានឫក្ស

- ហោរសង្កេតរកឫក្ស។

**អំពី លប់, ល្មប**

**លប់** *ន.* ប្រដាប់មានសណ្ឋានជាទ្រុង រុំស្នឹកឈើស្រស់មានប៉ែកដាក់បក្សីធ្លាក់មានប៉ែកសំណាញ់ មានគន្លឹះថ្ពោះបានសម្រាប់ឱ្យជាប់បក្សីព្រៃដែលដេញធ្លាក់ :

- លប់ទទា

- លប់លលក

- លលកព្រៃជាប់លប់។

**លុប** *កិ.* ធ្វើឱ្យបាត់ស្នាម, ឱ្យបាត់គំនូស, ឱ្យបាត់លំអាន, ឱ្យបាត់រូប, ឱ្យបាត់ឈ្មោះ; ធ្វើឱ្យវិនាស, ឱ្យសូន្យ; បំបាត់មិនឱ្យមាន :

- លុបដាន

- លុបអក្សរ

- លុបឈ្មោះ។

❖ បំពេញក្រហូង, ជម្រៅ, រណ្ដៅឱ្យបាត់ :

- លុបអណ្ដូង

- លុបរណ្ដៅ។

❖ លាង, ជម្រះស្រលាបដោយទឹក :

- លុបមុខ

- លុបខ្លួន។

❖ គ្របលើ, លើសជាង :

- សម្ដីលុបលើ

- សំឡេងឮលុបគេទាំងអស់។

លុបគុណ : បំបាត់គុណ គឺបំបាត់មិនឱ្យលេចឮថា គេមានគុណចំពោះខ្លួន។

❖ *គុ.* ដែលបំបាត់គុណគេ :

- សម្ដីលុបគុណ

- មនុស្សលុបគុណគេ។

លុបថ្លុក : បំបាត់ដំណើរដើមឬសម្ដីដើមលេចឮតទៅទៀត :

- សម្ដីលុបថ្លុក

- និយាយលុបថ្លុក។

លុបមាត្រ : លើធ្ងន់លុបមាត្រ, ខ្លាំងលុបមាត្រ, ហួសមាត្រ, លើសមាត្រ។

លើសមាត្រ : លើធ្ងន់លុបមាត្រ, ខ្លាំងលុបមាត្រ, លុបមាត្រ, ហួសមាត្រ។

ហួសមាត្រ : លើធ្ងន់លុបមាត្រ, ខ្លាំងលុបមាត្រ, លុបមាត្រ, លើសមាត្រ។

លុបលាង : បំបាត់ឱ្យសូន្យឈឹងឬបំបិទបំបាំងមិនឱ្យលេចឮ, កាយយកកប់លុបលាង។

កាយយកកប់លុបលាង : បំបាត់ឱ្យសូន្យឈឹងឬបំបិទបំបាំងមិនឱ្យលេចឮ, លុបលាង។

### អំពី **លាក់, ល័ក្ខ (ល័ខ), លក្ខណ៍ ឬ លក្ស្មណ៍**

**លាក់** *កិ.* ធ្វើឱ្យមានគន្លាក់ :

- លាក់ឈើ

- បិទបាំង។

❖ បំបាំងឬទុកមិនឱ្យគេឃើញមិនឱ្យគេដឹង :

- លាក់របស់

- លាក់ខ្លួន

- លាក់ពុត។

លាក់កំណ្ឋច : លាក់គំនិតដែលក្អួចកាន់ទុកឬលាក់ល្បិច, លាក់ចំណេះ។

❖ លាក់បាំងអ្វី *និ.* ពាក្យនិបាតសម្រាប់និយាយផ្ដើមប្រាប់សេចក្ដីទៀងត្រង់មិនលាក់មិនបំបាំង :

- លាក់បាំងអ្វីខ្ញុំសព្វថ្ងៃនេះទ័លក្រណាស់បានជាមករកខ្ចីប្រាក់អ្នក។

លាក់ល្បៀប : លាក់ក្បិតក្បៀតទុកសំចៃឬលាក់ទុកនៅកៀនកោះ, លាក់លៀម។

លាក់ល្បៀម : លាក់ក្បិតក្បៀតទុកសំចៃឬលាក់ទុកនៅកៀនកោះ, លាក់លៀប។

លាក់សុំ : លាក់ទុកត្រដក់ត្រសុំ...។

**ល័ក្ត (ល័ខ)** *ន.* ជ័រខះរឹងកើតអំពីសត្វល្អិតពួកមួយមានសម្បុរក្រហមសម្រាប់ប្រើការជ្រលក់ស្បូត្រ, អំបោះជាដើម :

- ល័ក្តស្រម៉។

ល័ក្តជុំកន្លង់ : ស្រម៉ល័ក្តដែលដុះព័ទ្ធស្រោបរុំជុំវិញមែកឈើ។

កាកល័ក្ត : កាករបស់ល័ក្តស្រម៉ដែលស្ងោររំងាស់អស់ជាតិហើយ, សម្រាប់ប្រើការបិទឬភ្ជួរភ្ជាប់អ្វីផ្សេងៗ, អាចម៍ល័ក្ត។

អាចម៍ល័ក្ត : កាករបស់ល័ក្តស្រម៉ដែលស្ងោររំងាស់អស់ជាតិហើយ, សម្រាប់ប្រើការបិទឬភ្ជួរភ្ជាប់អ្វីផ្សេងៗ, កាកល័ក្ត។

ចងល័ក្ត : យកស្រម៉ល័ក្តដែលនៅមានសត្វល្អិតជាមេដាក់ក្នុងសំបកកាតំស្ពឹកត្នោតជាដើមចងភ្ជាប់នឹងឈើរស់មានដើមសង្កែ, ត្រាង, ស្នួលជាដើម ដើម្បីឱ្យមេនោះចេញមកវារលោមមែកឈើកកើតបានជា ស្រម៉ល័ក្ខតទៅទៀត, បន្ទុំល័ក្ត។

បន្ទុំល័ក្ត : យកស្រម៉ល័ក្តដែលនៅមានសត្វល្អិតជាមេដាក់ក្នុងសំបកកាតំស្ពឹកត្នោតជាដើមចងភ្ជាប់នឹងឈើរស់មានដើមសង្កែ, ត្រាង, ស្នួលជាដើម ដើម្បីឱ្យមេនោះចេញមកវារលោមមែកឈើកកើតបានជា ស្រម៉ល័ក្ខតទៅទៀត, ចងល័ក្ត :

- របរចងល័ក្ត។

❖ ផង់ល្អិតឬកករឹងជាដុំមានពណ៌ផ្សេងៗសម្រាប់ប្រើជាគ្រឿងជ្រលក់ :

- ល័ក្តខៀវ
- ល័ក្តស្វាយ
- ល័ក្តបៃតង
- ល័ក្ខលឿងទុំ...។

❖ ឈ្មោះឈើឬដំណាំដែលមានសម្បុរដូចល័ក្តស្រម៉ :

- ចេកល័ក្ត

- ម្ទេសល័ក្ត ...។

**លក្ខណ៍** *ន.* លក្ខណៈ, លក្សណ៍ :

មនុស្សខាតលក្ខណ៍ : មនុស្សមានលក្ខណៈអភ័ព្វឬមានឫកពាថោក។

ស្ត្រីគ្រប់លក្ខណ៍ : ស្ត្រីដែលបរិបូណ៌ដោយលក្ខណៈល្អ។

**អំពី លាប, លាភ**

**លាប** *កិ.* (**បា. លេប < លិប**) ធ្វើវត្ថុខាប់រាវឬផង់ឱ្យជិតជាប់, ឱ្យជោក, ឱ្យប្រឡាក់; ផាត់ :

- លាបថ្នាំ
- លាបម្សៅ
- លាបប្រេង។

❖ **ព. ប្រ.** សេពគប់, ជិតដិត, ដិតដោយ, ចូលដៃ, ចូលគំនិត :

- លាបលន
- កុំលាបដោយមនុស្សខូច
- យកឈ្មោះគេមកលាប។

**លាភ** *ន.* (**បា. សំ.**) ការបាន, ដំណើរប្រទះលើការបាន, អ្វីៗដែលគួរបាន; ចំណេញ :

- មានលាភ
- កើតលាភ។

❖ ប្រើជាបទសមាសបើរៀងពីខាងដើមក៏បាន, រៀងពីខាងចុងសព្ទក៏បាន ដូចជា :

លាភគិទ្ធ : ដែលជាប់ជំពាក់ដោយលាភ, ដែលញ៉ាំមព្រោះធ្លាប់តែបាន; សេចក្ដីជាប់ចិត្តក្នុងលាភ។

លាភតណ្ហា : ចំណង់ឬសេចក្ដីស្ងន់ស្ងោទៅរកលាភ។

លាភន្តរាយ : សេចក្ដីអន្តរាយលាភ។

លាភវិនាស : ការខូចលាភ, ដំណើរខាតខានបាន។

លាភសក្ការៈ : លាភនិងសក្ការៈ។

លាភសន្តោស : សេចក្ដីត្រេកអរចំពោះតែត្រឹមលាភរបស់ខ្លួនគឺបានប៉ុន្មានយកប៉ុណ្ណោះមិនរវះរវាមហួសពីការបាន។

លាភសម្ប័ទ : សេចក្ដីសមប្រកបដោយការបាន, លាភសម្បទា។

លាភសម្បទា : សេចក្ដីសមប្រកបដោយការបាន, លាភសម្ប័ទ។

លាភាលាភ : ការបាននិងការខានបានឬការខាតបង់...។

ធនលាភ : ការបានទ្រព្យ។

ធម្មលាភ : ការបានដោយធម៌ (បានដោយត្រឹមត្រូវ), ធម្មិកលាភ។

ធម្មិកលាភ : ការបានដោយធម៌ (បានដោយត្រឹមត្រូវ), ធម្មលាភ។

បច្ចយលាភ : ការបាននូវបច្ច័យ។

បុញ្ញលាភ : ការបានដោយសារបុណ្យ។

បុត្តលាភ : ការបានកូន។

មិត្តលាភ : ការបានមិត្ត...។

## អំពី **លិច**, **លេច**

**លិច** *កិ.* លិបចុះបាត់ទៅ, ចូលកប់បាត់ទៅក្នុងទឹកជាដើម :

- ទូកលិច
- បន្ទាមុតលិច
- សន្ទូងលិចទឹក។

❖ អស្តង្គត :

- ព្រះអាទិត្យលិច (ថ្ងៃលិច)។

❖ **ព. ប្រ.** វិនាស, ខូច, អន្តរាយ; បាត់ឈ្មោះ; លង់គំនិត :

លិចខ្លួន : ខូចខ្លួនឬបាត់ឈ្មោះ។

លិចលែងងើបរួច : វិនាសរើខ្លួនលែងរួច។

❖ *គុ.* ដែលធ្ងន់មិនអណ្តែតទឹក :

- មួយកំណាត់នុ៎ះអណ្តែត
- ឈើមួយកំណាត់នេះលិចទឹក។

❖ ដែលទាបឬជ្រៅតែងតែលិចទឹក :

- ដីលិចទឹក
- ព្រៃទឹកលិច។

លិចកញ្ឆង់ : ដែលចេះតែហិនហោចវិនាសទ្រព្យសម្បត្តិជានិច្ច :

- មនុស្សលិចកញ្ឆង់។

លិចកញ្ឆង់លង់កញ្ឆើ : ហិនហោចវិនាសដូចគេលិចលង់ក្នុងទឹកទាំងកញ្ឆើដាក់អីវ៉ាន់។

លិចកណ្ដោងដី : វិនាសដូចជាកប់បាត់ទៅក្នុងដីកណ្ដោង។

លិចក្បាលទ្រទ្រូងដៃ : ដែលលិចក្បាលបាត់ទៅឃើញតែដៃ។

ទាំងពីរលើកជ្រោងឡើង : ទឹកជ្រៅលិចក្បាលទ្រទ្រូងដៃ។

លិចក្រជាំ : វិនាសទ្រព្យធនអាប់កេរ្តិ៍ឈ្មោះ។

- លិចតែម្ដង ! ខូចតែម្ដង; ! លិចទៅ ! ខូចទៅ ! (ពាក្យឧទាន)។

លិចលង់ : វិនាសអន្តរាយដូចជាលិចលង់ក្នុងទឹក។

លិចលង់ផុងកៃ : វិនាសអន្តរាយផុងលង់រើខ្លួនពុំរួច។

លិចអណ្ដែត : លិចខាតហើយចំណេញៗហើយខាតទៅវិញឬបង់ហើយបានៗហើយបង់ទៅវិញ, លិចៗអណ្ដែតៗ, លិចអណ្ដែតៗ។

លិចៗអណ្ដែតៗ : លិចខាតហើយចំណេញៗហើយខាតទៅវិញឬបង់ហើយបានៗហើយបង់ទៅវិញ, លិចអណ្ដែតៗ, លិចអណ្ដែត។

លិចអណ្ដែតៗ : លិចខាតហើយចំណេញៗហើយខាតទៅវិញឬបង់ហើយបានៗហើយបង់ទៅវិញ, លិចអណ្ដែត, លិចៗអណ្ដែតៗ។

- អាលិច !

- អាខូច ! (ពាក្យជេរលេង)...។

❖ *៦.* ឈ្មោះទិសដែលព្រះអាទិត្យអស្តង្គត, ទិសបស្ចិម; និយាយបានតែមានពាក្យខាងឬឯផ្សំពីខាងដើម :

- ទៅឯលិច

- ទិសខាងលិច

- ស្រុកឯលិច...។

❖ ល្ងង់មិនដឹងឯលិចឯកើតល្ងង់ដូចជា មនុស្សវង្វេងទិសឬល្ងង់មិនស្គាល់ទិស។

**លេច** *៣.* ចេញពីទីកំបាំង :

- ស្រាប់តែឃើញលេចប្លឹមពីក្នុងព្រៃមក។

❖ ជ្រាបហូរចេញ :

- ទឹកលេចពីភ្លឺស្រែ។

❖ លៀនចេញឬទុលចេញ :

- គ្រាប់ឈើដុះលេចពន្លកពីក្នុងដី។

❖ ធ្លាយឬលាន់ចេញ, ផ្សាយចេញ :

- លេចសម្តី

- លេចដំណឹង។

❖ បង្ហាញមុខឬចេញមុខឱ្យឃើញ :

- ចុះទើបនឹងលេចមុខមកពីណាហ្នឹង?

❖ ដើរលេចវាលចូលព្រៃ លេចព្រៃចូលវាល ដើរផុតពីទីវាលចូលក្នុងព្រៃចេញពីព្រៃចូលក្នុងវាលទៀត។

លេចឮ : លេចដំណឹងឮដល់...។

## ពាក្យទំនឹមបុរាណ

☆ លេចទឹកលេចត្រី : ការកំបាំងតែហើបចេញឮដល់មនុស្សម្នាក់ហើយច្រើនតែលេចឮតទៅទៀត (ស្រដៀងគ្នានឹង ក្អែកមួយជាក្អែកដប់ ដែរ)។

❖ *គុ.* ដែលមិនគត់ :

- ផ្ទះលេច

- ក្អមលេច

- ការុងលេច។

❖ **ព. ប្រ.** មាត់លេចមាត់រអិលចេះតែធ្លាយសម្ដីចេញទៅទប់មិនទាន់ :

- មនុស្សមាត់លេច (និយាយថាមាត់ដាចក៏បាន)។

❖ *ន.* ឈ្មោះដំបៅមួយប្រភេទកើតនៅបាតជើងឬកែងជើងលៀនសាច់រឹងចេញមក :

- កើតដំបៅលេច។

## អំពី លេស, លេះ ឬ លែះ

**លេស** *គុ* (បា. សំ.) តិច, តិចតួច; តូច, ឆ្មារ។

❖ *ន.* ហេតុបន្តិចបន្តួច; ការតូចតាច; ពុត; កិច្ចកល, ឧបាយ, ហេតុជាគ្រឿងអាង :

- អាងកូនក្មេងជាលេស
- យកជំងឺបន្តិចបន្តួចជាលេសឈប់មិនទៅធ្វើការ។

លេសភាព : ភាវៈនៃលេស, ដំណើរលេស។

លេសមត្ត : ការយកលេសជាប្រមាណ, ជាដុំកំភួន; ដំណើរត្រឹមតែលេស, លេសមាត្រ។

លេសមាត្រ : ការយកលេសជាប្រមាណ, ជាដុំកំភួន; ដំណើរត្រឹមតែលេស, លេសមត្ត។

លេសាបទេស : ការអាងលេស, ដំណើរយកលេសជាអាង...។

**លេះ** ឬ **លែះ** *ន.* (**បា. លិហ>លេហ** “លិទ្ធ, ជញ្ជក់”) វត្ថុដែលត្រូវលិទ្ធភ្លក្ស, ដែលត្រូវជញ្ជក់ជញ្ជាប; របស់តិចតួចស្តួចស្តើង :

- អស់អង្ករអស់ម្ហូបទៅហើយមានលែះអីស៊ី !
- អស់ប្រាក់រលីងទៅហើយបានលែះអីចាយ !

កណ្តាច់លែះ : ដែលទ័លក្ររហាមរកនេះបាត់រកនោះគ្មាន :

- មនុស្សកណ្តាច់លែះ។

## អំពី ស, សរ

**ស** *គុ.* ដែលមានសម្បុរដូចសំឡី កប្បាស :

- ពណ៌ស

- សំពត់ស។

សក្បុស : សណាស់។

សគ្រសុស : សម៉ដ្ឋប៉ផូរ, សផូរផង់។

សត្លី : សស្អាត។

សស្គុស : សត្រសោល, សបរិសុទ្ធ។

សស្វាច : សភ្លឺមើលទៅឃើញស្វាច...។

*គិ.* ចាក់បុះព្រាវដោយស្ន :

- ស្នត្រី។

❖ **ព. ប្រ.** សរកឱ្យឃើញ សង្កេតឃើញព្រាវ ដោយស្នានៗឱ្យឃើញ។

❖ សម្ដែងអាការៈឱ្យឃើញច្បាស់, បញ្ចេញបែបឱ្យឃើញជាក់ :

- សហេតុ

- សសេចក្ដី។

ហែកកេរ្តិ៍ : សកេរ្តិ៍ឬសកេរ្តិ៍សគុល។

## ពាក្យទំនឹមបុរាណ

❖ សម្ដីសជាតិ មារយាទសត្រកូល : សំនៀងភាសាសប្រាប់ឱ្យគេស្គាល់ជាតិឬកពាមារយាទ សម្រាប់ឱ្យគេស្គាល់ពូជត្រកូល។

**សរ** *៩.* ព្រួញ, កាំ, កាំធ្នូ, កាំស្នា :

- ត្រូវសរ

- ស្ដេចថ្លែងសរ។

សរជ័យ : សរមានជ័យ។

កូនសរ : ព្រួញ; គ្រាប់កាំភ្លើង...។

❖ រឭក, រឭកឃើញ, នឹកឃើញ, សាដឹងឡើងវិញ។

សរជាតិ : ដឹងជាតិ។

សរញាណ : ពិចារណាឬរំពឹងដឹងហេតុច្បាស់ទៅខាងអតីតកាល ឬខាងអនាគតកាល :

- ព្រះពុទ្ធទ្រង់សរញាណ។

**អំពី សក្តិ, ស័ក, សាក់**

**សក្តិ** ន. (សំ.) អំណាច, សេចក្ដីអង់អាច, សេចក្ដីក្លាហាន; កម្លាំង; ព្យាយាមរឹងប៉ឹង; ការខ្លាំងពូកែ; ការជំនាញ; សេចក្ដីធន់, ការប៉ុនធន់ទ្រាំ; លំពែង :

- សក្តិធំ

- សក្តិតូច

- សក្តិស្មើគ្នា

- អ្នកមានសក្តិ។

❖ ឥស្សរិយាភរណៈដែលប៉ាក់ដោយចេសមាសឬចេសប្រាក់ជាដើមសម្រាប់ដាក់ភ្ជាប់នឹងអាវរបស់មន្ត្រីសម្គាល់ឱ្យដឹងថ្នាក់ធំតូច :

- សក្តិ១

- សក្តិ២

- ពាក់សក្តិ

- សក្តិមាស

- សក្តិប្រាក់...។

សក្តិត្រ័យ : ប្រជុំ៣នៃសក្តិឬអង្គ៣នៃរាជសក្តិគឺ ព្រះរាជា, អមាត្យ ឬ មន្ត្រី, ពលសក្តិ (ពលរដ្ឋដែលមានកេរ្តិ៍ឈ្មោះ)។

សក្តិធរ : អ្នកទ្រទ្រង់សក្តិ; អ្នកកាន់លំពែងសក្តិ៩ហ៊ឺពាន់។

សក្តិយស : អំណាចនិងបរិវារ, ទ្រព្យសម្បត្តិ, កេរ្តិ៍ឈ្មោះល្អ, សេចក្តីរាប់អាននៃអ្នកដទៃ (និយាយថា យសសក្តិ ក៏បាន "បរិវារនិងអំណាច" ឬ "អំណាចលើបរិវារ")។

សក្តិសម : សមដោយអំណាច។

សមសក្តិ : អំណាចដ៏សមរម្យឬអំណាចស្មើគ្នា។

**ស័ក** ន. (**សំ. សក**) កាល, សម័យ, យុគ, ការរាប់លំដាប់ឆ្នាំ, ពួកជនជាតំណវង្សដែលជាប់ទាក់ទងដោយ **ក្សត្រសកៈ** ឬ **សាលិវាហនៈ**។ ខ្មែរប្រើពាក្យនេះចំពោះតែការរាប់លំដាប់ឆ្នាំតាំងពីស័កទី១ដល់ស័កទី១០ ត្រលប់សាមករាប់ពីស័កទី១វិញ គឺរាប់ថា :

- ឯកស័ក

- ទោស័ក

- ត្រីស័ក

- ចត្វាស័ក

- បញ្ចស័ក

- ឆស័ក

- សប្តស័ក

- អដ្ឋស័ក

- នព្វស័ក

- សំរឹទ្ធិស័ក។

❖ ដូចជាឆ្នាំថោះឯកស័ក...។ ឆ្នាំជូតសំរឹទ្ធិស័ក; ឆ្នាំឆ្លូវឯកស័ក,...។

**សាក់** *ន.* ស្នាមក្បាច់ក្បូរឬរូប, យ័ន្ត, អក្សរដែលចាក់នឹងម្ជុលឬដែកស្រួចបញ្ចូលទឹកខ្មៅឬទឹកក្រហម ជិតជាប់នៅក្នុងសាច់ :

- មនុស្សនុះមានសាក់រូបហនុមានត្រង់កំភួនដៃឆ្វេង។

❖ *កិ.* ចាក់ដោយម្ជុលឬដែកស្រួចបញ្ចូលទឹកខ្មៅឬទឹកក្រហមក្នុងសាច់ឱ្យជិតជាប់ជាក្បាច់ឬជារូប, យ័ន្ត, អក្សរ :

- ចូលចិត្តចង់សាក់ខ្ញុំសាក់ឱ្យ។

**អំពី សត្ត ឬ សត្វ, សត្យ, សាត់**

**សត្ត** *ប. សំ.* (បា.) ប្រាំពីរ (៧)។

សត្តខណ្ឌ : ៧សង្កាត់, ៧ផ្ទាំង។

ចីវរសត្តខណ្ឌ : ចីវរមានផ្ទាំង៧។

សត្តទិន : នៅអស់សត្តទិនគឺរវាង៧ថ្ងៃ (មួយសប្តាហ៍), សត្តវារៈ, សត្តពារ : ក្នុងមួយសត្តវារៈ។

សត្តវារៈ : នៅអស់សត្តទិនគឺរវាង៧ថ្ងៃ (មួយសប្តាហ៍), សត្តទិន, សត្តពារ : ក្នុងមួយសត្តវារៈ។

សត្តពារ : នៅអស់សត្តទិនគឺរវាង៧ថ្ងៃ (មួយសប្តាហ៍), សត្តទិន, សត្តវារៈ : ក្នុងមួយសត្តវារៈ។

សត្តមាស : ៧ខែ។

សត្តពិធ : ៧យ៉ាង, ៧បែប; ៧មុខ។

សត្តបរិតណ្ឌ : ភ្នំ៧សង្កាត់ដែលព័ទ្ធភ្នំព្រះសុមេរុ។

សត្តភូមិក : ដែលមានជាន់ឬថ្នាក់៧, ផ្ទះសត្តភូមិក ។

សត្តាហៈ : ៧ថ្ងៃ; រវាង៧ថ្ងៃ, មួយខួប៧ថ្ងៃ, មួយសត្តាហៈ; សប្តាហៈទី១។

សត្តាហកាលិក : ភេសជ្ជៈដែលភិក្ខុទទួលប្រគេនហើយត្រូវទុកខ្លួនឯងឆាន់បានយ៉ាងយូរត្រឹម៧ថ្ងៃ។

សត្តាហករណីយកិច្ច: កិច្ចធុរៈដែលភិក្ខុសាមណេរ អ្នកកំពុងនៅចាំវស្សាត្រូវអធិដ្ឋានចិត្តកំណត់ថ្ងៃ ហើយចេញទៅនៅក្រៅអាវាសបានយ៉ាងយូរ

ត្រឹម៦យប់...។

**សត្ត ន.** (**បា. សំ.**) បុគ្គលអ្នកជាប់ជំពាក់ក្នុងអារម្មណ៍ឬក្នុងបំណង; ខ្យល់ដកដង្ហើម, ជីវិត, ប្រាណ, បុគ្គលមានជីវិត (ក្នុងលោកទាំងអស់); កម្លាំង, ពលសក្តិ, អំណាច, សេចក្តីក្លាហាន; អធ្យាស្រ័យ; ការតាំងចិត្ត; សេចក្តីបរិសុទ្ធ, គុណសម្បត្តិសេចក្តីបរិសុទ្ធ; សេចក្តីពិត; ខ្លឹមសារ; វត្ថុ; ទ្រព្យ; ធម្មតា; ...។

សត្តក្ខ័យ : ដំណើរអស់អំណាច, អស់កម្លាំង, សត្វក្ស័យ...។

សត្វក្ស័យ : ដំណើរអស់អំណាច, អស់កម្លាំង, សត្តក្ខ័យ...។

សត្តគុណ : គុណនៃសេចក្តីបរិសុទ្ធ, សត្វគុណ។

សត្វគុណ : គុណនៃសេចក្តីបរិសុទ្ធ, សត្តគុណ។

សត្តឃាត : ការពិឃាតសត្វ :

- ទីសត្តឃាត
- ផ្សារសត្តឃាតទី
- ផ្សារពិឃាតសត្វ។

សត្តឃាតក: : អ្នកពិឃាតសត្វ (បើស្ត្រីជា សត្តឃាតិកា)។

សត្តឃាតដ្ឋាន : ទីសម្រាប់ពិឃាតសត្វឬទីដែលពិឃាតសត្វ, សត្វឃាតស្ថាន ។

សត្វឃាតស្ថាន : ទីសម្រាប់ពិឃាតសត្វឬទីដែលពិឃាតសត្វ, សត្តឃាតដ្ឋាន។

សត្តនាយក : អ្នកនាំសត្វ, អ្នកទូន្មានប្រដៅសត្វ; ព្រះពុទ្ធ។

សត្តនិករ : ពួកសត្វ, សត្តនិកាយ។

សត្តនិកាយ : ពួកសត្វ, សត្តនិករ។

សត្តលោក : ពពួកសត្វ, ដែលរាប់ថាជាលោកមួយ, សត្វលោក។

សត្វលោក : ពពួកសត្វ, ដែលរាប់ថាជាលោកមួយ, សត្តលោក។

**ពាក្យកាព្យ**

រីសត្វលោក តែងមានការស្មោក ព្រោះលោកធម៌
ឥតលាភអាក់អន់ មានលាភត្រេកអរ ចិត្តវែងត្រាច់ចរ
រវើកឥតស្រាក។

សត្តវិជ្ជា : វិជ្ជាសម្រាប់រក្សាសត្វ, វិជ្ជាពេទ្យសត្វ, សត្វវិទ្យា។

សត្វវិទ្យា : វិទ្យាសម្រាប់រក្សាសត្វ, វិទ្យាពេទ្យសត្វ, សត្តវិជ្ជា។

សត្តសញ្ញា : សេចក្ដីសម្គាល់ថាសត្វ; សញ្ញារបស់សត្វ។

សត្តសារ : ខ្លឹមរបស់សត្វ; (អ្នកមានបុណ្យអស្ចារ្យ, អច្ឆរិយមនុស្ស, ព្រះពុទ្ធ) ...។

**សត្យ** *ន.* (**សំ.**) សេចក្ដីពិត, ដំណើរទៀង, ទៀងទាត់, ដំណើរទៀងត្រង់, ការមែនប្រាកដ :

- និយាយដោយសត្យដោយធម៌។

❖ *គុ.* (**សំ.**) ដែលទៀង, ទៀងត្រង់, ពិត, ប្រាកដ, មែន :

ពាក្យសង្ឃពាក្យសត្យ : សម្ដីលោកសង្ឃជាពាក្យទៀងត្រង់។

សត្យវ័ត : ដែលមានពាក្យសត្យ (បើស្ត្រីជា សត្យវ័តី)។

**សាត់** ***កិ.*** ប៉ើង, ហើរតាមខ្យល់ឬអណ្ដែតតាមខ្សែទឹក (រសាត់)។

សាត់ព្រាត់ : ចេញចោលស្រុកទេសខ្ចាត់ភ្លាត់ព្រាត់បងប្អូនញាតិមិត្រ។

**ពាក្យទំនឹមបុរាណ**

❖ ត្រីកំភ្លាញលាញព្រោះមាត់, មនុស្សសាត់ព្រាត់លាញព្រោះឆោត : សាត់ភ្លាត់ដែលខិលខូចដើរសាត់អណ្ដែតតាមតែប្រទះ គ្មានលំនៅជាប្រាកដ។

❖ ឈើកោងវល្លិព័ទ្ធមនុស្សសាត់ឆ្ងាត់កុំយកខ្លួនបៀតៗ សាត់អណ្ដែត, សាត់អណ្ដែតសែតអញ្ចង់ : ដែលដើរសាត់ព្រាត់ទៅតាមតែប្រទះឥតមានទីនៅជាប្រាកដ។

- មនុស្សសាត់អណ្ដែត
- ដើរសាត់អណ្ដែតសែតអញ្ចង់។

**អំពី សា, សារ**

**សា** ***កិ.*** មូរឡើងវិញ :

- សាកន្ទេល។

❖ កើបឡើងវិញ :

- សាស្រូវ។

❖ ត្រលប់វិញ :

- សាមកវិញ

- ដើរសាចុះសាឡើង។

❖ វើឈឺឡើងវិញ :

- សាឈឺឡើងវិញ។

❖ និយាយថ្លែងពីទុក្ខឬថ្លែងពីទុក្ខទោសដែលកន្លងហួសទៅហើយ, មានដំណើរគួរឱ្យរង្កៀសចិត្ត, ដើម្បីអ្នកស្ដាប់ដឹងច្បាស់; និយាយសើរើពីទុក្ខឬទោសរបស់ខ្លួន :

- និយាយសាទុក្ខ

- សាទុក្ខសាទោស។

❖ និយាយជាថ្មីទៀតឬនិយាយសើរើថែមទៀត :

- សានិយាយម្ដងទៀត។

❖ វើធ្វើជាថ្មីទៀត :

- សាធ្វើជាថ្មី។

❖ ដំណើរត្រលប់ទៅមកឬចុះឡើង; ដង, គ្រា, ត្រលប់; បក :

- ដើរមួយសា

- មួយសាពីរសា។

❖ ៨. ស្រូវឬដំណាំពួកខ្លះដែលដុះលូតលាស់តពីគល់ចាស់ឬពីជញ្ជ្រាំងស្រស់ :

- សាស្រូវ

- សាឪឡឹក។

❖ ប្រើដូចជា ន. ក៏បាន :

- ស្រូវសា

- ឪឡឹកសា។

❖ ឈ្មោះជំងឺខ្យល់ពួកមួយចាប់សត្វចតុប្បាទមានគោក្របីជាដើម :

- ជំងឺសា

- សាថាប់។

❖ ឈ្មោះម្ហូបមួយប្រភេទជាគ្រូគ្នានឹងភ្ជា :

- សាត្រីក្អែក។

❖ ក្រពះមូត្រសត្វពួកខ្លះមានសំពោច, ឆ្កួកជាដើម :

- សាសំពោច។

បែកសា : បែកក្រពះមូត្រ។

❖ **ព. ប្រ.** និយាយបែកសាឬបែកសាយាមោនិយាយបែកពីនេះហើយពីនោះទៀតល្អូល្អាចស្មើររកទីចប់គ្មាន។

ឈ្លោះបែកសា : ឈ្លោះប្រកែកជជែកបូរបាច់ឮខ្លាំងៗដណ្ដើមយកផ្លូវត្រូវតែរៀងខ្លួន។

បែកការខ្ចរខ្ចាយសាយសុស : ដំណើរនុ៎ះវាបែកសាខូចអស់ទៅហើយ !

**សារ** *ន.* (**បា. សំ.**) ខ្លឹម; សេចក្ដីខ្ជាប់ខ្ជួន, មាំមួន, រឹងប៉ឹង; ការសំខាន់, របស់សំខាន់; គោល, គោលចារឹក, ហ្ល័កឋាន; កម្លាំង; អំណាច, សេចក្ដីអង់អាច, សេចក្ដីក្លាហាន; សំណាង, បុណ្យភ័ព្វ; តម្លៃ, ទ្រព្យ, សម្បត្តិ; របស់សុទ្ធ; សេចក្ដីពិត; ប្រយោជន៍, ផលប្រយោជន៍; ធាតុសុទ្ធឬធាតុផ្សំណាមួយ; សំបុត្រ, ចុតហ្មាយ; ពាក្យសង្ខេប, សេចក្ដីបំប្រួញ; ...។

❖ *គុ.* រឹង, រ៉ឹងប៉ឹង, ខ្ជាប់ខ្ជួន, មាំមួន; ខ្លាំង, ដែលមានកម្លាំង; ដែលក្លាហាន, អង់អាច, អាចហាន; ដែលពិត, ប្រាកដ; មានតម្លៃ; ថ្លៃ, ថ្លៃថ្លា, ប្រសើរ, ខ្ពង់ខ្ពស់; សំខាន់; គ្រប់, គ្រប់សព្វ; ...។

ខ្លឹមសារ : ខ្លឹមរឹង, ខ្លឹមសំខាន់; ប្រយោជន៍ថ្លៃថ្លា។

មានសារមកដល់ : មានសំបុត្រមកដល់។

ឥតសារ : ឥតខ្លឹម; ឥតតម្លៃ; ឥតប្រយោជន៍។

ឥតសព្ទឥតសារ : ឥតផលប្រយោជន៍, មិនបានការ, សម្ដីឥតសព្ទឥតសារ។

❖ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃក៏បាន, ដូចជា :

សារកតិកា : សេចក្ដីប្ដេជ្ញាមានហ្ល័កឋាន។

សារកម្មទណ្ឌ : សំបុត្រដែលសាមីខ្លួនអ្នកទ័លក្រធ្វើដាក់ដៃអ្នកម្ចាស់ប្រាក់ប្រគល់ខ្លួនជា ទាស: ឬ ទាសី នៅបម្រើគេ (ប្រើតែក្នុងសម័យពីដើម)។

សារគតិ : គតិខ្ជាប់ខ្ជួន។

សារគន្ធ : ក្លិនខ្លឹម (មានខ្លឹមចន្ទន៍ជាដើម)។

សារជាត : ឈើមានខ្លឹម, សារព្រឹក្ស។

សារព្រឹក្ស : ឈើមានខ្លឹម, សារជាត។

សារតាំង : សារ (សំបុត្រ) តែងតាំងដែលប្រមុខរដ្ឋចេញឱ្យទូតកាន់ទៅប្រគល់ជូនចំពោះប្រមុខរដ្ឋបរទេស ដែលទូតនោះត្រូវនៅអែបទាក់ទងជាមួយ :

- ប្រគល់សារតាំង

- បានទទួលសារតាំង។

សារត្រា : សំបុត្រអគ្គសេនាបតីប្រើជាផ្លូវរាជការ (សម័យពីដើម) : សំបុត្រប្រកាសរបស់រដ្ឋមន្ត្រីណាមួយប្រើជាផ្លូវរាជការ (សម័យបច្ចុប្បន្ន) : សារត្រារដ្ឋមន្ត្រីក្រសួងអប់រំជាតិ។

សារទស្សី : អ្នកដែលយល់ឃើញធម៌ឬអ្វីមួយថាជាសារៈ។

សារទិស : គ្រប់ទិស។

សារទុក្ខ : ទុក្ខគ្រប់សព្វ, ទុក្ខទាំងពួង។

សារទ្រព្យ : ទ្រព្យមានតម្លៃ, សារធន។

សារធន : ទ្រព្យមានតម្លៃ, សារទ្រព្យ។

សារធម្ម : ធម៌ជាសារៈ, ធម៌ជាគោល, សារធម៌។

សារធម៌ : ធម៌ជាសារៈ, ធម៌ជាគោល, សារធម្ម។

សារបណ្ណ : សារបញ្ជីសន្លឹកប្រាប់បញ្ជីមាតិកាឬសន្លឹកប្រាប់បញ្ជីរឿង, បញ្ជីមាតិកា, បញ្ជីរឿង, សារប័ព្វ។

សារប័ព្វ : សារបញ្ជីសន្លឹកប្រាប់បញ្ជីមាតិកាឬសន្លឹកប្រាប់បញ្ជីរឿង, បញ្ជីមាតិកា, បញ្ជីរឿង, សារបណ្ណ។

សារប្បវត្តិ : ដំណឹងពិត; កាសែត, សារព័ត៌មាន។

សារព័ត៌មាន : ដំណឹងពិត; កាសែត, សារប្បវត្តិ។

សារពស្តុ : វត្ថុជាសារៈ, របស់មានតម្លៃ, សារវត្ថុ។

សារវត្ថុ : វត្ថុជាសារៈ, របស់មានតម្លៃ, សារពស្តុ។

សារព្រឹក្ស : ដូចគ្នានឹង សារជាត។

សារភណ្ឌ : ភណ្ឌៈមានតម្លៃ; ទំនិញមានតម្លៃ។

សារភាព : ភាវៈពិត, ដំណើរឬសេចក្ដីពិត : ទទួលសារភាពទទួលតាមដំណើរពិត, ទទួលខុស។

សារភូត : ដែលជាសារៈ, ដើមចម, ជាគោល, ជាហ្ល័កឋាន។

សារមតិ : គំនិតដែលយល់ធម៌ឬអ្វីមួយថាជាសារៈ។

សារមតី : អ្នកដែលមានគំនិតយល់ថាជាសារៈ។

សារមន្ទីរ : មន្ទីរដាក់របស់មានតម្លៃ; វិវិធភណ្ឌដ្ឋាន។

សារវន្ត : ដែលមានសារៈ, ដែលមានប្រយោជន៍, ដែលសំខាន់, ដែលប្រកបដោយខ្លឹមសារ។

សារិទ : អ្នកដឹងអ្វីៗដែលជាប្រយោជន៍ឬដែលមានតម្លៃ, សារវិទូ។

សារិទូ : អ្នកដឹងអ្វីៗដែលជាប្រយោជន៍ឬដែលមានតម្លៃ, សារវិទ។

សារសព្ទ : ពាក្យពិត; ពាក្យមានប្រយោជន៍, ពាក្យមានតម្លៃ។

សារសូន្យ : ដែលសូន្យចាកតម្លៃ; ដំណើរសូន្យចាកប្រយោជន៍ឬសូន្យចាកតម្លៃ, ការខូចប្រយោជន៍, ការអស់តម្លៃ។

សារាចរ : លិខិតមានកម្មវត្ថុដូចគ្នាតែមួយដែលប្រាស្រ័យចំពោះបុគ្គលច្រើនគ្នាដូចយ៉ាងលិខិតរបស់នាយករដ្ឋមន្ត្រី ដែលប្រាស្រ័យកិច្ចការជាមួយនឹងក្រសួងរដ្ឋមន្ត្រីនានាជាដើម :

- ប្រតិបត្តិតាមសារាចរ

- ធ្វើសារាចរបង្គាប់ទៅគ្រប់ក្រុមក្រោមឱវាទ។

សារាសារៈ : សារៈនិងអសារៈ; ខ្លាំងនិងខ្សោយ; កម្លាំងនិងកម្សោយ។

❖ ៩. ដំរីស្ទាវឬដំរីមានភ្លុកដែលធំអស់ទំហំហើយ :

- ដំរីសារ។

**ពាក្យទំនឹមបុរាណ**

ដំរីសារស្លាប់យកចង្អេរបាំង : ការអាក្រក់យ៉ាងធំខំប្រឹងបិទបាំងដោយហេតុឬដោយឧបាយបន្តិចបន្តួចធ្វើម្តេចនឹងកំបាំង។

គជសារ : ដំរីមាឌធំសម្បើម។

## អំពី **សាសន៍, សាស្ត្រ, សះ**

**សាសន៍** *ន.* (**បា. សំ. សាសន**) សាសន, សាសនា :

- ចូលសាសន៍
- សាសន៍ព្រាហ្មណ៍
- សាសន៍ព្រះពុទ្ធ ឬ ពុទ្ធសាសន៍។

❖ មនុស្សខ្លះមានជាតិត្រូវគ្នា ប៉ុន្តែសាសន៍ខុសគ្នា; ខ្មែរ, សៀម, លាវ, មន, ភូមា, សិង្ហល, ...មានជាតិផ្សេងគ្នា ប៉ុន្តែសាសន៍ត្រូវគ្នាព្រោះជាពុទ្ធសាសន៍ដូចគ្នា។

**សាស្ត្រ** *ន.* (**សំ.**) គម្ពីរ, គម្ពីរប្រាប់វិទ្យា, គម្ពីរសាសនា; ច្បាប់, ច្បាប់ប្រដៅក្បួន, តម្រា; វិជ្ជា; ការសិក្សា; ពាក្យណែនាំ, ពាក្យពន្យល់; ពាក្យបង្គាប់។ បើរៀងភ្ជាប់ពីខាងចុងសព្ទដទៃក៏បាន, ដូចជា :

ប្រវត្តិសាស្ត្រ : គម្ពីរឬក្បួននិយាយអំពីពង្សាវតារប្រទេស...។

វិទ្យាសាស្ត្រ : គម្ពីរឬក្បួនប្រាប់វិទ្យាផ្សេងៗ; វិជ្ជាពួកមួយដែលគេរកឃើញដោយការលៃផ្សំធាតុជាដើម។

សិល្បសាស្ត្រ : តម្រាសម្រាប់រៀនសិល្បៈ។

សាស្ត្រចក្សុ : ភ្នែករបស់សាស្ត្រ, សាស្ត្រនេត្រ, សាស្ត្រន័យន៍។

សាស្ត្រន័យន៍ : ភ្នែករបស់សាស្ត្រ, សាស្ត្រចក្សុ, សាស្ត្រនេត្រ។

សាស្ត្រនេត្រ : ភ្នែករបស់សាស្ត្រ, សាស្ត្រចក្សុ, សាស្ត្រន័យន៍។

សាស្ត្រាចារ្យ : គ្រូបង្រៀនសាស្ត្រ។

**សាសន** *ន.* (**បា. សំ.**) ពាក្យបណ្ដាំ, ពាក្យផ្ដាំផ្ញើ; ពាក្យប្រៀនប្រដៅ, ការប្រៀនប្រដៅ; សាសនា, លទ្ធិ; ពាក្យបង្គាប់, ការបង្គាប់បញ្ជា; ដំណឹង; សំបុត្រ; ពាក្យប្រកាស, ការប្រកាសប្រាប់; ការជឿស្ដាប់; ការដាក់ទណ្ឌកម្ម, ការផ្ចាលទោស; ការកែសម្រួល; ការគ្រប់គ្រង; ការត្រួតត្រា។

សាសនកាល : កាលដែលឥតអំពីសាស្ដាដើមទៅហើយនៅសល់តែសាសនា។

សាសនសម័យ : សម័យដែលឥតអំពីសាស្ដាដើមទៅហើយនៅសល់តែសាសនា។

សាសនកិច្ច : កិច្ចក្នុងសាសនាឬរបស់សាសនា។

សាសនក្រឹត្យ : ក្រឹត្យក្នុងសាសនាឬរបស់សាសនា។

សាសនហារិន : អ្នកនាំសំបុត្រ, អ្នកនាំដំណឹងឬពាក្យបណ្ដាំ (បើស្ត្រីជា សាសនទូតី, សាសនហារិនី)។

សាសនហារី : អ្នកនាំសំបុត្រ, អ្នកនាំដំណឹងឬពាក្យបណ្ដាំ (បើស្ត្រីជា សាសនទូតី, សាសនហារិនី)។

សាសនទូសក: : អ្នកប្រទូស្តសាសនា (បើស្ត្រីជា សាសនទូសិកា)។

សាសនធម៌ : ធម៌ជាពាក្យប្រៀនប្រដៅក៏គឺសាសនានុ៎ះឯង។

សាសនបត្រ : សំបុត្របញ្ជាក់ការយ៉ាងដាច់ខាត។

សាសនប្បដិបត្តិ : ការប្រតិបត្តិតាមសាសនា។

សាសនប្រតិបត្តិ : ការប្រតិបត្តិតាមសាសនា, សាសនប្បដិបត្តិ។

សាសនប្បវត្តិ : ដំណើងសាសនា, ពង្សាវតារសាសនា។

សាសនប្រវត្តិ : ដំណើងសាសនា, ពង្សាវតារសាសនា។

សាសនមណ្ឌល : មណ្ឌលសាសនា, សាសនាទាំងមូល។

សាសនមូល : ទីតាំងឬឫសគល់នៃសាសនា។

សាសនវិទ : អ្នកប្រាជ្ញខាងការប្រកាសសាសនា។

សាសនវិទូ : អ្នកប្រាជ្ញខាងការប្រកាសសាសនា។

សាសនវោហារ : វោហារបស់សាសនា, ពាក្យប្រើក្នុងសាសនា។

សាសនសម្បត្តិ : សម្បត្តិសម្រាប់ទំនុកចម្រុងសាសនា។

សាសនាយុ : អាយុសាសនាគឺការឋិតនៅនៃសាសនា។

សាសនូបត្ថម្ភ : ការទំនុកបម្រុងសាសនា។

សាសនូបត្ថម្ភក៏ : អ្នកទំនុកបម្រុងសាសនា។

សាសនោវាទ : ដំបូន្មានក្នុងសាសនា...។

**សះ** ***កិ.*** ជាដំបៅ, បាត់ដំបៅ :

ដំបៅសះ : សះដំបៅ។

សះជា : ជានឹងគ្នា, លែងខឹងប្រកាន់គ្នា, លែងទាស់គ្នា។

សះស្បើយ : បាត់ឈឺស្រាលះ, ជាស្រាលះពីជំងឺ, ជាស្មោះស្មាន។

## អំពី សិង, សិង្ហ, សឹង

**សិង** *កិ.* ដេក។ ខ្មែរប្រើចំពោះតែជាសមណសព្ទ :

- លោកសិង (បព្វជិតដេក)។

**សិង្ហ** *ន.* (**សំ. សឹហ**) សីហៈឬតោ។ អ្នកខ្លះយល់ថាសិង្ហដោយខ្លួនតោដោយខ្លួន, ចួនកាលហៅរួមថា **សិង្ហតោ** យល់ថា **សិង្ហ** និង **តោ**; តាមសេចក្ដីពិតសិង្ហ ឬ **សីហៈ** ប្រែថា **តោ** មិនមែនទីទៃពីគ្នាទេ, ប៉ុន្តែជាងរាល់ប្រទេសច្រើនធ្វើរូបក្លាយផ្សេងៗពីគ្នា ក៏នាំឱ្យមានអ្នកយល់ថា **សិង្ហ** ឬ **សីហៈ** ទីទៃពី **តោ**។

**សឹង** *និ.* រកកល់, រកកល់នឹង, ស្មើរនឹង :

- ថាដូច្នេះវិញក៏សឹងបាន។

សឹងតែ *និ.* រកកល់តែ, ស្មើរតែ; ក៏បានដែរ :

- បើអ្នកមិនយកឱ្យមកខ្ញុំវិញក៏សឹងតែបានឥតទាស់អ្វីទេ។

**ស៊ឹង** *និ.* (ព. សា.) ស្មើរនឹង, វិះនឹង :

- ពិបាកស៊ឹងស្លាប់។

❖ ស៊ឹងនឹង ឬ ស៊ឹងតែនឹង *និ.* ស្មើរនឹង ឬ ស្មើរតែនឹង :

- ពិបាកចិត្តស៊ឹងនឹងទ្រាំមិនបាន។

## អំពី សិល្ប៍, សីល

**សិល្ប៍** *ន.* (**សំ. សិល្ប**) សិប្បៈ។

រៀនសិល្ប៍ : រៀនសិប្បៈ។

អ្នកសិល្ប៍ : អ្នកចេះសិប្បៈ។

❖ ខ្មែរហៅសំដៅចំពោះមនុស្សក្បត់ផែនដីដែលប្រកាសខ្លួនថាជាអ្នកខ្លាំងពូកែឬថា ជាអ្នកបុណ្យដឹកនាំប្រជាជនអ្នកឆោតល្ងង់ឱ្យចុះចូលខ្លួនហើយតាំងកជាទ័ព (ដូចយ៉ាងអាចារ្យស្វា, ពោធិ៍កំបោរជាដើម) :

- កើតមានអ្នកសិល្ប៍ទៅតាំងសិល្ប៍នៅក្នុងព្រៃស្ងាត់។

- សិល្បករ។

សិល្បការ : ជាង, អ្នកធ្វើជាង, សិល្បការិន។

សិល្បការិន : ជាង, អ្នកធ្វើជាង, សិល្បការ។

សិល្បជីវិកា : ការចិញ្ចឹមជីវិតដោយសិប្បកម្ម។

សិល្បជីវិន : អ្នកចិញ្ចឹមជីវិតដោយសិប្បកម្ម។

សិល្បវិទ : អ្នកចេះសិល្បៈ (សិប្បវិទូ)។

សិល្បវិជ្ជា : ការចេះសិល្បៈ; ចំណេះជាង (សិល្បសាស្ត្រ)។

សិល្បសាលា : រោងរៀនសិល្បៈ; រោងការ (សិប្បសាលា), សិល្បាគារ, សិល្បគ្រឹះ។

សិល្បគ្រឹះ : រោងរៀនសិល្បៈ; រោងការ (សិប្បសាលា), សិល្បាគារ, សិល្បសាលា។

សិល្បាគារ : រោងរៀនសិល្បៈ; រោងការ (សិប្បសាលា), សិល្បគ្រឹះ, សិល្បសាលា។

សិល្ប៍សាស្ត្រ : ក្បួនរៀនសិល្បៈ; ចំណេះជាង។

សិល្បសិក្សា : ការរៀនសិល្បៈ; ការរៀនធ្វើជាង។

សិល្បាករ : ទីកើតសិល្បៈ; កន្លែងបង្កើតសិល្បៈ...។

សិល្ប៍សាស្ត្រវិទ្យាការ : ការចេះសិល្បសាស្ត្រ។ ខ្មែរច្រើនហៅសំដៅចំពោះមន្តអាគមផ្សេងៗ។

**សីល ន.** (**បា. សំ.**) វិរតិចេតនាដែលវៀរចាកអំពើអាក្រក់, ការកាន់ឬប្រព្រឹត្តល្អដោយកាយវាចា, ការមិនប្រព្រឹត្តកន្លងសិក្ខាបទឬវិនយប្បញ្ញត្តិ។ ការកាន់ចរិយាល្អ; ការសង្រួម; អង្គនៃចរិយា; ចរិត, ចរិយា; មារយាទល្អ; សេចក្ដីល្អ; គតិ; លក្ខណៈ; និស្ស័យ; អធ្យាស្រ័យ; សភាព; ប្រក្រតី; ទម្លាប់; សណ្ដាប់ធ្នាប់; ធម្មជាត; ធម្មតា...។ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃក៏បាន :

សីលកថា : សម្ដីនិយាយអំពីសីល, និយាយអំពីការប្រព្រឹត្តល្អ។

សីលខណ្ឌ : ការដាច់សីល, ដំណើរខូចការប្រព្រឹត្តល្អ។

សីលភេទ : ការដាច់សីល, ដំណើរខូចការប្រព្រឹត្តល្អ។

សីលក្ខន្ធ : កងសីល។

សីលគន្ធ : ក្លិនសីល គឺកេរ្តិ៍ឈ្មោះល្អ។

សីលគុណ : គុណសីល។

សីលច្ចាគ : ការលះបង់សីល, ការលះសេចក្ដីល្អចោល។

សីលត្យាគ : ការលះបង់សីល, ការលះសេចក្ដីល្អចោល។

សីលតេជះ : តេជះសីល, អំណាចការប្រព្រឹត្តល្អ។

សីលទាយ : អ្នកឱ្យសីល (បើស្ត្រីជា សីលទាយិកា)។

សីលធន : សីលដែលទុកជាទ្រព្យ (របស់សត្វលោក)។

សីលធម៌ : សីលដែលជាធម៌ (របស់សត្វលោក) ឬសីលនិងធម៌; កិរិយាមារយាទ, សណ្ដាប់ធ្នាប់; ដំបូន្មានដែលនាំឱ្យចៀសវាងអំពើអាក្រក់ ហើយឱ្យប្រព្រឹត្តតែអំពើល្អ :

- ប្រាកចាកសីលធម៌

- ប្រកបដោយសីលធម៌។

សីលនិធិ : ការប្រព្រឹត្តល្អដែលទុកជាកំណប់ទ្រព្យ។

សីលវន្ត : អ្នកមានសីល (បើស្ត្រីជា សីលវតី ឬ សីលវន្តី)។

សីលវិបត្តិ : ការវិនាសសីល, ការដាច់សីល; ការខូចមារយាទល្អ។

សីលវិសុទ្ធិ : សេចក្ដីបរិសុទ្ធនៃសីល។

សីលសមាទាន : ការទទួលសីល, ការកាន់សីល។

សីលសម្បត្តិ : ការបរិបូណ៌ដោយសីល, ការជាប់សីល, សីលសម្ប័ទ, សីលសម្បទា។

សីលសម្ប័ទ : ការបរិបូណ៌ដោយសីល, ការជាប់សីល, សីលសម្បត្តិ, សីលសម្បទា។

សីលសម្បទា : ការបរិបូណ៌ដោយសីល, ការជាប់សីល, សីលសម្បត្តិ, សីលសម្ប័ទ។

សីលសារ : សីលដែលទុកជាខ្លឹម (របស់សត្វលោក)។

សីលាចារ : សីលនិងមារយាទ។

សីលាទិគុណ : គុណមានសីលជាដើម។

សីលានុស្សតិ : ការនឹករំពឹងដល់សីល...។

**អំពី សុក, សុក្រ, សុខ**

**សុក** *ន.* អាការៈមួយប្រភេទជាស្រោមស្រោបកូនដែលនៅក្នុងផ្ទៃម្ដាយមានទងជាប់នឹងផ្ចិតកូន ជាផ្លូវជ្រួតជ្រាបរសជាតិឱ្យកូនចម្រើនធំតាមកំណត់, ឋិតនៅក្នុងស្រោមទឹកភ្លោះ, វេលាដល់កាលកំណត់ស្រោមទឹកភ្លោះបែកកូនក៏សម្រាលចេញមក, គេកាត់ទងសុកឱ្យដាច់ចេញពីផ្ចិតកូន...។

ទីកប់សុក : ទីដែលកាលកើតគេយកសុកទៅកប់ គឺជាតិភូមិ; ជួនកាលគេនិយាយថាទីកប់សុកទុកភូមិ។

បងប្អូនប្រធាក់ទងសុក : បងប្អូនបង្កើតរួមមាតាមួយ (កូនភ្លោះ)។

**សុក្រ** *ន.* (សំ.) ឈ្មោះផ្កាយទី៦ គឺផ្កាយប្រចាំទ្វីបឬផ្កាយព្រឹក :

- ផ្កាយសុក្រ។

ឈ្មោះថ្ងៃទី៦ : ថ្ងៃសុក្រ។

**សុខ** *គុ.* (បា. សំ.) ដែលសប្បាយ; ងាយ; ស្រួល; ស្រណុក; សម្រាន្ត។

❖ *ន.* សេចក្ដីសប្បាយ; ដំណើរងាយ; ដំណើរស្រួល; ដំណើរស្រណុក; សេចក្ដីសម្រាន្ត :

- មានសុខ

- បានសុខ។

❖ ប្រើពាក្យ "សេចក្ដី" ផ្សំខាងដើមផងក៏បាន : មានសេចក្ដីសុខ។

សុខកថា : សម្ដីដែលនាំឱ្យបានសុខ។

សុខកាម : អ្នកស្រលាញ់សុខ, អ្នកប្រាថ្នាសុខ។

សុខកាយ : ស្រួលខ្លួន។

សុខការណ៍ : ហេតុដែលនាំឱ្យបានសុខ, ហេតុដែលនាំឱ្យបានស្រួល។

សុខកិរិយា : ការធ្វើឱ្យបានសុខ, ការធ្វើឱ្យបានស្រួល។

សុខក្សេម : សុខសម្រាន្ត, សុខស្រួល។

សុខចិត្ត : សប្បាយចិត្ត; ពេញចិត្ត, ល្មមដល់ចិត្ត។

សុខទាយក : អ្នកឱ្យសុខ។

សុខទាយិកា : ស្ត្រីឱ្យសុខ។

សុខទុក្ខ : សុខនិងទុក្ខ។

សុខប្រធាន : ការប្រគល់សុខឱ្យ, ការឱ្យសុខ។

សុខប្រាប្ត : អ្នកដែលបានប្រទះសេចក្ដីសុខ, អ្នកបានសុខ។

សុខព័ន្ធន៍ : ការជាប់ជំពាក់ដោយសេចក្ដីសុខ។

សុខភាព : ភាពជាសុខ, សេចក្ដីសុខ។

សុខភូមិ : ទីដែលប្រកបដោយសុខ, ទីស្រួលនៅ។

សុខយាត្រា : ការដើរស្រួល។

សុខយាន : យានស្រួលជិះ។

សុខលាភ : ការបានសុខ។

សុខលក្ខណ: : លក្ខណៈនៃសេចក្ដីសុខ។

សុខវឌ្ឍក: : អ្នកដែលចម្រើនដោយសុខ (បើស្ត្រីជា សុខវឌ្ឍិកា)។

សុខវឌ្ឍន៍ : ការចម្រើនដោយសុខ។

សុខវិជ្ជា : វិជ្ជាប្រាប់វិធីប្រតិបត្តិឬថែទាំមានការសម្អាតជាដើមដែលនាំឱ្យបានសុខ។

សុខវិទ្យា : វិទ្យាប្រាប់វិធីប្រតិបត្តិឬថែទាំមានការសម្អាតជាដើមដែលនាំឱ្យបានសុខ។

សុខវិទ្យាសាស្ត្រ : ក្បួនឬតម្រា, ច្បាប់និយាយអំពីខុសវិទ្យា។

សុខវេទនា : ការទទួលអារម្មណ៍ជាសុខ។

សុខសម្ផស្ស : សម្ផស្សដែលស្រួល, ការប៉ះប្រទះសេចក្ដីសុខ។

សុខសម្ភាស : អ្នកពោលពាក្យនាំឱ្យបានសុខ; អ្នកនិយាយសម្ដីងាយស្ដាប់។

សុខសយនា : កន្លែងដេកស្រួល។

សុខសាន្ត : សុខស្ងប់។

សុខសាន្តត្រាណ : ដែលមានទីពំនាក់ឬមានទីអាងឱ្យបានសុខស្ងប់ : ស្រុកសុខសាន្តត្រាណ។

សុខសាសន៍ : ដំណឹងឬសំបុត្រប្រាប់សេចក្ដីសុខ។

សុខសួស្ដី : សុខនិងសួស្ដី។

សុខសេយ្យា : ការដេកជាសុខ, ការដេកស្រណុក។

សុខា : សេចក្ដីសុខ។

**ពាក្យកាព្យ**

សូមពួកទេវតា ជួយឱ្យសុខា ដល់ពួកអ្នកត្រង់
កាន់សីលកាន់ធម៌ បវរផ្ចិតផ្ចង់ ពុំដែលលុះលង់
ក្នុងក្ដីទុច្ចរិត។

សុខាភិបាល : ការថែរក្សាឬគ្រប់គ្រង, ការទំនុកបម្រុងឱ្យបានសុខ។ ឈ្មោះក្រសួងរដ្ឋមន្ត្រីមួយកាន់កាប់ខាងមុខការថែរក្សាប្រជាពលរដ្ឋឱ្យបានប្រកបដោយសុខភាព គឺក្រសួងពេទ្យ :

- ក្រសួងសុខាភិបាលឬក្រសួងសាធារណសុខាភិបាល

- ក្រសួងសុខាភិបាលជាសាធារណៈ។

សុខាភិយាចនា : ការបន់ស្រន់, ការបួងសួង, សំបូងសង្រូងសូមឱ្យបានសុខ : ធ្វើសុខាភិយាចនា។

សុខារម្មណ៍ : អារម្មណ៍ជាសុខ, អារម្មណ៍ដែលទទួលសេចក្ដីសុខ។

សុខាសា : បំណងឱ្យបានសុខទៅមុខ...។

**អំពី ស្វ, ស្វរ, ស្វៀ**

**ស្វ** *ន.* (*ស.*) ខ្សែមាសឬប្រាក់មានសណ្ឋានជាច្រវាក់ :

- ខ្សែស្វ។

**ស្វរ** *ន.* (*សំ.* **ស្វរ**) សព្ទ, សំឡេង; សំឡេងលាន់ឮ :

- ស្វរផ្គរ
- ស្វរភ្លេង
- ឥតស្វរ
- ស្វរកាំភ្លើង។

ស្វរសព្ទ : ស្វរសំឡេងឬសំឡេងកៀវក្លា, សំឡេងខ្លាំង។

ស្វរសព្ទ : សំនៀងនៃព្រះសម្មាសម្ពុទ្ធប្រកបដោយអង្គ៨ហៅថា អដ្ឋង្គុបតសរៈ ឬ អដ្ឋង្គិកសរៈ គឺ

១- ស្រលះស្រឡះស្មើៗ

២- ស្រទន់ពីរោះ

៣- ឱ្យអ្នកស្ដាប់ងាយដឹងងាយយល់

៤- គួរឱ្យអ្នកស្ដាប់ចង់ស្ដាប់មិនធុញទ្រាន់

៥- ក្បោះក្បាយមិនស្អកស្អា

៦- មានសូរនិគ្គហិតមូលក្រឡង់

៧- មានសូរជ្រៅក្នុងទ្រូង

៨- ក្រាងក្រអៅ។

ស្ងួរសៀង : ស្ងួរសំឡេងឬសំឡេងក្លៀវក្លា; (រ. ស.) : ព្រះស្ងួរសៀង។

**ស្ងួរ គុ.** ក្លៀវក្លា, អង់អាច, ក្លាហាន, អាចហាន, ដែលមានចិត្តមុត, មោះមុត។

❖ ***ន.*** អ្នកក្លៀវក្លា, អ្នកអង់អាច,...អ្នកចម្បាំង។

ស្ងួរចិត្ត : ចិត្តក្លាហាន។

ស្ងួរបុរស : បុរសក្លៀវក្លា; អ្នកចម្បាំង។

ស្ងួរពាក្យ : សម្ដីក្លៀវក្លា, សម្ដីក្អេងក្អាង; សម្ដីអ្នកក្លៀវក្លា។

ស្ងួរវាក្យ : សម្ដីក្លៀវក្លា, សម្ដីក្អេងក្អាង; សម្ដីអ្នកក្លៀវក្លា។

ស្ងួរភាព : ភាពក្លៀវក្លា, សេចក្ដីអង់អាច។

ស្ងួរយុទ្ធ : ចម្បាំងខ្លាំងក្លា។

ស្ងួរសីហនាទ : សីហនាទដ៏ក្លៀវក្លា។

❖ **ព. ប្រ.** សព្ទបន្លឺឬកម្ទរឡើងដូចជាសម្រែកសីហៈក្លៀវក្លា : ព្រះរាជឱង្ការនូវព្រះបន្ទូលស្ងួរសីហនាទ សំបុត្រប្រកាសរបស់ក្សត្រទ្រង់រាជ្យចេញឱ្យសាធារណជនដឹងគ្រប់គ្នា។

ស្ងួរសេនា : សេនាចិត្តមុត...។

**សូរ្យ** *ន.* (**សំ. សូរ្យ៍**) ព្រះអាទិត្យ។ ប្រើរៀងភ្ជាប់ពីខាងដើមសព្ទដទៃបាន តាមការប្រកប (ដូច សុរិយ ដែរ) :

សូរ្យករ : រស្មីព្រះអាទិត្យ, សូរ្យការ, សូរ្យរស្មី។

សូរ្យការ : រស្មីព្រះអាទិត្យ, សូរ្យរស្មី, សូរ្យករ។

សូរ្យរស្មី : រស្មីព្រះអាទិត្យ, សូរ្យករ, សូរ្យការ។

សូរ្យកាល : ពេលថ្ងៃត្រង់។

សូរ្យគតិ : ដំណើរព្រះអាទិត្យ។

សូរ្យគោត្រ : គោត្រព្រះអាទិត្យ។

សូរ្យគ្រាស : ដំណើរដែលរាហូចាប់ដួងព្រះអាទិត្យឬដំណើរដែលរាហូបាំងដួងព្រះអាទិត្យ, សូរ្យគ្រាះ។

សូរ្យគ្រាះ : ដំណើរដែលរាហូចាប់ដួងព្រះអាទិត្យឬដំណើរដែលរាហូបាំងដួងព្រះអាទិត្យ, សូរ្យគ្រាស។

សូរ្យសែង : ពន្លឺព្រះអាទិត្យ...។

## អំពី សូន, សូន្យ

**សូន** *កិ.* ប្រមូលអ្វីៗដែលមានសាច់ទន់ជ្រាយឱ្យកើតជាដុំ, ជាគ្រាប់ឬជារូប :

- សូនគុលិកា
- សូនរូបក្រមួន
- សូនរូបម្សៅ។

**សូន្យ** *គុ.* (សំ.) ផេង, ទទេ, សោះទទេ, ឃែត :

សូន្យឈឹង : សូន្យឥតឮសូរឬដំណឹងអ្វីសោះ, ស្ងាត់សូន្យឈឹង។

សូន្យសុង : សូន្យគ្មានពន្លឺតិចតួច, ងងឹតសូន្យសុង។

សូន្យសោះ : ឃែតទទេ, ឥតអំពើ, ឥតប្រយោជន៍, សោះសូន្យ។

សោះសូន្យ : ឃែតទទេ, ឥតអំពើ, ឥតប្រយោជន៍, សូន្យសោះ។

បុរសសោះសូន្យ : បុរសឥតអំពើ, មនុស្សចោលម្សៀត (មោឃបុរស)...។

**សូន្យ** *ន.* ភាវៈទទេ; អាកាស; ពិន្ទុឬក្បៀល, និគ្គហិត (0) នេះ :

លេខ១ : សូន្យ១មុខ = ១០

លេខ២ : សូន្យ២មុខ = ១០០...។

**អំពី ស្ទួ, ស្ទួរ, ស្ទួត៏**

**ស្ទួ** *កិ.* ដើរលើស្ពួឬលើអ្វីៗដែលមានគ្រឿងតោងផង :

- ស្ទួស្ពួ
- ស្ទួស្ពានឫស្សី
- ស្ទួមែកឈើ។

ស្ទួព្រ័ត្រ : កាន់សំណុំកន្ទុយក្ងោកវាំដើរស្ទួលើព្រ័ត្រចងខ្វែងល្បែងស្ទួព្រ័ត្រ។

**ស្ទួរ** *កិ.* ពោលពាក្យឆ្ពោះទៅរកអ្នកដទៃឱ្យគេឆ្លើយតប, ឱ្យគេប្រាប់ :

- ស្ទួរដំណឹង។

សួរនាំ : សួរឱ្យណែនាំ។

សួរមាត់សួរពាក្យ : សួរបញ្ជាក់ឱ្យដឹងថាបាននិយាយមែនឬទេ?

- សួរសោក។

សួរសុខទុក្ខ : សួរឱ្យដឹងអំពីសុខទុក្ខ...។

**ស្ួគ៌** *ន.* (**សំ. ស្វគ៌**) ទេវលោក, លោកទិព្វ, ឋានទេវតា :

- ផ្លូវសួគ៌

- ទៅសួគ៌

- ឋានសួគ៌។

### អំពី ស្បៀ, ស្បៀរ

**ស្បៀ** *កិ.* បង់, លះ, លះបង់, ខូច :

ស្បៀកម្លាំង : បង់កម្លាំង។

ស្បៀប្រយោជន៍ : ខាតប្រយោជន៍, បង់ប្រយោជន៍។

ស្បៀធី (ស.) : អាប់ឱន, ទន់ថយ។

ស្បៀប្រៀប (ស.) : ចាញ់ប្រៀប; ថយថោក។

**ស្បៀរ** *កិ.* ឬ *កិ. វិ.* ដើរតាមក្បែរទីប្របេះឬទីផុតមានក្បែរជញ្ជាំង, ក្បែរមាត់ព្រែកជាដើម :

- សៀរតាមជញ្ជាំង

- ដើរសៀរតាមមាត់ស្ទឹង។

## អំពី សេ, សេរ

**សេ** *គុ.* *១.* ឬ *កុ.* សិញ, ស្អេក, ស្អេកស្អះ, ញើកណាស់ :

- ញើកសេ
- ដើរញាប់សេ។

**សេរ** *កុ.* ឬ *ន.* (**បា.** <**ស** "ខ្លួនឯង" + **ឆ្ន៍រ** "ប្រព្រឹត្តទៅ") ដែលមានសិទ្ធិលើខ្លួនឯង, ដែលធ្វើអ្វីបានតាមចិត្ត, ការប្រព្រឹត្តទៅតាមទំនើងខ្លួន, ការធ្វើអ្វីបានតាមអំពើចិត្ត, អំណាចលើខ្លួន :

សេរកថា : សម្ដីឥតក្រែង, សម្ដីឥតញញើត។

សេរជន : អ្នកដែលមានសិទ្ធិលើខ្លួន។

សេរប្រទេស : ប្រទេសឯករាជ្យដែលមានអំណាចលើខ្លួនឯង...។

## អំពី សំណុស, សំណុះ

**សំណុស** *ន.* អ្វីៗដែលសុស, អ្វីៗដែលអស់រសជាតិ :

- សំណុសឧស
- សំណុសឃ្មុំ។

**សំណុះ** *កុ.* ដែលចុះតាមទឹកស្រេក (ចំពោះតែមច្ឆជាតិ) :

ត្រីសំណុះ : ត្រីដែលចុះតាមទឹកហូរចេញពីទីផ្សេងចូលមកក្នុងទន្លេ, ព្រែក, ស្ទឹងក្នុងរដូវទឹកស្រេកឬខែរំហើយ (អ្នកស្រុកខ្លះហៅ ត្រីចំណុះ)។

## អំពី ស្គា, ស្គារ

**ស្គា** *ន.* ឈ្មោះស្មៅមានដើមរឹង, មានពីរប្រភេទគឺ ស្គាក្រអូប ស្គាមានឫស
ក្រអូបប្រើជាគ្រឿងអប់បាន, គេប្រើដាក់ត្រាំក្នុងប្រេងស្អិតប្រើលាបសក់,
ស្គាធំ ឬ ស្គាព្រៃ ស្គាដើមធំៗច្រើនដុះតាមវាលទំនាប។

**ស្គារ** *កិ.* ធ្វើមេថុនសេវនៈ (ចំពោះតែ ឧរគសត្វ ឬ ទីឃជាតិ) :

- ពស់ស្គារគ្នា។

## អំពី ស្គុស, ស្គុះ

**ស្គុស** *គុ.* សច្បាស់, សក្បុស, សសុទ្ធ :

- សស្គុស។

**ស្គុះ** *ន.* ឈ្មោះស្គន់មួយប្រភេទ ដើមសណ្ឋានជាជ្រុងៗ, ប្រើជាបន្លែ ឬជាអន្លក់បាន :

- អន្លក់ស្គុះ។

## អំពី ស្មេ, ស្មេរ

**ស្មេ** *គុ.* ល្អិតញ៊ើកស្មែក : ល្អិតស្មេ។

**ស្មេរ** *ន.* អ្នកសរសេរ (ស្មៀន) : កាលណោះព្រះយមពណ្ណវាយលើសលែងសព្វសាយស្ដេចទតព្រះនេត្រយល់ជាក់។ ស្ដេចបើកព្រះឱស្ឋប្រើអ្នកស្មេរមួយប្រត្យក្សដណ្ដឹងឱ្យជាក់ក្ដាត់ណា (សាស្ត្រាសុបិនកុមារ)។

ស្មៀនស្មេរ : (ព. សា.) ស្មៀនអ្នកសរសេរ, ស្មៀនធម្មតា។

## អំពី សម្រិត, សំរឹទ្ធ ឬ សំរិទ្ធិ

**សម្រិត** *កិ.* ធ្វើឱ្យស្អាត, ធ្វើឱ្យបរិសុទ្ធ; សិតទឹកឬផាត់ទឹកសម្រេងមិនឱ្យដោយកករជាដើម :

- សម្រិតទឹក។

❖ សម្រិតសម្រាំងផ្ចិតផ្ចង់ឱ្យស្អាត, សម្រិតសម្រាំងផ្ចិតផ្ចង់ឱ្យបរិសុទ្ធ :

- ធ្វើការសម្រិតសម្រាំង។

❖ រើសសម្រាំងយកតែល្អ :

- រើសសម្រិតសម្រាំងយកសុទ្ធតែល្អៗ។

❖ *គុ.* ដែលស្រិតរួចហើយ (ប្រើចំពោះតែអង្ករ) : អង្ករសម្រិត។

**សំរឹទ្ធ** *ន.* (**សំ. សំ + ឫទ្ធ**) សេចក្តីសម្រេច; សេចក្តីចម្រើន; ការលូតលាស់, ការដុះដាល; ផលសម្រេច។ ខ្មែរហៅលោហៈមួយប្រភេទកើតអំពីការលាយផ្សំលោហជាតិផ្សេងៗមានដែក, ស្ពាន់ជាដើម, សន្មតថាជារបស់ត្រជាក់ត្រជំនាំឱ្យសម្រេចប្រយោជន៍ផ្សេងៗ (ច្រើនសរសេរ សំរឹទ្ធិ ជាង) :

- ព្រះសំរឹទ្ធិ

- ផ្តិលសំរឹទ្ធិ (សរសេរជា សំឫទ្ធ ឬ សំឫទ្ធិ ក៏បាន)។ សំរឹទ្ធិ ឬ សំឫទ្ធិ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃក៏បាន, ដូចជា

សំរឹទ្ធិការ្យ : ការសម្រេច, កិច្ចការដែលសម្រេចប្រយោជន៍។

សំរឹទ្ធិជ័យ : ជ័យសម្រេច។

សំរឹទ្ធិជោគ : ជោគសម្រេចផលប្រយោជន៍។

សំរឹទ្ធិភាព : ភាពនៃសេចក្តីសម្រេច, ដំណើរសម្រេចប្រយោជន៍។

សំរឹទ្ធិស័ក : ស័កសម្រេច គឺស័ក១០នៃឆ្នាំដែលជាចុងបំផុតនៃស័កទាំង១០...។

## អំពី ស្រាស់, ស្រះ

**ស្រាស់** ***កិ.*** បិទដោយសម្រាស់, រាំងដោយសម្រាស់ :

- ស្រាស់ច្រក

- ស្រាស់របង។

❖ និយាយស្រាស់ឬនិយាយស្រាស់ផ្លូវ (ព. ប្រ.) និយាយរាំងមិនឱ្យជ្រៀតជ្រែកបាន, និយាយរាំងមិនឱ្យចាប់ដំណើរបាន។

## ពាក្យទំនឹមបុរាណ

☆ នៅស្រុកត្រូវស្រាស់បន្លាអារសាច់ជូនខ្លាទើបចូលព្រៃបាន : ត្រូវយកចិត្តទុកដាក់ផ្គាប់ផ្គុនឥស្សរជនដែលមានអំណាចលើខ្លួន ទើបបានសេចក្តីសុខស្រួល។

**ស្រះ** ***ន.*** ទីដក់ទឹកធំដែលកើតពីជីកឬកើតឯងក៏មាន (ដែលកើតឯងហៅជាតស្រះ ប៉ុន្តែខ្មែរច្រើនហៅ ត្រពាំង ទៅវិញ)។

ស្រះបោក្ខរណី : ស្រះមានឈូក។

ស្រះស្រង់ : ឈ្មោះស្រះបុរាណមួយធំល្វឹងល្វើយនៅខាងមុខប្រាសាទបន្ទាយក្តីក្នុងខេត្តសៀមរាប សម្រាប់ក្សត្រក្នុងសម័យមហានគរ ស្តេចចុះស្រង់

ក្រសាលមួយដងមួយកាល។

ស្រះស្រី : ស្រះមានសិរី, ស្រះមានស្រីសួស្ដី។

**អំពី ស្រុស, ស្រុះ**

**ស្រុស** ***កិ.*** ដាក់របស់ស្រស់ឆៅក្នុងទឹកកំពុងពុះឬក្នុងទឹកក្ដៅតែមួយរំពេចមិនឱ្យយូរហួសប្រមាណ :

- ស្រុសមាន់
- ស្រុសអន្លក់ស្ដៅ។

**ស្រុះ** ***កិ. ៖.*** ឬ ***គុ.*** ដែលព្រមព្រៀងគ្នាឥតទាស់ទាក់, ព្រមព្រើស, ដែលស្រវាស្រទេញព្រមគ្នា :

- ធ្វើការស្រុះគ្នា
- ស្រុះគ្នាដូចស្រមោច
- ពួកនុ៎ះស្រុះគ្នាណាស់។

ស្រុះដៃ : ដណ្ដើមដៃគ្នាឥតសំចៃកម្លាំង, ធ្វើការស្រុះដៃ។

ស្រុះស្រួល : យល់ព្រមជាមួយគ្នាឥតទទឹងទាស់...។

**អំពី ស្រែស, ស្រែះ ឬ ស្រេះ**

**ស្រែស** ***គុ.*** ស្រួយខ្លាំង, ស្រួយក្រៃពេក :

- ស្រួយស្រែស

សម្ដីស្រួយស្រែស : សម្ដីស្រួយច្បាស់លាស់ (សម្ដីរឹងតែពីរោះ)។

**ស្រែះ** ឬ **ស្រះ** *កិ.* ចាក់ចេសប្រទាក់ឆ្វាក់ញឹកជាក្រឡាល្អិតៗ :

- ស្រែះសំពត់ផ្ទុះ។

ជំពាក់ចាក់ស្រែះ : ជំពាក់ឆ្វាក់ដូចជាចាក់ចេសស្រែះ។

❖ ឈ្មោះអាវឬកន្សែងជាដើមដែលស្រែះជាក្រឡាល្អិតៗ :

- អាវស្រែះ

- កន្សែងស្រែះ។

❖ ឈ្មោះផ្សិតមួយប្រភេទមានស្នាប់ដូចជាចាក់ស្រែះ :

ផ្សិតស្រែះ : ជាផ្សិតពុលបរិភោគពុំបាន។

### អំពី សង់, សង្ឃ

**សង់** *កិ.* ប្រជុំគ្រឿងទព្វសម្ភារៈធ្វើឱ្យកើតបានជាលំនៅ :

- សង់ផ្ទះ

- សង់សាលា

- សង់រោង។

❖ ធ្វើស្ពាន : សង់ស្ពាន។

**សង្ឃ** *ន.* (**បា. សំ.**) ពួក; ប្រជុំ; បន; ហ្វូង។ តាមលទ្ធិពុទ្ធសាសនាសំដៅចំពោះពួកភិក្ខុតាំងពី៤រូបឡើងទៅ :

- ជំនុំសង្ឃ

- របស់សង្ឃ

- អាជ្ញាសង្ឃ

- សង្ឃព្រមព្រៀងគ្នា។

❖ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃក៏បាន, ដូចជា :

សង្ឃកតិកា : បញ្ញត្តិរបស់សង្ឃ។

សង្ឃកម្ម : ការរបស់សង្ឃដែលប្រជុំគ្នាធ្វើក្នុងសីមា។

សង្ឃករណីយកិច្ច : កិច្ចដែលសង្ឃត្រូវធ្វើ។ (មានការជួសជុលសេនាសនៈជាដើម)។

សង្ឃការី : អ្នកធ្វើការសង្ឃ; ខ្មែរហៅក្រុមអ្នករាជការក្នុងព្រះរាជវាំងមួយក្រុម មានមុខការខាងចាត់ការសង្ឃដែលទាក់ទងដោយកិច្ចមានព្រះរាជនិមន្តជាដើម។

សង្ឃកិច្ច : កិច្ចការផ្សេងៗរបស់សង្ឃ។

សង្ឃគតទាន : ទានដែលបង្អោនទៅចំពោះសង្ឃ គឺទានដែលទាយកប្រគេនចំពោះសង្ឃ។

សង្ឃគារវតា : សេចក្តីគោរពចំពោះសង្ឃ។

សង្ឃគុណ : គុណព្រះសង្ឃគឺវត្តប្រតិបត្តិឬសណ្តាប់ធ្នាប់ល្អវិសេសរបស់ព្រះអរិយសង្ឃ។

សង្ឃដីកា : ដីការបស់សង្ឃ; ដីការបស់ភិក្ខុដែលចេញជាផ្លូវរាជការ; សំបុត្រសម្រាប់សាមណេរក្នុងសម័យបច្ចុប្បន្ននេះកាន់ជាសម្គាល់ខ្លួន ទុកដូច

ជាសំបុត្រឆាយាសម្រាប់ភិក្ខុ។

សង្ឃត្ថេរ : ភិក្ខុដែលជាថេរៈក្នុងជំនុំសង្ឃ។

សង្ឃទាន : ទានដែលទាយកប្រគេនចំពោះសង្ឃ។

សង្ឃទាសៈ : បុរសដោយប្តេជ្ញាប្រគល់ខ្លួនជាអ្នកធ្វើការបម្រើសង្ឃ ហាក់ដូចជា ទាសៈ។

សង្ឃទាសី : ស្ត្រីដោយប្តេជ្ញាប្រគល់ខ្លួនជាអ្នកធ្វើការបម្រើសង្ឃ ហាក់ដូចជា ទាសី។

សង្ឃទូត : បម្រើរបស់សង្ឃ, តំណាងសង្ឃ។

សង្ឃនវក : ភិក្ខុថ្មីក្នុងសង្ឃគឺភិក្ខុដែលទើបនឹងបួសថ្មីក្នុងជំនុំសង្ឃ មួយពួកៗ។

សង្ឃនាយក : មហាថេរដែលជាអ្នកដឹកនាំសង្ឃគឺព្រះថេរៈធំដែលជា អ្នកត្រួតត្រាលើសង្ឃទូទៅក្នុងរដ្ឋមួយៗ។

សង្ឃបញ្ញា : ពាក្យបង្គាប់របស់សង្ឃ, ពាក្យផ្ដាំផ្ញើរបស់សង្ឃ។

សង្ឃបរិនាយក : ព្រះថេរៈដែលជាអ្នកត្រួតត្រាលើសង្ឃមួយពួកៗ សង្ឃ បរិភោគ។

សង្ឃប្បាមោក្ខ : ការប្រើប្រាស់របស់ក្នុងអំណាចសង្ឃ។

សង្ឃប្បាមោក្ខ : ព្រះថេរៈដែលជាប្រធានឬជាមេរបស់សង្ឃ, មេក្រុម ក្នុងវត្តមួយៗឬមេគណក្នុងខេត្តមួយៗ។

សង្ឃបិតា : ព្រះមហាថេរដែលទុកដូចជាបិតារបស់សង្ឃ។

សង្ឃបូជា : បូជាចំពោះសង្ឃ។

ព្រះសង្ឃប្រកាស : សេចក្ដីប្រកាសរបស់សម្ដេចព្រះសង្ឃនាយក។

ព្រះសង្ឃរាជប្រកាស : សេចក្ដីប្រកាសរបស់សម្ដេចព្រះសង្ឃរាជ។

សង្ឃប្រណាម : ការបង្អោនកាយវាចាចិត្តជ្រះថ្លាថ្វាយបង្គំសង្ឃគុណ។

សង្ឃទត្ត : ភត្តដែលទាយកប្រគេនចំពោះសង្ឃ។

សង្ឃភេទ : ការបំបែកសង្ឃ (ដោយពេញតាមលក្ខណៈវិន័យ)។

សង្ឃភេទក: : ភិក្ខុអ្នកបំបែកសង្ឃ។

សង្ឃមណ្ឌល : ជំនុំសង្ឃ; ភិក្ខុសង្ឃក្នុងប្រទេសឬដែននីមួយៗ។

សង្ឃមាមក: : អ្នករាប់អានសង្ឃថាជារបស់ខ្លួន (អ្នកប្ដេជ្ញាយកសង្ឃរតនៈជាសរណៈ); បើស្ត្រីជា សង្ឃមាមិកា។

សង្ឃរតនៈ : រតនៈគឺសង្ឃ, សង្ឃដែលទុកដូចជារតនៈ, សង្ឃរត្ន។

សង្ឃរត្ន : រតនៈគឺសង្ឃ, សង្ឃដែលទុកដូចជារតនៈ, សង្ឃរតនៈ។

សង្ឃរាជ : សម្ដេចសង្ឃ, សង្ឃរាជា។

សង្ឃរាជា : សម្ដេចសង្ឃ, សង្ឃរាជ។

សង្ឃរាជី : ការប្រេះឆារបស់សង្ឃ, ដំណើរមោះមៃរបស់សង្ឃ។

សង្ឃវង្ស : វង្សរបស់សង្ឃ។ ខ្មែរប្រើពាក្យនេះជាសមណ-សក្តិទីបាឡាត់ខាងស្តាំជាឋានានុក្រមសម្រាប់សម្តេចព្រះមហាសង្ឃរាជ : ព្រះបាឡាត់សង្ឃវង្សជាគូគ្នានឹងព្រះបាឡាត់សង្ឃរក្ខ (បាឡាត់ខាងឆ្វេង)។

សង្ឃសម្មតិ : សន្មតិរបស់សង្ឃ។

សង្ឃសាមគ្គី : សេចក្តីព្រមព្រៀងឬស្រុះស្រួលរបស់សង្ឃ; សេចក្តីព្រមព្រៀងរបស់ពួកក្រុម។

សង្ឃាណត្តិ : សេចក្តីបង្គាប់ឬពាក្យផ្តាំផ្ញើរបស់សង្ឃ។

សង្ឃានុស្សតិ : សេចក្តីរឭកដល់សង្ឃគុណ។

សង្ឃុបដ្ឋាក : អ្នកបម្រើឬក៏អ្នកទំនុកបម្រុងសង្ឃ; បើស្ត្រីជាសង្ឃុបដ្ឋាយិកា។

អំពី **សង្ហា, សង្ហារ**

**សង្ហា** *គុ.* ដែលរុងរឿង,មានរូបល្អអង់អាច,ឆើតឆាយ, ស្រស់, ស្រស់បស់:

- រូបឆោមសង្ហា
- មានសង្ហារាសី
- តែងខ្លួនយ៉ាងសង្ហា

សង្ហារាសី : រាសីរុងរឿង។

**សង្ហារ** *ន.* ការនាំយក, ការបំប្រួញ, សង្ខេប, ការរួបរួម, ការទម្លាយបង់, ការបំផ្លាញ, ការបំបាត់បង់, ការផ្តាច់ផ្តិល។

❖ *កិ.* សំដៅសេចក្ដីថា "បំផ្លាញ, បំបាត់បង់, ផ្ដាច់ផ្ដិល, សម្លាប់" :

សង្ហារជីវិត : ផ្ដាច់ផ្ដិលជីវិត។

**សង្ខារ** *ន.* (រ. ស.) ត្រាសម្រាប់ក្សត្រ, ត្រាផែនដី, ព្រះលញ្ឆករ :

- បោះព្រះសង្ហារ។

**អំពី សប់, សប្ត, សព, សព្វ**

**សប់** *កិ.* ស្រូបដោយស្នប់; ទាញរុញដៃស្នប់រឿយៗឱ្យមានខ្យល់ :

- សប់ទឹក
- សប់ស្នប់
- សប់គោមម៉ង់សុង
- សប់ម៉ាស៊ីនដាក់ទឹក។

**សប្ត** *ឞ. សំ.* (សំ.) ប្រាំពីរ (៧)។ សប្ដស័ក ស័កទី៧ (នៃឆ្នាំ) :

- ឆ្នាំអដ្ឋស័ក
- ឆ្នាំមមែសប្ដស័ក។

**សព** *ន.* (សំ. សវ) ខ្មោចស្រស់, រូបបុគ្គលស្លាប់, សាកខ្មោច :

- បូជាសព
- តម្កល់សព
- រំលាយសព
- ធ្វើបុណ្យសព

- បុណ្យលើកសព

- លើកសពសំស្ការ

ព្រះបរមសព : សពក្សត្រទ្រង់រាជ្យ។

សាកសព : រូបរាងបុគ្គលស្លាប់, សាកខ្មោច

លោកគ្រូព្រះសព : លោកគ្រូដែលទទួលអនិច្ចធម្មទៅហើយ...។

**សព្វ** ***ន.*** ឬ ***កិ. វិ.*** (បា.) ទាំងពួង, ទាំងអស់, ទាំងមូល,ទាំងស្រុង, ទាំងគ្រប់; គ្រប់, ទូ, ទូទៅ, រាល់ :

- សព្វគ្នា

- សព្វដង

- ចេះសព្វ

- ដឹងសព្វ

- សព្វឋាន

- សព្វកាល

- សព្វប្រការ

- ឃើញសព្វ

- សព្វមួយដង...។

សព្វជាតិ : រាប់ជាតិ។

- មិនបានការ

មនុស្សសព្វជាតិ  : មនុស្សមិនបានការ។

- ចោលម្សៀត

- អាសព្វជាតិ !

- អាចោលម្សៀត !

❖ សព្វសរពើ, សព្វសរពើឬសព្វសរពើអ្វីៗទាំងអស់។

❖ *គុ.* (បា.) ពាក្យនេះជា *គុ. ន.* ឬ *កិ.* ដូចពាក្យសព្វ១ដែរ, ប៉ុន្តែខ្មែរប្រើជា *គុ.* មានន័យថា "ពេញ, គាប់, ស្ម័គ្រស្មោះ, ត្រូវ, ឥតខុស, ឥតទាស់" :

- សព្វព្រះទ័យ

- ទ្រង់សព្វព្រះរាជហឫទ័យ។

❖ *ន. ស.* ឬ *កិ.* (បា.) ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, ទាំងគ្រប់; គ្រប់, គ្រប់យ៉ាង; ទូទៅ; រាល់។

សព្វគុណ : គុណសម្បត្តិគ្រប់យ៉ាង។

ថ្នាំសព្វគុណ : ថ្នាំដែលប្រើរំងាប់រោគបានច្រើនយ៉ាង។

សព្វញ្ញុតញ្ញាណ : ញាណឬប្រាជ្ញាដែលដឹងសព្វ (ញាណរបស់ព្រះសព្វញ្ញុពុទ្ធ)។

សព្វញ្ញុពុទ្ធ : លោកអ្នកត្រាស់ដឹងសព្វ (ព្រះសម្មាសម្ពុទ្ធ), ហៅត្រឹមតែ សព្វញ្ញូ ក៏បាន, ព្រះសព្វញ្ញូ, សព្វញ្ញូពុទ្ធ។

សព្វញ្ញុពុទ្ធ : លោកអ្នកត្រាស់ដឹងសព្វ (ព្រះសម្មាសម្ពុទ្ធ), ហៅត្រឹមតែ សព្វញ្ញូ ក៏បាន, ព្រះសព្វញ្ញូ, សព្វញ្ញុពុទ្ធ។

សព្វន្តរាយ : អន្តរាយទាំងពួង។

សព្វភ័យ : ភ័យទាំងគ្រប់។

សព្វសត្វ : សត្វទាំងពួង, ពួកសត្វទាំងអស់។

សព្វភោគ : សម្បត្តិគ្រប់យ៉ាង។

សព្វយុត្ត : ដែលប្រកបដោយលម្អគ្រប់យ៉ាង :

- ក្បាច់សព្វយុត្ត។

សព្វរុតញ្ញូ : អ្នកដឹងសំឡេងទាំងគ្រប់, អ្នកដែលចេះវិជ្ជាចំណាំសូរសំឡេងគ្រាន់តែឮរំពងសំឡេងមនុស្សក៏អាចដឹងថា មានបុណ្យឬឥតបុណ្យបាន។

សព្វរោគ : រោគគ្រប់យ៉ាង។

សព្វរោគវិនិមុត្ត : ដែលរួចផុតស្រលះចាករោគគ្រប់យ៉ាង, សព្វរោគវិមុត្ត។

សព្វរោគវិមុត្ត : ដែលរួចផុតស្រលះចាករោគគ្រប់យ៉ាង, សព្វរោគវិនិមុត្ត។

សព្វលាភ : លាភទាំងគ្រប់។ សព្វលោកលោកទាំងមូល, សកលលោក។

សព្វវចនៈ : ពាក្យទាំងពួង; វចនានុក្រម។

សព្វវចនាធិប្បាយ : សៀវភៅអធិប្បាយពាក្យដោយសព្វគ្រប់។

សព្វវិទូ : សព្វញ្ញូ។

សព្វវិនាស : វិនាសទាំងអស់, វិនាសទាំងស្រុង។

សព្វវេទី : អ្នកចេះចំណេះគ្រប់យ៉ាង។

សព្វសន្តិភាព : សេចក្ដីស្ងប់ឬសេចក្ដីសុខសាន្តទូទៅ។

សព្វសោក : សេចក្ដីស្ដាយស្រណោះទាំងគ្រប់...។

## អំពី សព្ទ, សាប់

**សព្ទ** *ន.* (សំ.) សូរ, សំឡេង, សំនៀងភាសា, ពាក្យ, សម្ដី, សម្រែក :

- ឆ្លុតសព្ទ
- សូរសព្ទ
- រៀនចាំសព្ទ។

**សាប់** *កិ.* កាប់ចិញ្ច្រាំស្រាលៗញាប់ៗឱ្យដាច់ជាចំណិតតូចៗស្ដើងៗ :

- សាប់ផ្លែល្ហុង
- សាប់ទំពាំង
- សាប់ត្រសក់។

## អំពី ស្និត, ស្និទ្ធ

**ស្និត** *ន.* ប្រជុំឬសំណុំផ្លែចេកដែលនៅជាប់នឹងស្ទងឬដែលពន្លះចេញពីស្ទង

មកមិនឱ្យដាច់ពីគ្នា :

- ស្អិតចេកឬចេកមួយស្អិត។

❖ *៣.* ក្រាសមួយប្រភេទមានធ្មេញទាំងពីរខាងល្អិតញឹកជិតសម្រាប់សិតឱ្យដោយថៃឬសិតសក់ស្លូតឱ្យរាបជិត។

**ស្និទ្ធ** *គុ.* ដែលជាទីស្រលាញ់, ជាទីពេញចិត្ត; ស្អិត; ខាប់; ឆ្វាញ់; ល្អ; ល្អិតល្អ។

❖ *កិ., កិ. វិ.* ឬ *គុ.* ស្រលាញ់ស៊ប់, ស្រលាញ់អស់ពីចិត្ត, ស៊ប់ចិត្តឥតរង្កៀស, ទុកចិត្តស៊ប់; ជិតដិត, ទំនុកទុកចិត្ត, ឥតរង្កៀស :

- មិត្រស្និទ្ធ
- បរិភោគស្និទ្ធ
- មនុស្សស្និទ្ធនឹងគ្នា
- ខ្ញុំមិនសូវស្និទ្ធនឹងគេទេ។

| | |
|---|---|
| ជិតស្លុង | : ឈើសាច់ស្និទ្ធ; ដៃជាងនេះបញ្ចុះដំណាប់ស្និទ្ធល្អណាស់។ |
| ស្និទ្ធជិត | : ជិតដិតណាស់; ជិតស្លុងឥតមានស្នាម។ |
| ស្និទ្ធស្នាល | : ស្និទ្ធជិតដិតនឹងគ្នា, ស្និទ្ធឥតរង្កៀស។ |
| ស្នេហ៍ស្និទ្ធ | : ជាទីស្រលាញ់ស៊ប់ជាប់ចិត្ត។ |
| ស្និទ្ធស្នេហា | : ស្នេហាស៊ប់ចិត្ត, ស្នេហ៍ស្និទ្ធ...។ |

## អំពី ស្ទេះ, ស្ទេរ

**ស្ទេះ** *កិ.* ឈប់បង្អង់ទុកដោយឡែក, ឈប់បង្អង់ទុកដោយអន្លើសិន :

- ត្រូវស្តេះសេចក្តីនេះទុកសិន។

**ស្លេស្ម** *ន.* ទឹករំអិលរាវឬខាប់ដែលចេញមកតាមបំពង់ក :

- ស្លេស្មរាវ

- ធ្លាក់ស្លេស្ម

- ស្លេស្មខាប់។

## អំពី **ហត្ថ, ហាត់**

**ហត្ថ** *ន.* (បា.) ដៃ,ប្រមោយដំរី, ផ្នួងសក់។ ឈ្មោះនក្សត្រឬផ្កាយឫក្សពួក ទី១៣ មានសណ្ឋានស្រដៀងនឹងដៃ។ ខ្នាតរង្វាស់ប្រវែង២ចំអាមឬប្រវែង

កន្លះល្វូកគឺប្រវែងពីត្រឹមចុងដៃដល់ចុងម្រាមដៃកណ្តាល :

- ប្រវែងមួយហត្ថមួយចំអាម។

ហត្ថក្រពុំ : ខ្នាតរង្វាស់ប្រវែងមួយគត់។

ហត្ថខ្នាត : រង្វាស់ប្រវែងមួយហត្ថដែលជាខ្នាតសម្រាប់ជាងឈើក្នុង សម័យបុរាណហៅ វឌ្ឍកីហត្ថឧហត្ថមជ្ឈិមបុរស ក៏បាន។

❖ បើរៀងភ្ជាប់ពីដើមសព្ទដូចជា :

ហត្ថកម្ម : ដែលត្រូវធ្វើដោយដៃ, ការរបស់ជាង, ជំនាង, ហត្ថកិច្ចការ។

ហត្ថកិច្ចការ : ដែលត្រូវធ្វើដោយដៃ, ការរបស់ជាង, ជំនាង, ហត្ថកម្ម។

ហត្ថមូល : ថ្លៃបំណាច់ដៃ, រង្វាន់ស្នាដៃ។

ហត្ថកោសល្យ : ការឈ្លាសដោយដៃ, ហត្ថសល្ល, ការប៉ិនប្រសប់ខាងធ្វើកិច្ចការផ្សេងៗដោយដៃ មានការគូសវាសឬកាត់ដេរខោអាវជាដើម។

ហត្ថកោសល្ល : ការឈ្លាសដោយដៃ, ហត្ថកោសល្យ, ការប៉ិនប្រសប់ខាងធ្វើកិច្ចការផ្សេងៗដោយដៃ មានការគូសវាសឬកាត់ដេរខោអាវជាដើម។

ហត្ថគត : ដែលដល់ដៃ, ដែលនៅក្នុងកណ្ដាប់ដៃ; អ្វីៗដែលនៅក្នុងកណ្ដាប់ដៃ។

ហត្ថពល : កម្លាំងដៃ។

ទោសហត្ថច្ឆេទ : ទោសកាត់ដៃ។

ហត្ថច្ឆេទ : កាត់ដៃ, ការកាត់ដៃ។

ហត្ថលេខា : លាយដៃថ្នាំងដៃ។ សម័យបច្ចុប្បន្ននេះប្រើសំដៅការចុះនាមដោយដៃខ្លួនឯង។

ហត្ថសូត្រ : អំបោះចំណងដៃ (ចងក្នុងវេលា អាវាហមង្គល ជាដើម)។

ហត្ថហារីយ៍ : ដែលល្មមចាប់កាន់ដោយដៃយកទៅមកបាន :

- របស់នេះជាហត្ថហារីយ៍។

ហត្ថាភរណៈ : គ្រឿងប្រដាប់សម្រាប់តាក់តែងដៃមានចិញ្ចៀន, ហត្ថលង្ការ...។

**ហាត់** ***កិ.*** ធ្វើឱ្យជំនាញ, រៀនឱ្យស្ទាត់, ហ្វឹក :

- ហាត់គុន

- ហាត់ភ្លេង

- ហាត់សរសេរ។

ហាត់ប្រាណ : ហាត់ខ្លួនឱ្យថ្នឹក, បង្ហឹកខ្លួន; ហាត់ឱ្យយឺតសរសៃក្នុងខ្លួនជាដើម។

ល្បែងហាត់ប្រាណ : ល្បែងដែលនាំឱ្យយឺតសរសៃ, ឱ្យស្រួលមានកម្លាំងច្រើន, ឱ្យថ្នឹកក្នុងការលើកទម្ងន់ជាដើម, ល្បែងបុរាណយ៉ាងដូចទាញព្រ័ត, លោតអន្ទាក់, ទាត់សីជាដើម; ល្បែងសម័យឥឡូវដូចយ៉ាងហាត់ពត់ខ្លួន, ទាត់បាល់, វាយកូនឃ្លី, ហាត់លោតតោងជាដើម។ មានបែបបទផ្សេងៗឱ្យហាត់ប្រាណ...។

**អំពី ហា, ហារ**

**ហា** *កិ.* របើកហើយច្រហាឡើង, ធ្វើឱ្យរបើកឡើង, បើកមាត់ច្រហាឡើង :

- ហាមាត់។

❖ *គុ.* ដែលរបើកហើបឡើង, ដែលប្រេះហើបច្រហ :

- លៀសហាលថ្ងៃហា

- ផ្លែសំរោងទុំប្រេះហា។

ហាទៅត្រង់ណាចេះតែកើត : ការនិយាយត្រង់ណាចេះតែកើតការទាំងអស់។

ហាមាត់មិនរួច : ហើបមាត់ហាស្ដីមិនរួច ឬហើបមាត់ស្ដីមិនកើតព្រោះទើសទាល់។

ហាហៅ : ស្រែកហៅ។

**ពាក្យកាព្យ**

អ្នកមានពូជផៅ ឃើញភ្ញៀវហាហៅ ថៅរ៉ៅរាក់ទាក់
ចរចាស្មោះស្មើ អើពើដោយស្ម័គ្រ ហៅលោកហៅអ្នក
តាមការប្រាស្រ័យ។

❖ *ប. សំ.* (ស.) ប្រាំ (៥) :

- ចោរហារយ ចោរប្រាំរយ (មានប្រើខ្លះតែក្នុងសាស្ត្របុរាណ)។

**ហារ** *ន.* (បា. សំ.) ការនាំយកអ្វីៗទៅ, អ្វីដែលល្មមយកទៅបានខ្សែជាគ្រឿងប្រដាប់ក, កង-ក។

❖ *កិ.* ចែក, បែងជាចំណែក, រកឱ្យឃើញជាចំណែក (ពាក្យប្រើក្នុងក្បួនទព្វន្ត) ហារលេខ។

- លេខហារ

- លេខចែក។

**អំពី ហៀ, ហៀរ**

**ហៀ** *គុ.* ស្តើងណាស់, ស្តើងហៀ, សម្ដីហៀ, ស្តើងសើកប៉ប្រើក។

**ហៀរ** *កិ.* កំពប់ហូរចេញព្រោះពេញខ្លាំងហួសប្រមាណ, ព្រោះខ្ពុរឡើងឬព្រោះធ្លាក់រអិលជ្រុលចុះមក :

- សំបោរហៀរ
- ទឹកឆ្នោតហៀរពីបំពង់
- ទឹកបបរពុះហៀរពីមាត់ឆ្នាំង។

❖ ប្រើជា *គុ.* ក៏បាន :

ទឹកហៀរត្លី : ទឹកច្រើនពេកហៀរលើភ្លឺ។

❖ ដែលច្រើនពេកចង្អៀតអង្គុយឬឈរមិនអស់គ្នា :

- សម្បូណ៌គរគោក
- ហៀរហូរឬហូរហៀរ
- មនុស្សច្រើនហៀរសាលា។

### អំពី ហោ, ហោរ

**ហោ** *កិ.* (**ស.**) "ខ្ទប់" ខ្ទប់ដោយក្រដាសជាកញ្ចប់ខ្ពស់ច្រឡោឬជារាងបួនជ្រុង :

- ហោស្ករស។

❖ ហោសម្រាប់រុំសពឥស្សរជនមានក្សត្រទ្រង់រាជជាដើម :

- ហោព្រះបរមសព
- ហោព្រះសព (ប្រើតាមថ្នាក់ឱ្យស្សរជន)។

**ហោ** *ន.* (**ស.**) "កញ្ចប់" កញ្ចប់ដែលខ្ទប់ជារាងច្រឡោឬជារាងបួនជ្រុង :

- ឈើគូសមួយហោ

- បារីថ្នាំខ្មែរមួយហោ។

❖ ចំនួនអំបោះ២០ជុំ (ក្នុងមួយជុំ១០ប៉ោយក្នុង១ប៉ោយ៧កម្រងក្នុង១កម្រង៨០សរសៃ) :

- អំបោះមួយហោ។

❖ *ឥ.* ដែលមានសាច់ប៉ោងឬជ្រួញខ្លះដោយអន្លើមិនរាបស្មើ (ចំពោះតែវត្ថុមានសាច់ទន់យ៉ាងដូចសំពត់ឬក្រដាសជាដើមដែលដេរឬបត់, ខ្ចប់ជាជាន់) :

- ដេរប្រយ័ត្នកុំឱ្យហោ !

- សង្ហាដីឡើងសាច់ហោមួយផ្ទាំង។

❖ *ឥ.* (ចិ.) ល្អ; ត្រូវ :

- ធ្វើយ៉ាងហ្នឹងមិនហោទេ !

❖ *ន.* (សៈ) មន្ទីរ។ ហោគ្រឿងមន្ទីរទុកគ្រឿងទ្រង់សម្រាប់ព្រះរាជាទ្រង់សោយព្រះក្រយាស្ងោយ (ធ្វើក្នុងព្រះបរមរាជវាំង)។

ហោណ៍ង : ផ្ទះសម្រាប់អង្គុយឬដេករំហើយសម្រាកកាយឬសម្រាប់ទទួលភ្ញៀវ, ហោណាំង។

ហោណាំង : ផ្ទះសម្រាប់អង្គុយឬដេករំហើយ សម្រាកកាយឬសម្រាប់ទទួលភ្ញៀវ, ហោណ៍ង។

ហោត្រ័យ : មន្ទីរតម្កល់គម្ពីរព្រះត្រៃបិដកឬតម្កល់គម្ពីរផ្សេងៗផងក៏បាន; ធម្មមន្ទីរ, ហោត្រៃ។

ហោត្រៃ : មន្ទីរតម្កល់គម្ពីរព្រះត្រៃបិដកឬតម្កល់គម្ពីរផ្សេងៗផងក៏បាន; ធម្មមន្ទីរ, ហោត្រ័យ។

ហោព្រះ : មន្ទីរតម្កល់សុទ្ធតែព្រះពុទ្ធរូបច្រើនព្រះអង្គ (ធ្វើតែក្នុងទីវត្តនិងក្នុងព្រះបរមរាជវាំង)។

ហោព្រះអដ្ឋិ : មន្ទីរតម្កល់ព្រះអដ្ឋនៃក្សត្រទ្រង់រាជ្យនិងព្រះអដ្ឋិនៃក្សត្រីទាំងឡាយ (ធ្វើក្នុងព្រះបរមរាជវាំង)...។

**ហោរ** *ន.* (ពាក្យឃ្លាតក្លាយមកពី **សំ. ហោរា**) អ្នកចេះហោរាសាស្ត្រឬអ្នកចេះតារាសាស្ត្រ, ហិណ្ឋិក :

- ក្បួនហោរ
- ទំនាយហោរ។

## ពាក្យទំនីមបុរាណ

☆ ទូតនៅហោរ ចោរនៅជាង : ធម្មតាហោរច្រើនភូតកុហកផ្សំខ្លះ, ធម្មតាជាងមាសប្រាក់ច្រើនតែលបកៃកិបយកមាសប្រាក់ ដែលគេយកមកជួលឱ្យធ្វើគ្រឿងមាសប្រាក់ខ្លះ (តែបើតាមពិតមិនដែលសុទ្ធតែដូច្នេះទាំងអស់គ្នាទេ)។

ហោរាសាស្ត្រ : ក្បួនហោរ; វិជ្ជាហោរ, តារាសាស្ត្រឬជោតិសាស្ត្រ។

ហោរាចារ្យ : អ្នកស្ទាត់ជំនាញខាងហោរាសាស្ត្រ, ជោតិកាចារ្យ, គ្រូហោរ, ហិណ្ឋិកាចារ្យ។

**ពាក្យកាព្យ**

| | | |
|---|---|---|
| ពួកហោរព្យាករ | ថាបុត្របវរ | កបដោយលក្ខណា |
| នៅជាគ្រហស្ថ | នឹងបានឡើងជា | ចក្រពត្រា- |
| | ធិរាជអង្គឯក។ | |
| បើទ្រង់ព្រះផ្នួស | នឹងបានឡើងហួស | ដល់ធម៌ដ៏ប្លែក |
| គឺជាព្រះពុទ្ធ | វិសុទ្ធក្រៃពេក | ជាសាស្តាឯក |
| | តែមួយក្នុងលោក។ | |

**អំពី អក, អក៍**

**អក** *ក.* ចាប់ចំណីអាហារក្រៀម, ផង់ឬភេសជ្ជៈស្ងួតផង់ជាដើមពេញទូក ដៃហាមាត់ធំងើយពម :

- អកថ្នាំផង់
- អកប្រអួល
- អកអំបុក។

❖ *ន.* អជ្ឈបាតកសត្តមួយប្រភេទសម្បុរខ្លួនខ្មៅស្រអាប់ មាឧធំកន្ទុលបន្តិចជាងកុកខ្មៅ, ឆាបចាប់មច្ឆជាតិជាចំណី; កាលណាព្រាត់គូឬព្រាត់កូន ស្រែកយំគ្រលួចសង្រេងសង្រៃ ហើរផ្សៀលឆ្ងាត់ខ្ពស់ៗទាបៗ ប្រះប្រាណគួរ

ឱ្យស្រវេះស្រវោចអាណោចអាធម្មហៅ **អគតាមស្នូរវាយ**។ គេតែងនិយាយប្រៀបកើតទុក្ខធំយំបោកខ្លួនឬយំប្រះប្រាណដូចជាអក។

**ពាក្យកាព្យ**

សត្វអកជាសត្វមានចិត្តស្មោះ អាឡោះអាល័យហួសទំនង
នៅពេលដែលព្រាត់បាត់គូគ្រង ទោះព្រាត់រំលងកាលយូរថ្ងៃ។
ស្រែកយំរង្គុំមិនស្ងួវស្រាក ក្រៀមក្រំលំបាកពន់ពេកក្រៃ
ជួនកាលបោកខ្លួនឱ្យក្សិណក្ស័យ សង្រេងសង្រៃដល់ស្គាំងស្គម។
មនុស្សខ្លះកើតទុក្ខដូចជាអក ច្រើនខកខូចចិត្តដល់ខ្លួនទ្រម
ទោះគេពន្យល់ក៏ពុំព្រម រញ៉ៃមត្រាតែមានជំងឺ។

❖ ប្រដាប់ធ្វើដោយលោហជាតិផ្សេងៗឬធ្វើដោយប្រាក់, មាសជាដើមមានរាងច្រឡូឬមានសណ្ឋានដូចបំពង់តូច មានមេមានគម្របសម្រាប់ដាក់កំបោរបៀកម្លូ :

- អកកំបោរ
- កំបោរកន្លះអក
- អកកំបោរប្រាក់
- អកកំបោរលង់ហិន។

**អករ៍** *ន.* (**បា. អ** < **ន** “មិន, ពុំ, ឥត” + **ករ** “ធ្វើ”) អ្នកមិនធ្វើការអ្វីពាក្យសម្រាប់ហៅស្ត្រីមានអាយុច្រើន ដែលព្រះអង្គម្ចាស់ជីវិត ទ្រង់ព្រះមេត្តា

ប្រោសតាំងឱ្យមានយសធំជាងយាយ, ចាស់ទុំទាំងពួង ប៉ុន្តែឥតនឿយ ដោយធ្វើការអ្វីទេ គ្រាន់តែចូលក្រាបបង្គំគាល់តាមពេលកំណត់ ក្នុងព្រះពិធីទាំងពួងម្តងៗ, ក្រៅពីវេលានោះគ្រាន់តែនាំក្សត្រី ឬ ចៅចមក្នុងព្រះបរមរាជវាំងទៅមកដោយកិច្ចណា១ម្តងៗប៉ុណ្ណោះ។ អករ៍នេះរមែងជ្រើសរើសយកព្រះស្នំចាស់ៗក្នុងរជ្ជកាលមុនៗមកឱ្យធ្វើ ព្រោះជាអ្នកដឹងបែបបទទំនៀមទម្លាប់ច្រើន។ ព្រះបាទហរិរក្សរាមាឥស្សរាធិបតី (ព្រះបរមកោដ្ឋ) ទ្រង់មេត្តាប្រោសតាំងស្ត្រីទីអករ៍៩នាក់, ទីយាយ១២នាក់, ទីចាស់៤នាក់, ទីទុំ៤នាក់, រួម២៩នាក់។ អករ៍៩នាក់នោះតាងជាទីលោកព្រះ១, ទីអ្នកព្រះ៤, ទីអ្នក៤គឺទី១លោកព្រះអករ៍ចមក្សត្រី (ជាអធិបតី), ២អ្នកព្រះអករ៍មង្គលក្សត្រី ៣ព្រះអករ៍ជាទីឧត្តម, ៤អ្នកព្រះអករ៍ធីតាធីភិរម្យ, ៥អ្នកព្រះអករ៍បទុមវស្សា, ៦អ្នកអករ៍រាជានុពង្ស, ៧អ្នកអករ៍រាជាវង្សឧត្តលា, ៨អ្នកអករ៍ឯកអគ្គកញ្ញា, ៩អ្នកអករ៍សុតាជាតី។ យាយទាំង១២នាក់នេះតាំងជាទីលោកអ្នកយាយ៤, ទីអ្នកយាយ៤, ទីយាយ៤, គឺ១លោកអ្នកយាយស្រីពិលាស, ២លោកអ្នកយាយឱភាសស្ងួនសក្តិ, ៣លោកអ្នកយាយនារីអនគ្ឃ, ៤លោកអ្នកយាយវរលក្ខណ៍អនេក; ៥អ្នកយាយទេពកោមល, ៦អ្នកយាយកុសលភិសេក, ៧អ្នកយាយបវរអតិរេក, អ្នកយាយ៤នាក់ គឺ១ចាស់អមច្ចា, ២ចាស់បរិវារក្សត្រ, ៣ចាស់ជាបរិស័ទ, ចាស់ចាត់បុរី។ ទីទុំ៤នាក់គឺ ១ទុំទទួលផ្គង់, ២ទុំប្រុងប្រក្រតី, ៣ទុំគាប់ភក្តី, ៤ទុំខ្មីបម្រើ។ ហៅដោយរួបរួម

ទាំងបួនពួកថា អករ៍, យាយ, ចាស់, ទុំ។

## ពាក្យកាព្យ

អករ៍យាយចាស់ទុំ ដែលព្រះបរម- កោដ្ឋក្សត្រក្សាន្ត
ទ្រង់ប្រោសប្រទាន ងារទាំងប៉ុន្មាន ដើម្បីឱ្យបាន
ទុក្ខជាព្រះកេរ្តិ៍។

ក្នុងកាលខាងមុខ គួរជនចាំទុក ឱ្យបានឋិតថេរ
កុំឱ្យបាត់សូន្យ គួរកូនចៅខ្មែរ កុំហ៊ានបង្វែរ
បំបែកបំបាក់។

## អំពី អង្គ, អង់

**អង្គ** *ន.* (បា.) អវយវៈ, រូប, តួរូប, កាយ, រាងកាយ, ខ្លួន, ខ្លួនប្រាណ; ភាគ, ចំណែកនៃរាងកាយ; ប្រភេទ; សេចក្តីដែលចែកឱ្យឃើញចំនួន; រូបសេចក្តី; លក្ខណៈ; ការណ៍, ដើមហេតុ។

អង្គកាយ : រូបកាយ

រូបអង្គ : ខ្លួនប្រាណ, តួអង្គ។

អង្គការបែបផែន : របៀបរៀបចំកិច្ចការដែលរដ្ឋឬក្រុមរាជការណាមួយបង្កើតឡើងដើម្បីប្រព្រឹត្តទៅកាន់សេចក្តីចម្រើន។ ទីកន្លែងចាត់ការធំៗ :

- អង្គការរបស់រដ្ឋ
- អង្គការនយោបាយ។

អង្គការសហប្រជាជាតិ : អង្គការរបស់ជាតិរួមគ្នា, អង្គការអន្តរជាតិឬជាតិនានាដែលស្ម័គ្រចិត្ត ប្រតិបត្តិការតាមច្បាប់រដ្ឋធម្មនុញ្ញសហប្រជាជាតិដើម្បីរក្សាការពារនូវសន្តិភាពនៃពិភពលោក។

អង្គកំណើត : អវយវៈសម្រាប់បង្កើតកូន (អង្គជាត) អង្គជៈ។

អង្គជៈ : បុត្រ (កូនប្រុស)។

អង្គជា : បុត្រី (កូនស្រី)។

អង្គជាត : លិង្គ, យោនី (ខ្លាសបុរស ឬ ខ្លាសស្ត្រី)។

អង្គណា : ទីលានសម្រាប់លេងល្បែង, ទីលានកីឡា; ទីទួល។

អង្គទូត : អង្គការផ្នែកខាងទូត, មុខក្រសួងទូតព្រមទាំងបុគ្គលិកនៃស្ថានទូតផង។

អង្គប្បញ្ញត្តិ : បញ្ញត្តិដោយមានហេតុជាគ្រឿងកំណត់; ហេតុឬលក្ខណៈដែលលើកឡើងជាគ្រឿងកំណត់បាន។

អង្គបទ : មេរៀនដែលប្រែពីភាសាខ្លួនទៅជាភាសាដទៃ។

អង្គបរាមាស : ការស្ទាបអង្អែលខ្លួនប្រាណ។

អង្គបរិច្ចាគ : ការលះបង់ខ្លួនឱ្យទៅស្នូម។

អង្គប្បច្ចង្គ : អវយវៈតូចធំ, ភាគតូចធំនៃរាងកាយ, អង្គប្បច្ចង្គា។

អង្គប្បច្ចង្គា : អវយវៈតូចធំ, ភាគតូចធំនៃរាងកាយ, អង្គប្បច្ចង្គ។

អង្គប្រហារ : ការប្រហាររូបកាយ (មានវាយកាប់ជាដើម)។

អង្គវិកល : វិកលអវយវៈ (មានឆែបមាត់, មានខ្វាក់ភ្នែកជាដើម)។

អង្គពិការ : ពិការអវយវៈ (មានបាក់ដៃ, មានបាក់ជើងជាដើម)។

អង្គភាព : ភាពរូបកាយ។

អង្គភេទ : ដំណើរផ្សេងរូបកាយគ្នា, ដំណើររូបកាយខុសគ្នា, ការបែកឬបាក់អវយវៈ។

អង្គមង្គានុសារី : ខ្យល់ដែលបក់ទូទៅតាមអវយវៈតូចធំឱ្យកម្រើកកាយកម្រើកវាចាបាន។

អង្គមន្ត្រី : មន្ត្រីថ្នាក់ខ្ពស់ដែលជាអ្នកប្រឹក្សាការផែនដីជាមួយនឹងព្រះរាជា។

អង្គមន្ត្រីសភា : សភានៃពួកអង្គមន្ត្រី។

អង្គរក្ខ : ដំណើរឬលំនាំងាកបែរ, កម្រើក, លើកដាក់នៃអវយវៈ, អង្គវិក្ខេម (មានវាសដៃ, វាសជើងជាដើម)។

អង្គវិក្ខេម : ដំណើរឬលំនាំងាកបែរ, កម្រើក, លើកដាក់នៃអវយវៈ, អង្គវិក្ខេមន៍ (មានវាសដៃ, វាសជើងជាដើម)។

អង្គវិក្ខេមន៍ : ដំណើរឬលំនាំងាកបែរ, កម្រើក, លើកដាក់នៃអវយវៈ, អង្គរក្ខ (មានវាសដៃ, វាសជើងជាដើម)។

អង្គវិជ្ជា : វិជ្ជាទាយលក្ខណៈរូបកាយ។

អង្គវិទ្យា : វិទ្យាទាយលក្ខណៈរូបកាយ, អង្គវិជ្ជា។

អង្គសីល : ប្រភេទប្រាប់ដំណើរដាច់សីលឬប្រភេទប្រាប់ដំណើរជាប់សីលដូចជា ប្បាណាតិបាត មានអង្គ៥ :

១- សត្វមានជីវិត

២- ដឹងថាសត្វមានជីវិត

៣- គិតនឹងសម្លាប់

៤- តាំងព្យាយាមនឹងសម្លាប់

៥- សត្វស្លាប់ដោយព្យាយាមនោះ...ៗ

អង្គាវយវ: : អវយវៈទាំងអស់នៃរាងកាយ។

❖ *ន.* អង្គជាតព្រះឥសូរ ឬ សិវលិង្គ។ ខ្មែរសម័យបុរាណហៅថ្មដែលធ្វើជារូបសិវលិង្គថា **អង្គ** ហៅកាត់ខ្លីមកពីពាក្យ (អង្គជាត), ហៅរូប **ឧមាយោនិ** (និមិត្តនាងឧមា) ថា បំពង់ខ្ចី; ទឹកដែលស្រោចលើថ្មទាំងពីរប្រភេទនោះ (សូមពរស្រីសួស្ដី...) ហៅថា ទឹកអង្គបំពង់ខ្ចី។ ក្នុងសម័យខ្មែរកំពុងកាន់សាសនាព្រាហ្មណ៍ពេញទី, ឥស្សរជននិងប្រជាជនច្រើនជីកស្រះសាងអង្គទុកជាទីគោរពក្នុងទីប្រជុំជនមួយៗ សឹងនៅមានរូបនិងឈ្មោះជាប់មកដល់សព្វថ្ងៃនេះច្រើនអន្លើដូចយ៉ាង អង្គតាសោម, អង្គតារាជ, អង្គស្នួល ជាដើម។

❖ *ន.* ឬ *មុ. ស.* នាក់; រូប; ខ្លួន; ទ្រង់; លោក (សម្រាប់ប្រើចំពោះតែព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធ, ព្រះពុទ្ធរូប, ព្រះអរហន្ត, ក្សត្រ, ទេវតាសក្តិធំ, បព្វជិតថ្នាក់ខ្ពស់, ...) :

- ក្សត្រពីរព្រះអង្គ

- មហាថេរច្រើនអង្គ

- ព្រះពុទ្ធគ្រប់ព្រះអង្គ

- លុះព្រះអង្គទ្រង់ជ្រាបហេតុនោះហើយ...។

❖ សម្រាប់ហៅព្រះរាជបុត្រ, ព្រះរាជនត្តាថា ព្រះអង្គម្ចាស់, អ្នកអង្គម្ចាស់។ សម្រាប់ហៅជនដែលជាប់វង្សក្សត្រឆ្ងាយមកហើយថាព្រះអង្គ, ព្រះវង្ស។ ព្រះអង្គ, លោក, ខ្លួនលោក។

ព្រះអង្គឯង : ខ្លួនឯង។

ល្អអស់អង្គ : ល្អអស់ទាំងខ្លួន, មានរូបល្អឥតខ្ចោះត្រង់ណា...។

**អង់** *កិ.* រង់, រង់ចាំ, ឈប់ចាំ :

- អង់ចាំ

- អង់មួយស្របក់។

## អំពី **អត្ត, អត្ថ, អាត់**

**អត្ត** *ន.* (បា.) ខ្លួន; ចិត្ត, អាត្មន, អាត្មា។ អត្តកិលមថានុយោគការប្រកបព្យាយាមតឹងហួសពេកឱ្យនឿយលំបាកខ្លួន (ជាវត្តប្រតិបត្តិរបស់ និគ្រន្ថតិរ្ថិយ ពួកខ្លះ)។

អត្តឃាត : ការសម្លាប់ខ្លួនឯង (ហៅ អត្តឃាតកម្ម ឬ អត្តវិនិបាតកម្ម "ការធ្វើឱ្យឃ្លាតចាកជីវិត" ក៏បាន)។

អត្តទត្ថ : ប្រយោជន៍ចំពោះខ្លួន, ប្រយោជន៍ផ្ទាល់ខ្លួន។

អត្តទត្ថភាព : ភាពនៃប្រយោជន៍ចំពោះខ្លួន, ការដែលគិតតែប្រយោជន៍ខ្លួនឯង។

អត្តទន្ត : អ្នកទូន្មានខ្លួន, អ្នកបង្ហឹកចិត្ត។ បើស្ត្រីជា អត្តទន្តី។

អត្តបរិហារ : ការរក្សាខ្លួន, ការថែទាំខ្លួន។

អត្តពលកម្ម : អំពើឬកិច្ចការដែលកើតអំពីកម្លាំងខ្លួន។

អត្តព្យាបាល : ការរក្សាខ្លួន, ការថែទាំខ្លួន, អត្តបរិហារ។

អត្តភាព : ភាវៈរបស់ខ្លួន; ខ្លួនទាំងមូល; ធម្មតារបស់ខ្លួន; និស្ស័យនៃខ្លួន; អាត្មាភាព។

អត្តលេខ : លេខប្រចាំខ្លួន, លេខសម្គាល់ខ្លួននៃទាហានជាដើម។

អត្តសន្និយាតន៍ : ការប្រគល់ខ្លួនឱ្យនៅក្នុងអំណាចគេ។

អត្តសញ្ញាណ : គ្រឿងសម្គាល់ខ្លួន; សញ្ញាដែលអាចសម្គាល់បានជាពត៌មាននោះៗពិតជាមានឬត្រូវចំលើរូបបុគ្គលឬវត្ថុណាមួយ, មនុស្សនិងសត្វតែងមានអត្តសញ្ញាណផ្ទាល់ខ្លួនជាដរាប។

អត្តសញ្ញាណបណ្ណ : លិខិតជាផ្លូវការនៃអត្តសញ្ញាណ, សំបុត្រជាគ្រឿងសម្គាល់ខ្លួនមនុស្សសត្វនិងវត្ថុផ្សេងៗ, អត្តសញ្ញាបត្រ។

អត្តសញ្ញាណបត្រ : លិខិតជាផ្លូវការនៃអត្តសញ្ញាណ, សំបុត្រជាគ្រឿងសម្គាល់ខ្លួនមនុស្សសត្វនិងវត្ថុផ្សេងៗ, អត្តសញ្ញាណបណ្ណ។

អត្តសម្មាបណិធិ : ការតាំងខ្លួនឱ្យល្អ គឺការតាំងចិត្តប្រតិបត្តិតាមធម៌ តាមច្បាប់។

អត្តហេតុ : ព្រោះហេតុខ្លួន; ការឃើញប្រយោជន៍ផ្ទាល់ខ្លួន។

អត្តាធិន : អ្នកដែលមានអំណាចលើខ្លួនឯង (សេរី ឬ ស្វែរិន, ស្វែរី), អត្តាធីនភាព សេរីភាព ឬ ស្វែរីភាព។

អត្តានុវាទភ័យ : ភ័យអំពីការតិះដៀលខ្លួនឯង គឺការខ្លាចក្រែងខ្លួនធ្វើអំពើអាក្រក់ហើយនឹងកើតក្តៅក្រហាយនឹកស្តាយក្រោយស្រឡេតចិត្ត។

អត្តានិបាល : ការរក្សាខ្លួន, ការថែទាំខ្លួន, អត្តបរិហារ។

អត្តុក្កង្សនកថា : សម្តីលើកខ្លួន។

អត្តុក្កង្សនតាព : ភាវៈលើកតម្កើងខ្លួន, ការលើកតម្កើងខ្លួន...។

**អត្ថ ន.** (បា.) ប្រយោជន៍; សេចក្តី; រឿង, ហេតុ, ការណ៍; ដំណើរ; ផល; ផលប្រយោជន៍; បំណង; សេចក្តីប្រាថ្នា; ទ្រព្យ, សម្បត្តិ; របស់; វត្ថុ; អីវ៉ាន់; កិច្ច, កិច្ចការ; ធុរៈ, រវល់; ...។

ស្គាល់អត្ថ : ស្គាល់ដំណើរ; ស្គាល់សេចក្តី។

រៀនអត្ថ : រៀនសេចក្តីអធិប្បាយ, រៀនអដ្ឋកថា។

ចេះអត្ថប្រែ : ចេះប្រែស្រាយអធិប្បាយសេចក្តីចេញពីបាលីបាន។

❖ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃក៏បាន, ដូចជា :

អត្ថកាម : អ្នកមានបំណងល្អ; អ្នកចង់ឱ្យមានសេចក្តីចម្រើន; អ្នកផ្គងដំណើរការណ៍សំដៅផលប្រយោជន៍។

អត្ថកោវិទ : អ្នកឈ្លាសក្នុងអត្ថបទ, អ្នកជំនាញក្នុងអត្ថបទ។

អត្ថគវេសនា : ការស្វែងរកប្រយោជន៍, ការស្វែងរកទ្រព្យ។

អត្ថគ្រឹះ : ផ្ទះដាក់អីវ៉ាន់, ឃ្លាំងដាក់របស់។

អត្ថចរិយា : ការប្រព្រឹត្តឱ្យកើតផលប្រយោជន៍, ការប្រព្រឹត្តឱ្យកើតសេចក្តីចម្រើន។

អត្ថចិន្តា : គំនិតគិតឱ្យមានប្រយោជន៍ឬឱ្យមានសេចក្តីចម្រើន, គំនិតគិតឱ្យកើតទ្រព្យ។

អត្ថញ្ញុតា : ការស្គាល់ផលរបស់ហេតុ។

អត្ថញ្ញូ : អ្នកស្គាល់ផលរបស់ហេតុ។

អត្ថទាន : ការឱ្យប្រយោជន៍។

អត្ថទោស : ដំណើរខុសសេចក្តី, ដំណើរខុសបំណង។

អត្ថន័យ : ការពន្យល់សេចក្តី, រាយរាប់ពីលក្ខណៈនៃវត្ថុផ្សេងៗ :

- តាមអត្ថន័យនេះ

- ពាក្យនេះមានអត្ថន័យយ៉ាងណា?។

អត្ថប្បដិរូប : សេចក្តីប្រៀបធៀប, ន័យប្រដូច គឺន័យរបស់ពាក្យដែលបង្វិលបញ្ចៀសពីន័យត្រង់ៗដូចជាពាក្យថា “ស៊ី” តាម អត្ថានុរូប គឺ

ន័យត្រង់ៗទៅតាមដំណើរដើមថា "បរិភោគភោជនាហារ" តែបើតាមគេយកទៅប្រើជាសេចក្ដីប្រៀបប្រដូចវិញ ប្រែរជាមានន័យផ្សេងពីន័យដើម, ដូចជា :

ស៊ីគ្នា : សមគ្នា, ត្រូវគ្នា។

ស៊ីថ្លៃ : យកតម្លៃច្រើន។

ស៊ីថោក : យកតម្លៃថោក; យ៉ាងនេះជាដើមហៅថា អត្ថប្បដិរូប។

អត្ថបតី : ម្ចាស់ទ្រព្យ; អ្នកមានទ្រព្យច្រើន។

អត្ថបទ : សេចក្ដីអធិប្បាយនៃរឿងអ្វីនីមួយៗ; សេចក្ដីជាខ្លឹមសាររបស់អ្នកនិពន្ធ; សេចក្ដីដែលចុះផ្សាយក្នុងសារព័ត៌មានផ្សេងៗ។

អត្ថប្រយោជន៍ : អ្វីៗដែលមានផលប្រយោជន៍, ប្រយោជន៍ដែលគួរប្រាថ្នា, ប្រយោជន៍ដែលគួរចង់បាន។

អត្ថប្បយោគ : ការចាយទ្រព្យឱ្យកើតប្រយោជន៍, អត្ថប្រយោគ។

អត្ថប្រយោគ : ការចាយទ្រព្យឱ្យកើតប្រយោជន៍, អត្ថប្បយោគ។

អត្ថរស : ដំណើរសេចក្ដី។

អត្ថរូប : រូបសេចក្ដី។

អត្ថលាភ : ការបានប្រយោជន៍; ការបានទ្រព្យ។

អត្ថវណ្ណនា : ការពន្យល់សេចក្ដី, អដ្ឋកថា។

អត្ថវិជ្ជា : វិជ្ជាសម្រាប់រៀនឱ្យស្គាល់កិច្ចការចិញ្ចឹមជីវិតនិងការគ្រប់គ្រងស្រុកទេស។

អត្ថសាស្ត្រ : សាស្ត្រសម្រាប់រៀនឱ្យស្គាល់កិច្ចការចិញ្ចឹមជីវិតនិងការគ្រប់គ្រងស្រុកទេស។

អត្ថវិញ្ញាបនី : សម្ដីបញ្ជាក់សេចក្ដី។

អត្ថវិនាស : ការខូចប្រយោជន៍។

អត្ថវិនិច្ឆ័យ : ការកាត់សេចក្ដី។

អត្ថវិបត្តិ : វិបត្តិសេចក្ដី, វិបត្តិប្រយោជន៍។

អត្ថវិប័ទ : វិបត្តិសេចក្ដី, វិបត្តិប្រយោជន៍, អត្ថវិបត្តិ។

អត្ថសង្គហ: : ការប្រមូលឬការសន្សំទ្រព្យសម្បត្តិ, អត្ថសង្គ្រោះ, អត្ថសន្និច្ច័យ។

អត្ថសង្គ្រោះ : ការប្រមូលឬការសន្សំទ្រព្យសម្បត្តិ, អត្ថសង្គហ:, អត្ថសន្និច្ច័យ។

អត្ថសន្និច្ច័យ : ការប្រមូលឬការសន្សំទ្រព្យសម្បត្តិ, អត្ថសង្គហ:, អត្ថសង្គ្រោះ។

អត្ថសម្ពន្ធ : ការត្រូវបានទ្រព្យសម្បាច់។

អត្ថសម្ពន្ធិន : អ្នកដែលត្រូវបានទ្រព្យសម្បាច់ (បើស្ត្រីជា អត្ថសម្ពន្ធិនី), អត្ថសម្ពន្ធី។

អត្ថសម្ពន្ធី : អ្នកដែលត្រូវបានទ្រព្យសម្បាច់ (បើស្ត្រីជា អត្ថសម្ពន្ធិនី), អត្ថសម្ពន្ធិន។

អត្ថសាធក : អ្នកសម្រេចសេចក្ដី; អ្នកដែលបានសម្រេចផលប្រយោជន៍ (បោះជាស្ត្រីជា អត្ថសាធិកា)។

អត្ថសាស្ត្រ : សាស្ត្រសម្រាប់រៀនឱ្យស្គាល់កិច្ចការចិញ្ចឹមជីវិតនិងការគ្រប់គ្រងស្រុកទេស, អត្ថវិជ្ជា។

អត្ថសិរី : សិរីជាទ្រព្យ; ទ្រព្យមានសិរី, ការមានទ្រព្យស្ដុកស្ដម្ភ។

អត្ថាធិប្បាយ : អធិប្បាយសេចក្ដី។

អត្ថានុរូប : ន័យរបស់ពាក្យដែលសមទៅតាមសេចក្ដី, ន័យរបស់ពាក្យត្រង់ៗ, ន័យដែលមិនបង្វិលបញ្ចៀសខុសឃ្លាតចាកសេចក្ដីដើម គឺពាក្យដែលមិនប្រើជាសេចក្ដីប្រៀបប្រដូច។

**អាត់** *គុ.* តូច; ក្រិស។

សេកអាត់ : ឈ្មោះសត្វមួយប្រភេទមាឌតូច ចំពុះខ្មៅអ្នកស្រុកខ្លះហៅ សេកក្រិច, ខ្លះហៅ សេកក្រិស "សេកតូច"។

ស្វាយអាត់ : ឈ្មោះស្វាយមួយប្រភេទផ្លែតូចៗជាងស្វាយទាំងពួង។

❖ *ន.* មេក្រមីដែលកើតនៅក្រោមស្បែកមនុស្ស, មានទឹករងៃថ្លាៗ (បន្តិចបន្តួច) នាំបណ្ដាលឱ្យរមាស់, ច្រើនកើតត្រង់ចង្វែកដៃ, បាទដៃនិងម្រាមដៃជាងកន្លែងឯទៀត, កើតអាត់, អាត់ស៊ីដៃ។

**អាត់មានពីរយ៉ាង :**

១- អាត់ដែលមានតែទឹករងៃថ្លា

២- អាត់ខ្មែរដែលមានមេដោះយកបាន : ដោះអាត់ឱ្យគ្នាបន្តិច !

## អំពី **អ័ព្ទ** ឬ **អ័ព្ឋ** ឬក៏ **អ័ត្រ, អាប់**

**អ័ព្ទ** *ន.* (**សំ. អព្ទ, អភ្រ; បា. អព្ឋ**) ពពក, ពពកខាប់ឬពពកក្រាស់; មេឃ, មេឃមីរ, ផ្សែងខាប់ដែលបណ្តាលកើតឡើងអំពីអាកាសធាតុងងឹតដាសជិតចាក់ភ្នែកពុំយល់ឬមើលឃើញអ្វីស្ទុងៗមិនប្រាកដ  ខ្មែរប្រើសំដៅប្រើពាក្យប្រៀបផងក៏បាន :

- ធូលីហុយអ័ព្ទ
- អួអ័ព្ទ
- អ័ព្ទអួ
- អ័ព្ទអន់
- អន់អ័ព្ទ...។

**អាប់** *គុ.* ដែលអន់ឬតិចពន្លឺ, អន់សម្បុរ, ថយលម្អ, មិនរុងរឿង; ថោក, ថោកថយ; សាបរលាប, ទន់ទាប, ខ្សោយ, ទន់ខ្សោយ; តិច, តិចផ្លូវដឹង, យឺតក្រយល់; ដែលឥតគេរាប់។

អាប់គំនិត : ខ្សោយគំនិត, គំនិតខ្សោយ, គំនិតតិច។

អាប់ជាតិ : ថោកជាតិ។

អាប់ប្រាជ្ញា : ខ្សោយប្រាជ្ញា, ប្រាជ្ញាខ្សោយ, ប្រាជ្ញាតិច, ប្រាជ្ញាអន់។

អាប់មុខ : ដែលមានមុខអាប់អន់, ដែលមិនរីកមុខ។

អាប់រស្មី : អន់ថយរស្មី, អន់រស្មី។

អាប់អន់ : ទន់ខ្សោយថយលម្អ។

អាប់អួ : សុកមម៉ុកពុំស្អាតពុំស្រលះ, កខ្វិកកខ្វក់,គគ្រិចគគ្រក់។

អាប់ឱន : ដែលអាប់អន់, ទន់ទាប,ខ្វះលម្អ,ខ្វះស្រីស្ដី; ថយថោក។

❖ *កិ.* ផាត់ប្រាក់កាក់ឱ្យទៅអ្នកទិញ, ផាត់លុយកាក់ឱ្យទៅអ្នកទិញ :

- ខ្ញុំទិញទំនអ្នក២៥សេន ខ្ញុំឱ្យលុយអ្នក១រៀលទៅអ្នកត្រូវអាប់៧៥សេនឱ្យខ្ញុំ (ពាក្យសាមញ្ញទំនើបថ្មី)។

**អំពី អា, អារ**

**អា** *ឝ្ញ. ស.* ជាពាក្យទាបឥតគួរសមនិយាយចំពោះទៅរកមនុស្សប្រុសដែលជាក្មេងតូចឬមនុស្សតូចទាប, មនុស្សស្មើភាពដែលស្និទ្ធស្នាលនឹងគ្នាណាស់, ភឿន, ក្លើ ឬហៅ ចោរ, មនុស្សទោស, សត្វតិរច្ឆាន... : អាណា?, អានេះ, អានុះ, អាហ្នឹង, អានោះ, អាឯង; អាណុប, អានាង, អាតូច, អាច្រមក់, អាវ៉ា, អាង៉ែត; អាសម្លាញ់, អាភឿន, អាក្លើ; អាចោរ, អាចោរកំណាច; អាផ្លុកសេះអ្នកមានល្បឿនស្មើគ្នានឹងអាខ្មៅសេះខ្ញុំដែរ។

❖ សុន្ទរោវាទ : យុវជនទាំងឡាយអើយ! គួរអ្នកកុំហៅគ្នា "អា", គួរហៅគ្នាអ្នកថា "បង" ថា "ប្អូន" (តាមបងប្អូន) ឬហៅថា "នាយ" គឺ "នាយនេះ, នាយនោះ" ដូច្នេះវិញទើបឈ្មោះថា អ្នករាល់គ្នាជាមនុស្សសុភាពត្រូវតាមក្រឹត្យដែលអ្នកបានរៀនមក !។

អាមឹង : ពាក្យទ្រគោះថា អា ហើយថែម មឹង ទៀតផង :

- ធ្វើជាអ្នកសុភាពត្រូវកុំប្រើសម្ដី អាមឹង ឬ ឯងមឹង រកគ្នា។

**អា** ! *ឧ.* ជា *ន.* ពាក្យលាន់មាត់ ដោយការងឿងឆ្ងល់, ដោយការភ័ន្តច្រឡំ; ដោយការភ័យស្លន់, ដោយភ្ញាក់ឬដោយបានយល់សេចក្ដីជាក់ច្បាស់; ដោយអំណរជាដើម :

- អា ! អ្វីហ្នឹ ! ដូច្នោះទេឬ?

- អា ! អញ្ជើញមក !...។

❖ ចេញសំឡេងខ្ពស់ថា អ៉ា ក៏មាន :

- អ៉ា ! មិនទាន់ទៅទេឬ?

**អារ** *កិ.* កាត់, បំបែក, ច្រៀក, កាត់ផ្ដាច់, តម្រឹមដោយរណារ :

- អាររំលំ

- អារឈើ

- អារផ្ដាច់

- អារបំបែក

- អារច្រៀក

- អារតម្រឹម។

❖ កាត់ពន្លះ, លឿយ, កាត់ដោយរណារ :

- អារពន្លះស្បែក។

អារកាត់ (ព. ប្រ.) : សម្រេចសេចក្ដីដោយកាត់ប្រមាណ, ដោយស្មាន :

- ខ្ញុំមិនបានអារកាត់សេចក្ដីនេះទេ។

❖ *ន.* ដែលកាត់ផ្ដាច់ប្រយោជន៍ដែលខ្លួនត្រូវបាន គឺប្រយោជន៍ខាងការបន្តពូជពង្សនិងមាតាបិតុដ្ឋាន។ អារនេះជាពាក្យហៅគូស្វាមីភរិយាដែលឥតកូនគឺដែលមិនធ្លាប់មានកូនសោះ, ហៅថា ស្រីអារ, ប្រុសអារ, អារទាំងពីរនាក់ប្ដីប្រពន្ធ, មេគោអារ (ស្រីអារ ព. ខ្ព. ថា វញ្ឈា)។

ទ្រព្យអារទ្រព្យផុត : ទ្រព្យសម្បត្តិរបស់គូស្វាមីភរិយាទាំងពីរនាក់ដែលអារឥតកូន ហើយអ្នកទាំងពីរនោះ ឥតបានប្រគល់ឱ្យដល់ញាតិឬដល់បុគ្គលណាមួយសោះឡើយ, លុះឥតអំពីអ្នកទាំងពីរនោះទៅ, ទ្រព្យសម្បត្តិនោះត្រូវបានជាប្រយោជន៍នៃព្រះរាជទ្រព្យ ឬជាប្រយោជន៍ឃ្លាំងរបស់រាជការគឺត្រូវទុកជាសម្បត្តិរបស់ប្រទេសជាតិតទៅ :

- ស្រែនិងចម្ការនោះជាទ្រព្យអារទ្រព្យផុតនៃតា “ក” យាយ “ច”។

ពាក្យជាគុណបទនេះ កាលពីដើមអ្នកសរសេរតាមទម្លាប់រៀងខ្លួនគឺសរសេរជា អា ក៏មាន ជា អារ ក៏មាន, តាំងពីនេះតទៅគួរសរសេរជា អារ ចុះ ព្រោះមានអត្ថន័យសមជាង អា។

## អំពី **អាចារ, អាចារ្យ**

**អាចារ** *ន.* ការប្រព្រឹត្ត, ចរិយា; ឫក, ឫកពា, មារយាទ, ឫកមារយាទ; បែបបទសណ្ដាប់ធ្នាប់ :

- មានអាចារល្អ

- មានអាចារពុំគួរសម។

អាចារកុសល : អ្នកដែលឈ្លាសក្នុងការសិក្សាមារយាទឱ្យល្អ។

អាចារកោសល្យ : ភាពជាអ្នកឈ្លាសក្នុងការរក្សាមារយាទឱ្យល្អ។

អាចារវិន័យ : ច្បាប់សម្រាប់រក្សាមារយាទឱ្យល្អ, ឱ្យត្រឹមត្រូវ។

អាចារវិបត្តិ : វិបត្តិមារយាទ គឺខូចមារយាទ, ខូចឫក។

អាចារសម្បត្តិ : ការបរិបូណ៌ដោយមារយាទល្អ, អាចារសម្ប័ទ, អាចារសម្បទា។

អាចារសម្ប័ទ : ការបរិបូណ៌ដោយមារយាទល្អ, អាចារសម្បត្តិ, អាចារសម្បទា។

អាចារសម្បទា : ការបរិបូណ៌ដោយមារយាទល្អ, អាចារសម្បត្តិ, អាចារសម្ប័ទ។

អាចារសាស្ត្រ : ក្បួននិយាយអំពីអាចារ, វិធីសាស្ត្រដែលថែងអំពីចរិយា, ឫកពា, សណ្ដាប់ធ្នាប់របស់មនុស្ស។

**អាចារ្យ** *ន.* អ្នកប្រដៅឬអ្នកហាត់មារយាទ, អ្នកប្រព្រឹត្តល្អ, អ្នកកាន់ត្រឹមត្រូវ, អ្នកត្រឹមត្រូវ, អ្នកដែលសិស្សត្រូវគោរព, អ្នកធ្វើប្រយោជន៍ដល់សិស្ស, អ្នកបង្រៀនចំណេះគេ, គ្រូបង្រៀន :

- សិស្សមានវិជ្ជាដោយសារអាចារ្យខំប្រឹងបង្រៀន។

## ក្នុងគម្ពីរពុទ្ធសាសនាថា អាចារ្យមានច្រើនប្រភេទ

១- បព្វជ្ជាចារ្យ : អាចារ្យបំបួស គឺភិក្ខុអ្នកបំបួសកុលបុត្រញត្តិចតុត្ថកម្មវាចាឱ្យសាមណេរ។

២- ឧបសម្បទាចារ្យ : ភិក្ខុអ្នកសូត្រញត្តិចតុត្ថកម្មវាចាឱ្យសាមណេរបានឧបសម្បទាជាភិក្ខុភាព។

៣- ឧទ្ទេសាចារ្យ : អាចារ្យបង្រៀនបាលី។

៤- និស្សយាចារ្យ : អាចារ្យអ្នកឱ្យនិស្ស័យ គឺភិក្ខុទទួលភារៈឱ្យសិស្សទៅអាស្រ័យនឹងខ្លួនផង។

៥- ធម្មាចារ្យ : អ្នកបង្រៀនធម៌អាថ៌ឬបង្រៀនចំណេះវិជ្ជា សិល្បសាស្ត្រផ្សេងៗ (ហៅ វិជ្ជាចារ្យ ឬ វិទ្យាចារ្យ, សិប្បាចារ្យ ឬ សិល្បាចារ្យ ជាដើម តាមរូបសព្ទចំណេះដែលបង្រៀនក៏បាន)។

☞ ពាក្យអាចារ្យនេះខ្មែរហៅបានច្រើនយ៉ាងទៀតតាមដំណើរដែលគួរប្រកបហៅដូចជា :

អាចារ្យកម្មដ្ឋាន : គ្រូបង្រៀនកម្មដ្ឋាន។

អាចារ្យគាន់ពេលា : អ្នកដែលពិនិត្យហើយកំណត់ឫក្សពារពេលាល្អឱ្យគូស្វាមីភរិយាក្នុងមង្គលការអាពាហ៍ពិពាហ៍។

អាចារ្យកោរជុក : អ្នកដែលពិនិត្យមើលឫក្សពារកំណត់វេលាឱ្យគេក្នុងមង្គលកោរជុក, អាចារ្យកោរសក់។

អាចារ្យការសក់: អ្នកដែលពិនិត្យមើលឫក្សពារកំណត់វេលាឱ្យគេក្នុងមង្គលកោរជុក, អាចារ្យកោរជុក។

អាចារ្យធាតុ : អ្នកដែលបញ្ចុះធាតុ។

អាចារ្យឃោត : អាចារ្យនៃប្រមុខនៃភិក្ខុទាំងបួននាក់ក្នុងពិធីធ្វើឈាបនកិច្ចឬអាចារ្យនាំមុខសព។

អាចារ្យវត្ត : ឧបាសកដែលជាប្រមុខក្នុងការចាត់ចែងកិច្ចការផ្សេងៗក្នុងវត្ត (ក្នុងសម័យបុរាណ អារាមិក ឬ អារាមិកជន, សម័យបច្ចុប្បន្នលុះត្រាតែមន្ត្រីអ្នករាជការរដ្ឋបាលក្នុងនាទីយល់ព្រមផង ទើបធ្វើជាអាចារ្យវត្តបាន...)។

## អំពី **អាស, អាសន៍**

**អាស** *គុ.* ដែលឥតបើគិតពីកេរខ្មាស, ដែលមានចិត្តនិងឫកពា-រហើ-រហាយឥតអៀនខ្មាស, ចើក (ប្រើចំពោះតែស្ត្រី) :

- ស្រីអាស

បញ្ឆោរលើកអាស : ជេរបញ្ឆោរចំអាសចំអ្វូងរំលើកបើកកកាយតាមតែរួចពីមាត់, ជេរលើកអាស។

ជេរលើកអាស : ជេរបញ្ឆោរចំអាសចំអ្វូងរំលើកបើកកកាយតាមតែរួចពីមាត់, បញ្ឆោរលើកអាស។

អាសតាងខ្មើយ : ទទួលរ៉ាប់រងជួយឈ្នោះប្រកែកឬជជែកវែកដៃដោយខុសមុខខុសទំនង (ដូចជាស្រីអាសទទួលភារៈជាជំនួសខ្មើយ); និយាយថា

ចើកតាងខ្មែរ ក៏បាន។

**អាសន៍ ៤.** ទីអង្គុយ, កន្លែងអង្គុយ, កម្រាលឬប្រដាប់សម្រាប់អង្គុយ :

- អង្គុយលើអាសន៍ស្មើគ្នា
- អង្គុយលើអាសនៈស្មើគ្នា។

**ពាក្យកាព្យ**

កុំអាលច្រឡាស អង្គុយដើមអាសន៍ រួចបែរជាថយ
ចុះមកចុងអាសន៍ ឱ្យខ្មាសស្ដាយក្រោយ ប្រយ័ត្នកុំឆ្គោយ
ឱ្យខ្សោយភាពខ្លួន។

ក្រាលអាសនៈ : ក្រាលជាអាសនៈសម្រាប់អង្គុយ។

ដើមអាសន៍ : អាសនៈខាងដើមបំផុត, ភិក្ខុដើមអាសន៍ភិក្ខុអង្គុយដើមគេបំផុត។

អាសនន្តរិក : លំដាប់នៃទីអង្គុយឬទីអង្គុយលំដាប់គ្នា។

អាសនសាលា : សាលាឬរោងសម្រាប់អង្គុយ។

អាសនានុក្រម : លំដាប់លំដោយនៃអាសនៈ, លំដាប់ថ្នាក់នៃទីអង្គុយតាមអាសនានុក្រម។

ទីចាសនៈ : អាសនៈទាប។

សមានាសនៈ : អាសនៈស្មើគ្នា។

សមាសនិក : អ្នកដែលមានទីអង្គុយស្មើគ្នា។

សមាសនិកា : ស្ត្រីដែលមានទីអង្គុយស្មើគ្នា។

ឧច្ចាសន៍ : អាសនៈខ្ពស់។ ច្រើនប្រើជា *កិ. ១.* ឬ *ន.* សំដៅសេចក្ដីថា "ខ្ពស់, ខ្ពស់ជាង" :

- ទីឧច្ចាសន៍
- កន្លែងឧច្ចាសន៍
- ឯងកុំឧច្ចាសន៍ជាងចាស់ទុំ !
- នាងកុំឧច្ចាសន៍ជាងចាស់ទុំ !។

**អំពី អាចិ, អាទិ**

**អាចិ** *ន.* អត្ថ។

ធម៌អាចិ : ធម៌និងអត្ថគឺ បាលី និង អដ្ឋកថា ឬ បាលី ព្រមទាំងសេចក្ដីអធិប្បាយ :

- ចេះធម៌អាចិ
- រៀនធម៌អាចិ។

**អាទិ** *ន.* ដើម, ខាងដើម; ដើមដំបូង; ការផ្ដួចផ្ដើមមុន :

ជាអាទិ : ជាដើម។

ដើមអាទិ : ដើមដំបូង, ដើមចម។

នាំអាទិ : នាំផ្ដើមមុន; ផ្ដួចផ្ដើមសេចក្ដីមុន; ផ្ដើមហេតុឬផ្ដើមដំណើរមុន។

❖ ខ្មែរប្រើពាក្យនេះជា *កិ.* ផងក៏មានខ្លះ "ផ្ដើម, ផ្ដួចផ្ដើម, តាំងផ្ដើមមុន; រៀបរាប់មុន" :

- កាលគេអាទិ

- កាលគេផ្ដួចផ្ដើម។

**កំណាព្យ**

ធម្មតាអ្នកជាជាតិ    កាលគេអាទិឱ្យគិតគូរ
កុំខ្ជិលដេកទទូរ    ដល់ថ្ងៃរះពេញពន្លឺ។

អាទិកម្មិក : បុគ្គលដើមបញ្ញត្តិ។

អាទិករ : អ្នកផ្ដើមធ្វើមុន។ អ្នកសាងលោកគឺ ព្រះព្រហ្ម ឬ ព្រះវិស្ណុ។

អាទិកល្យាណ : លម្អឬពីរោះខាងដើម; ដែលមានលម្អឬពីរោះខាងដើម។

អាទិការណ៍ : ហេតុដើមឬដើមហេតុ, ហេតុដំបូង, មូលហេតុ, ប្រថមហេតុ។

អាទិកាល : កាលខាងដើម, កាលពីដើម។

អាទិគុ : អក្សរគរុនៅខាងដើម; ដែលមានអក្សរ **គរុ** នៅខាងដើម។

អាទិគុរុ : គ្រូដើម; សេនាបតីទីមួយ។

អាទិទេព : ទេវតាខាងដើម, ទេវតាមុនបង្អស់។

☞ ពាក្យសន្មតហៅ **អនុត្តរបុគ្គល** ដែលគេជឿសម្គាល់ទុកថាជាព្រះ ជាអ្នកបង្កើតទឹកដីនិងសត្វលោក, ជាអ្នករក្សាការពារនិងឱ្យសុខទុក្ខដល់

មនុស្សលោក :

- ព្រះអាទិទេព

- ព្រះពុទ្ធមិនមែនជាអាទិទេពទេ ព្រះអង្គជាមនុស្សអស្ចារ្យ។

អាទិបរិយោសាន : ខាងដើមនិងខាងចុង។

អាទិបុរស : បុព្វបុរស; វិស្ណុ។

អាទិប្រយោគ : ប្រយោគដើម, ប្រយោគមុន។

អាទិពុទ្ធ : ព្រះពុទ្ធដើមគឺ **ព្រះពុទ្ធ** ដែលបានបង្កើតព្រះពុទ្ធនិងព្រះពោធិសត្វគ្រប់ព្រះអង្គ :

អាទិព្រហ្មចរិយធម៌ : ព្រហ្មចរិយធម៌ដែលត្រូវសិក្សាមុនដំបូង; បាតិមោក្ខសំវរសីល។

អាទិព្រហ្មចរិយសិក្ខា : ការសិក្សាអាទិព្រហ្មចរិយធម៌; សិក្ខាបទក្នុងបាតិមោក្ខ។

អាទិមជ្ឈិម : ខាងដើមនិងកណ្ដាល។

អាទិមធ្យម : ខាងដើមនិងកណ្ដាល, អាទិមជ្ឈិម។

អាទិរាជ : ព្រះរាជាដើមវង្សនៃក្សត្រក្នុងលោក, ប្រថមក្សត្រ។

អាទិលោប : ការលុបអក្សរដើមនៃពាក្យមួយៗចេញ, ដូចជា :

ឧបាសក ➤ បាសក

ឧបាសិកា ➤ បាសិកា

ខ្យាធ្យាយ ➤ ឮាធ្យាយ ជាដើម។

អាទិវាចា : សម្ដីដើម។

អាទិវាទ : សម្ដីដើម, អាទិវាចា។

អាទិសង្កេត : អក្សរសង្ខេបដែលដកយកតែពាក្យតែមួយតួៗខាងដើមពីក្នុងពាក្យមួយៗមកប្រើដូចជា :

*កិ.* : កិរិយាសព្ទ

*គុ.* : គុណសព្ទ

*ន.* : នាមសព្ទ

*ព. ស.* : ពុទ្ធសករាជ

*ពុ. ស.* : ពុទ្ធសករាជ

*ភ. ព.* : ភ្នំពេញ...។

អាទិសព្ទ : សព្ទដែលជាដើម គឺសព្ទមានចំនួនច្រើនប៉ុន្តែយកតែចំនួនប៉ុណ្ណោះៗមកប្រាប់ថា "មាននេះមួយជាដើម", ដូចជាសង្ហារិមទ្រព្យមានចាន, ឆ្នាំង, កែវ, គោម ជាដើម (ចាន, ឆ្នាំ, គោម ជាដើមជាអាទិសព្ទ)។

អាទិសម្ភាស : ការនិយាយរាក់ទាក់ទៅរកមុនឬមករកមុន, សម្ដីរួសរកមុន, អាទិសម្ភាសន៍...។

អាទិសម្ភាសន៍ : ការនិយាយរាក់ទាក់ទៅរកមុនឬមករកមុន, សម្ដីរួសរកមុន, អាទិសម្ភាស...។

# គន្ថនិទ្ទេស


១- **ជួន-ណាត** វចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ ព.ស. ២៥១១-២៥១២ គ.ស. ១៩៦៧-១៩៦៨, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

២- **លី-ថៃលី** វចនានុក្រមសុភាសិតអធិប្បាយភាគទី១

៣- **លី-ថៃលី** វចនានុក្រមសុភាសិតអធិប្បាយភាគទី២

៤- **ច័ន្ទ សំណាង** (១៩៩៩) វិជ្ជមានន័យ អវិជ្ជមានន័យ និងបរិធាតុរបស់វា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៥- **ច័ន្ទ សំណាង** (២០០២) គោលការណ៍នៃការបង្កើតពាក្យនិងកម្ចីពាក្យ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៦- **ច័ន្ទ សំណាង** (២០០៣) ធាតុវេយ្យាករប្រើសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៧- **ច័ន្ទ សំណាង** (២០០៦) ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ : តួនាទីនៃបុរេបទ **ភាវ** និងផ្នត់ជែក [-**អម/ណ**-] / [-**អឹម/ន**-] សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៨- អគ្គទត្តោ **គល់-សុភាព** ភាសាខ្មែរ

៩- **លី-ធាមតេង** កម្ពុជសុរិយា

១០- ខុកញ៉ាសុត្តន្តប្រីជាឥន្ទ គតិលោកភាគទី១

១១- ព្រះគ្រូមុនីសោភ័ណ **សេខ-នាង** សារញ្ញាណោ, បាលីវេយ្យាករណ៍, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៤៤ គ. ស. ២០០០

១២- ព្រះគ្រូសិរីសោភ័ណ **ភិម-ត្ន**, បទានុក្រមធម្មបទភាគទី១, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៣- ព្រះគ្រូសិរីសោភ័ណ **ភិម-ត្ន**, បទានុក្រមធម្មបទភាគទី២, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៤- ព្រះគ្រូសិរីសោភ័ណ **ភិម-ត្ន**, បទានុក្រមធម្មបទភាគទី៣, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៥- **អៀវ-កើស** ភាសាខ្មែរ

១៦- វចនានុក្រមខ្មែរ KHMER DICTIONARY, ការផ្សាយបណ្ណាគារអង្គរធំ ព. ស. ២៥៥៥ គ. ស. ២០១១

១៧- វេយ្យាករណ៍សំស្ក្រឹត

១៨- ធាតុសង្គ្រោះ

១៩- សព្ទានុក្រមពាក្យច្បាប់និងរដ្ឋបាល (អង់គ្លេស-បារាំង-ខ្មែរ)

២០- វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ, ការផ្សាយរបស់វិទ្យាស្ថានភាសាជាតិ

២១- ប្រស្នាកច្ចាយនូបត្ថម្ភកៈ កិតកនិទ្ទេស-ឧណាទិនិទ្ទេស, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

២២- **ហ៊ីង-ឆីប្ញធិ** អត្ថាធិប្បាយវចនានុក្រមច្បាប់

២៣- អៀង សាយ **មេភាព្យ** ព.ស. ២៥៤៨, គ.ស. ២០០៥

២៤- ឯកសារនានា